ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីពន្យល់ខ្លឹមសារសំណួរ ក្នុងសៀវភៅទិន្នន័យភូមិ

## សំរាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

354.968 DAT

រៀបចំដោយក្រុមការងារសិលានិងសិទ្ធិកុមារ ក្រសួងផែនការ

គាំទ្រដោយ: STF/PLG, Seth Koma Programme of UNICEF

ឆ្នាំ២០០៦

# អារម្ភកថា

សៀវភៅ "សេចក្ដីពន្យល់ពីខ្លឹមសារសំណួរ ក្នុងសៀវភៅទិន្នន័យភូមិ" ដែលបានរៀបចំឡើងនេះ ជាសេចក្ដីពន្យល់លំអិតអំពីស្ថិតិទាំងឡាយ ដែលត្រូវស្រង់ជារៀងរាល់ឆ្នាំនៅថ្នាក់ភូមិនិងនៅថ្នាក់ឃុំសង្កាត់ សំរាប់ប្រើប្រាស់ក្នុងការរៀបចំជាកំរងព័ត៌មានស្ថានភាពឃុំ សង្កាត់ដែលជាឯកសារបឋមផ្ដល់ឱ្យទៅការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រួមទាំងសំរាប់ផ្ទៀងផ្ទាត់ពីកំរិតអភិវឌ្ឍន៍កំរិតរីកចំរើនក្នុងមួយអណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

តួលេខស្ថិតិទាំងអស់ អាចស្រង់រួមគ្នា រវាងមេភូមិ សមាជិក គ.ផ.ថ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជនបង្គោលកិច្ចការនារី ប្រធានក្រុម ចាស់ទុំ ឬអ្នកមានចំណេះដឹងខ្ពស់នៅក្នុងភូមិ ។

តួលេខស្ថិតិទាំងអស់ ដែលស្រង់បានមកនេះនឹងត្រូវបានបញ្ជូនត្រឡប់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់ដោយខ្លួនឯងនៅពេលកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ក្រោមរូបភាពជាឯកសារស្ដីពីព័ត៌មានស្ថានភាពឃុំ សង្កាត់ ។ ហេតុនេះគុណភាពរបស់ទិន្នន័យដែលបានមកពីភូមិ ឃុំ សង្កាត់ គឺវាកំណត់ផ្ទាល់លើកំរិតគុណភាពរបស់ព័ត៌មានស្ថានភាពឃុំ សង្កាត់ ហើយព័ត៌មានស្ថានភាពឃុំសង្កាត់នឹងបង្កភាពងាយស្រួលឬលំបាកប្រើប្រាស់ក្នុងការពិចារណានៅពេលកសាងផែនការ ក៏ដូចជាកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ដែលទាំងនេះ គឺអាស្រ័យទាំងស្រុងទៅនឹងការយល់ឃើញ និងភាពជាក់លាក់ស្មោះត្រង់របស់អ្នកប្រមូលទិន្នន័យតាមភូមិ ឃុំ សង្កាត់ ។

NCDD Library
001359

ការប្រមូលទិន្នន័យភូមិ ឃុំ សង្កាត់នេះ មិនមែនជាការប្រមូលទិន្នន័យតាមបែបអង្កេតគំរូទេ ។ ម្ចាស់ទិន្នន័យភូមិ ឃុំ សង្កាត់ គឺមេភូមិ ចៅសង្កាត់ មេឃុំ ហើយមេភូមិ ចៅសង្កាត់ មេឃុំ គឺជាអ្នកគ្រប់គ្រងនិងប្រើប្រាស់ទិន្នន័យទាំងនេះដោយផ្ទាល់ ជាអ្នកទទួលផលពីទិន្នន័យទាំងនេះ ។

ខ្ញុំមានជំនឿនិងសង្ឃឹមថា មេភូមិ ស្មៀនឃុំ-សង្កាត់ មេឃុំ ចៅសង្កាត់ ប្រាកដជាយល់និងបែងចែកច្បាស់អំពីគោលបំណង និងអត្ថន័យ អត្ថប្រយោជន៍នៃការប្រមូលទិន្នន័យដោយទៀងទាត់នេះ និងការប្រមូលទិន្នន័យតាមការធ្វើអង្កេតគំរូនានា ។

ខ្ញុំសូមឱ្យការប្រមូលទិន្នន័យភូមិ ឃុំ សង្កាត់ បានប្រព្រឹត្តទៅដោយទៀងទាត់ ប្រកបដោយគុណភាព និងអារម្មណ៍ជាម្ចាស់ទិន្នន័យរបស់មេភូមិ មេឃុំ ចៅសង្កាត់ ត្រូវបានលើកកំពស់ជាជំហាន ដើម្បីបុព្វហេតុអភិវឌ្ឍន៍មូលដ្ឋានភូមិ ឃុំ សង្កាត់ ប្រកបដោយចិរភាព ការកាត់បន្ថយភាពក្រីក្របានដោយជោគជ័យ តាមស្មារតីនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាគឺ " ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា " ។

ភ្នំពេញ ថ្ងៃទី.......ខែ សីហា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

# ស្ថិតិថ្នាក់ភូមិ

## ស្ថានភាពប្រជាជននិងការអប់រំ

*ស្ថិតិគ្រួសារដែលមេភូមិទទួលស្គាល់នៅក្នុងឆ្នាំ .......... មានក្នុងតារាង ខាងក្រោម :*

| | | | |
|---|---|---|---|
| *1* | *ចំនួនគ្រួសារសរុបក្នុងភូមិ* | | *មាន .. គ្រួសារ* |
| *2* | *ក្នុងនោះ ចំនួនគ្រួសារដែលមានស្ត្រីជាមេគ្រួសារ* | | *មាន .... គ្រួសារ* |
| *3* | | *ក្នុងនោះ ស្ត្រីជាមេគ្រួសារមានកូនតូចអាយុ ក្រោម៥ឆ្នាំ* | *មាន ... គ្រួសារ* |

**សេចក្តីពន្យល់:**

**ចំនួនគ្រួសារសរុបក្នុងភូមិ :** គឺជាចំនួនគ្រួសារដែលកំពុងរស់ ក្នុងភូមិដែលមេភូមិទទួលស្គាល់ថា ជាសមាជិករស់នៅក្នុងភូមិរបស់គាត់ ។ ការរាប់ចំនួនគ្រួសារនេះ មិនគិតថាគ្រួសារនោះ ទើបតែផ្លាស់ប្តូរទីលំនៅមករស់នៅក្នុងភូមិទើបតែបានរយៈពេល៣ឬ៦ខែទេ គឺសំខាន់ឱ្យតែមេភូមិទទួលស្គាល់ថា គ្រួសារនោះជាសមាជិកនៅក្នុងភូមិរបស់គាត់ ។ ចំពោះគ្រួសារដែលចេញទៅប្រកបមុខរបរផ្សេងៗនៅក្រៅឃុំ ក៏ត្រូវរាប់បញ្ចូលផងដែរ ប្រសិនបើគ្រួសារទាំងនោះពុំទាន់មានការសុំផ្លាស់ប្តូរទីលំនៅពីមេភូមិ ហើយមេភូមិនៅតែ ទទួលស្គាល់ ។

**គ្រួសារដែលមានស្ត្រីជាមេគ្រួសារ :** មេគ្រួសារគឺជាមនុស្សមួយរូប ដែលគេទទួលស្គាល់ថា ជាមេនៅក្នុងគ្រួសារ ។ ចំពោះមេគ្រួសារជាស្ត្រីនេះ គឺសំដៅដល់ស្ត្រីដែលទទួលខុសត្រូវ ចាត់ចែងក្នុងគ្រួសារ ហើយធ្វើសេចក្តីសំរេចកិច្ចការនានាក្នុងនាមគ្រួសារ ទោះបីស្ត្រីនោះមានប្តីឬមេម៉ាយក៏ដោយ ។ នៅក្នុងប្រអប់សំណួរខាងលើនេះ តើនៅក្នុងភូមិមានប៉ុន្មានគ្រួសារកំពុងរស់នៅ ហើយក្នុងចំនួនគ្រួសារទាំងនោះ តើមានប៉ុន្មានគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ។

**គ្រួសារដែលមានមេគ្រួសារជាស្ត្រីមានកូនតូចអាយុក្រោម៥ឆ្នាំ :** គឺដូចប្រភេទគ្រួសារខាងលើដែរ ប៉ុន្តែកំពុងទទួលបន្ទុកចិញ្ចឹមកូនតូចអាយុក្រោម៥ឆ្នាំ ដែលប្រសូត្រចេញពីផ្ទៃរបស់ស្ត្រីជាមេគ្រួសារ។ ការស្រង់នេះ សំរាប់ឱ្យ គ.ផ.ថ ភូមិ ឃុំ គិតគូរជួយរកដំណោះស្រាយការលំបាក ឬស្វែងរកជំនួយឧបត្ថម្ភពីប្រភពផ្សេងៗចំពោះគ្រួសារប្រភេទនេះ ដែលភាសាបច្ចេកទេសហៅថា "ក្រុមជនងាយរងគ្រោះ"។ ជាទូទៅស្ត្រីជាមេគ្រួសារប្រភេទនេះ កំពុងត្រូវការជំនួយច្រើនយ៉ាងដូចជា ឥណទាន ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់មុខរបរ ឬការធ្វើពលកម្មការងារជិតៗផ្ទះ រហូតដល់កូនរបស់ខ្លួនមានអាយុធំជាង៥ឆ្នាំ ទើបអាចទៅធ្វើការងារឆ្ងាយពីផ្ទះបាន។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកជួយឧបត្ថម្ភនឹងធ្វើការពិនិត្យផ្ទៀងផ្ទាត់ភាពពិតជាក់លាក់ម្តងទៀត មុនពេលផ្តល់ជំនួយគាំទ្រ ។

# ស្ថិតិមនុស្សប្រុសនិងការអប់រំ

| | ស្ថិតិតាមក្រុមអាយុ | ចំនួន (នាក់) | កំពុងរៀននៅសាលាមត្តេយ្យ | | កំពុងរៀននៅសាលាចំណេះទូទៅ | ចំនួនអ្នកមិនចេះអក្សរ |
|---|---|---|---|---|---|---|
| | | | សហគមន៍ | រដ្ឋនិងឯកជន | | |
| 4 | ០-២ ឆ្នាំ | .... នាក់ | | | | |
| 5 | ៣-៤ ឆ្នាំ | .... នាក់ | ........ នាក់ | .......... នាក់ | | |
| 6 | ៥ ឆ្នាំ | .... នាក់ | ....... នាក់ | ......... នាក់ | | |
| 7 | ៦ ឆ្នាំ | .... នាក់ | | | ...... នាក់ | |
| 8 | ៧-១១ ឆ្នាំ | .... នាក់ | | | ...... នាក់ | |
| 9 | ១២-១៤ ឆ្នាំ | .... នាក់ | | | ...... នាក់ | |
| 10 | ១៥-១៧ ឆ្នាំ | .... នាក់ | | | ...... នាក់ | ..... នាក់ |
| 11 | ១៨-២៤ ឆ្នាំ | .... នាក់ | | | ...... នាក់ | ..... នាក់ |
| 12 | ២៥-៣៥ ឆ្នាំ | .... នាក់ | | | | ..... នាក់ |
| 13 | ៣៦-៤៥ ឆ្នាំ | .... នាក់ | | | | ..... នាក់ |
| 14 | ៤៦-៦០ ឆ្នាំ | .... នាក់ | | | | ..... នាក់ |
| 15 | ៦១ឆ្នាំឡើង | .... នាក់ | | | | |
| 16 | **សរុប** | .... នាក់ | ......... **នាក់** | ............. **នាក់** | ...... នាក់ | ..... នាក់ |

# ស្ថិតិមនុស្សស្រីនិងការអប់រំ

| | ស្ថិតិតាមក្រុមអាយុ | ចំនួន (នាក់) | កំពុងរៀននៅសាលាមត្តេយ្យ | | កំពុងរៀននៅសាលាចំណេះទូទៅ | ចំនួនអ្នកមិនចេះអក្សរ |
|---|---|---|---|---|---|---|
| | | | សហគមន៍ | រដ្ឋនិងឯកជន | | |
| 17 | ០-២ ឆ្នាំ | .... នាក់ | | | | |
| 18 | ៣-៤ ឆ្នាំ | .... នាក់ | ........ នាក់ | ......... នាក់ | | |
| 19 | ៥ ឆ្នាំ | .... នាក់ | ....... នាក់ | ......... នាក់ | | |
| 20 | ៦ ឆ្នាំ | .... នាក់ | | | ...... នាក់ | |
| 21 | ៧-១១ ឆ្នាំ | .... នាក់ | | | ...... នាក់ | |
| 22 | ១២-១៤ ឆ្នាំ | .... នាក់ | | | ...... នាក់ | |
| 23 | ១៥-១៧ ឆ្នាំ | .... នាក់ | | | ...... នាក់ | ..... នាក់ |
| 24 | ១៨-២៤ ឆ្នាំ | .... នាក់ | | | ...... នាក់ | ..... នាក់ |
| 25 | ២៥-៣៥ ឆ្នាំ | .... នាក់ | | | | ..... នាក់ |
| 26 | ៣៦-៤៥ ឆ្នាំ | .... នាក់ | | | | ..... នាក់ |
| 27 | ៤៦-៦០ ឆ្នាំ | .... នាក់ | | | | ..... នាក់ |
| 28 | ៦១ឆ្នាំឡើង | .... នាក់ | | | | |
| 29 | សរុប | .... នាក់ | ......... នាក់ | ............ នាក់ | ...... នាក់ | ..... នាក់ |

## សេចក្តីពន្យល់:

ស្ថិតិប្រជាជននេះ បានកត់ត្រាញែកគ្នារវាងបុរសនិងស្ត្រី ហើយទៅតាមក្រុមអាយុនិមួយៗ ។ ការកត់ត្រាតាមក្រុមអាយុនេះ សំខាន់ផ្តោតទៅលើការអប់រំ ដូចជា :

- ក្រុមអាយុ ៣-៤ ឆ្នាំ ជាវ័យកុមារមានឱកាសរៀននៅសាលាមត្តេយ្យសហគមន៍ មត្តេយ្យរដ្ឋ ឬសាលាមត្តេយ្យឯកជន ។

- អាយុ **៥** ឆ្នាំ ជាឆ្នាំដែលកុមារត្រៀមចូលរៀននៅថ្នាក់បឋមសិក្សា ដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវរៀបចំយុទ្ធនាការជំរុញអោយកុមារទាំងនោះបានទៅចុះឈ្មោះចូលរៀននៅឆ្នាំបន្ទាប់ ។
- ក្រុមអាយុ **៦-១១** ឆ្នាំកុមាររៀននៅសាលាបឋមសិក្សា (ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦) ។
- ក្រុមអាយុ **១២-១៤** ឆ្នាំរៀននៅសាលាអនុវិទ្យាល័យ (រៀនថ្នាក់ទី៧ ដល់ថ្នាក់ទី៩) ។
- ក្រុមអាយុ **១៥-១៧** ឆ្នាំរៀននៅសាលាវិទ្យាល័យ(ថ្នាក់ទី១០ដល់ថ្នាក់ទី១២) ។

ប្រសិនបើ យើងយកចំនួនស្ថិតិកុមារដែលកំពុងរៀន ដក ចំនួនសរុប ខាងលើ យើងបានចំនួនកុមារ ដែលមិនបានទៅរៀន ។ ចំនួនកុមារដែលមិនទៅរៀន ឬឈប់ទៅរៀននេះហើយដែលជាកង្វល់សំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ ផ្តោតការយកចិត្តទុកដាក់ថាតើអ្វីជា "មូលហេតុចំបង" ដែលកុមារមិនទៅរៀន ឬឈប់រៀនមុនអាយុធំពេញវ័យ ។ តើក្រុមប្រឹក្សាឃុំ-សង្កាត់មានយុទ្ធសាស្ត្រ បែបណាសំរាប់ដោះស្រាយបញ្ហាចំពោះមុខនានា ដើម្បីធានាអោយកុមារគ្រប់រូប មានឱកាសទៅសាលារៀនអោយបានគ្រប់ៗគ្នា ។

សំរាប់ស្ថិតិមនុស្សពេញវ័យ ពត៌មានសំខាន់ដែលត្រូវពិភាក្សានៅពេលរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ គឺ :

- ក្រុមអាយុ**១៥-១៧**ឆ្នាំដែលមិនបានរៀនឬបោះបង់ការសិក្សានៅថ្នាក់បឋមសិក្សា( មិនចេះអក្សរ) ។
- ក្រុមអាយុ **១៨-២៤** ឆ្នាំកំពុងរៀន ជាចំនួន ដែលអាចមានចំពោះសិស្សដែលបានចូលរៀនមានការយឺតយ៉ាវ ឬរៀនត្រួតថ្នាក់ (បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ) ឬកំពុងនៅរៀននៅសាលាវិជ្ជាជីវៈផ្សេងៗទៀត ។

• ក្រុមអាយុ **១៨-២៤ , ២៥-៣៥** និង **៣៦-៤៥** ឆ្នាំ ចំពោះមនុស្សស្រីជាវ័យបន្តពូជ ដែលចាំបាច់ត្រូវកត់ត្រាអោយដឹងពីចំនួនអ្នកមិនចេះអក្សរ ដែលងាយស្រួលក្នុងការរៀបចំវគ្គផ្សព្វផ្សាយផ្នែកសុខភាព ។

**ជនមិនចេះអក្សរ :** គឺជាជនដែលមិនអាចអានអក្សរបានត្រឹមត្រូវក្នុងអត្ថបទពី៥ទៅ៦បន្ទាត់ និង មិនអាចសរសេរបានពី ៣ទៅ៤បន្ទាត់ ។

ការកត់ត្រាចំនួនស្ថិតិប្រជាជនមិនចេះអក្សរមានសារៈសំខាន់ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអ្នកជួយគាំទ្រកិច្ចអភិវឌ្ឍន៍ឃុំ-សង្កាត់ (មន្ទីរជំនាញអង្គការនានា)ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលផ្សេងៗ សំរាប់អ្នកភូមិដូចជា:

-កម្មវិធីចូលរៀនឡើងវិញ ឬ កម្មវិធីអក្ខរកម្មសំរាប់ប្រជាជន អាយុពី១៥-១៧ឆ្នាំ ។

-កម្មវិធីអក្ខរកម្មនិងបណ្តុះបណ្តាលវិជ្ជាជីវៈងាយៗសំរាប់ក្រុមអាយុ១៨ឆ្នាំឡើង ។

សូមចងចាំថា វិធីសាស្ត្របណ្តុះបណ្តាលសំរាប់អ្នកមិនចេះអក្សរ និងអ្នកចេះអក្សរ ត្រូវរៀបចំឡើងដោយឡែកពីគ្នា និងតាមវិធីបង្រៀនខុសពីគ្នា ដោយប្រើរូបភាពជំនួសអក្សរ ។

## ទីតាំងសាលារៀននានា ធៀបនឹងចំនុចកណ្តាលភូមិ

*ប្រសិនបើទីតាំងសាលារៀន (បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ) មាននៅក្នុងភូមិតែម្តង គឺកត់យកចំងាយ **សូន្យ** គ.ម ។ ចំពោះសាលាបឋមសិក្សានិងអនុវិទ្យាល័យ ឬ អនុវិទ្យាល័យនិងវិទ្យាល័យនៅជាមួយគ្នា គឺមានចំងាយដូចគ្នា។*

| | | |
|---|---|---|
| 30 | ចំងាយផ្លូវពីចំនុចកណ្តាលភូមិទៅដល់សាលា**បឋមសិក្សា** (ថ្នាក់ទី **១** ដល់ថ្នាក់ទី **៦**) | ចំងាយ... គ.ម |
| 31 | ចំងាយផ្លូវពីចំនុចកណ្តាលភូមិទៅដល់សាលា**អនុវិទ្យាល័យ** (ថ្នាក់ទី **៧** ដល់ថ្នាក់ទី **៩**) | ចំងាយ... គ.ម |
| 32 | ចំងាយផ្លូវពីចំនុចកណ្តាលភូមិទៅដល់សាលា**វិទ្យាល័យ** (ថ្នាក់ទី **១០** ដល់ថ្នាក់ទី **១២**) | ចំងាយ... គ.ម |

ស្ថិតិនេះមានសារៈសំខាន់ក្នុងការជួយពន្យល់ឬឆ្លុះបញ្ចាំងថាតើ មាន "មូលហេតុអ្វី" បានជាកុមារមិនទៅ ឬឈប់ទៅរៀនដូចមានក្នុងស្ថិតិខាងលើ ។ ប៉ុន្តែគួរពិចារណាថា ចំងាយផ្លូវគ្រាន់តែជាមូលហេតុមួយ ក្នុងចំនោមមូលហេតុផ្សេងៗប៉ុណ្ណោះ មានន័យថា ចំងាយផ្លូវទៅសាលា មិនមែនជាកត្តាតែមួយគត់ដែលត្រូវពិចារណាឡើយ ក្នុងនោះអាចមាន កត្តាឪពុកម្តាយ សន្តិសុខ ឬ ឧបសគ្គផ្សេងៗទៀតជាច្រើន (អាស្រ័យតាមការពិភាក្សារបស់គ.ផ.ថ) ។

# ស្ថិតិមុខរបរ

*ការកត់ត្រាស្ថិតិមុខរបរនេះ សំដៅយកមុខរបរចំបងដែលមានចំណូលជាសំខាន់ក្នុងការទ្រទ្រង់ជីវភាពគ្រួសារ ចំពោះមុខរបរបន្ទាប់បន្សំមិនត្រូវកត់ត្រាឡើយ ។ ដូចនេះ ផលបូកចំនួនគ្រួសារដែលប្រកបមុខរបរជាចំបង អាចស្មើឬតិចជាងចំនួនគ្រួសារសរុបក្នុងភូមិ ព្រោះមិនបានរាប់បញ្ចូលចំនួនគ្រួសារដែលគ្មានមុខរបរច្បាស់លាស់ ។*

*ធ្វើស្រែ ( បើគ្មានបំពេញលេខសូន្យ)*

| | | |
|---|---|---|
| 33 | *ចំនួនគ្រួសារកសិករធ្វើស្រូវស្រែជាចំបង* | *មាន.... គ្រួសារ* |
| 34 | *ចំនួនគ្រួសារកសិករធ្វើស្រូវចំការជាចំបង* | *មាន..... គ្រួសារ* |
| 35 | ***សរុបចំនួនគ្រួសារកសិករដែលប្រកបរបរ ដាំដុះស្រូវ ជាចំបង*** | ***មាន.... គ្រួសារ*** |

**គ្រួសារដែលប្រកបរបរដាំដុះស្រូវជាចំបង** : គឺជាប្រភេទគ្រួសារដែលយកមុខរបរធ្វើស្រូវស្រែ ឬធ្វើស្រូវចំការ ជាចំណូលសំខាន់ក្នុងការទ្រទ្រង់ជីវភាពគ្រួសារ ។

**សរុបចំនួនគ្រួសារដែលប្រកបរបរដាំដំណាំស្រូវជាចំបង=** ចំនួនគ្រួសារកសិករធ្វើស្រូវស្រែជាចំបង**+** ចំនួនគ្រួសារធ្វើស្រូវចំការជាចំបង ។

*ធ្វើចំការ ( បើគ្មានបំពេញលេខសូន្យ)*

| | | |
|---|---|---|
| 36 | *ចំនួនគ្រួសារដែលប្រកបរបរ ដាំដំណាំរយៈពេលវែង ជាចំបង* | *មាន....... គ្រួសារ* |
| 37 | *ចំនួនគ្រួសារដែលប្រកបរបរ ដាំដំណាំរយៈពេលខ្លី ជាចំបង* | *មាន....... គ្រួសារ* |
| 38 | *ចំនួនគ្រួសារដែលប្រកបរបរ ដាំដំណាំបន្លែ ជាចំបង* | *មាន....... គ្រួសារ* |
| 39 | ***សរុបចំនួនគ្រួសារដែលប្រកបរបរ ធ្វើចំការ ជាចំបង*** | ***មាន....... គ្រួសារ*** |

**ដំណាំរយៈពេលវែង :** សំដៅទៅលើដំណាំដែលប្រមូលផលរយៈពេលយូរអង្វែង ដូចជា ដូង ល្មុត ធូរេន ស្វាយចន្ទី សាវម៉ាវ កៅស៊ូ ម្រេច ចេក ... ។ល។ ដែលភាគច្រើនយើងមានទំលាប់ហៅថា ធ្វើចំការ ។

**ដំណាំរយៈពេលខ្លី** : សំដៅទៅលើដំណាំដែលប្រមូលផលក្នុងរយៈពេលខ្លី ហើយដាំឡើងវិញ ដូចជា សណ្តែក ល្ង ពោត ម្ទេស ឳឡឹក ដំឡូង ត្រាវ ប៉ិះគួក ... ។ល។

**ដាំដំណាំបន្លែ :** សំដៅទៅលើដំណាំបន្លែ ដូចជា ស្ពៃ សាលាដ់ ខាត់ណា ថៃថាវ ការ៉ុត ប៉េងប៉ោះ បណ្ដុះផ្សិត .... ។ល។ ដោយរួមបញ្ចូលទៅលើគ្រួសារណា ដែលប្រកបរបរដាំផ្កាលក់ជាចំបង ផងដែរ ។

**សរុបចំនួនគ្រួសារដែលប្រកបរបរធ្វើចំការជាចំបង =** ចំនួនគ្រួសារដែលប្រកបរបរដាំដំណាំរយៈពេលវែង**+** ចំនួនគ្រួសារដែលប្រកបរបរដាំដំណាំរយៈពេលខ្លី **+** ចំនួនគ្រួសារដែលប្រកបរបរដាំដំណាំបន្លែជាចំបង ។

***នេសាទ ចិញ្ចឹមសត្វ អនុផលព្រៃឈើ (បើគ្មានបំពេញលេខសូន្យ)***

| | | |
|---|---|---|
| *40* | *ចំនួនគ្រួសារដែលប្រកបរបរ **ធ្វើនេសាទ** ជាចំបង* | *មាន ........... គ្រួសារ* |
| *41* | *ចំនួនគ្រួសារដែលប្រកបរបរ **ចិញ្ចឹមសត្វ**ជាចំបង* | *មាន ........... គ្រួសារ* |
| *42* | *ចំនួនគ្រួសារដែលប្រកបរបរចំបងពី **អនុផលព្រៃឈើ*** | *មាន ........... គ្រួសារ* |

**ចំនួនគ្រួសារដែលប្រកបរបរធ្វើនេសាទជាចំបង :** សំដៅទៅលើគ្រួសារមួយចំនួន ដែលរស់នៅចិញ្ចឹមជីវិតពឹងផ្អែកតែលើការនេសាទ ។

**ចំនួនគ្រួសារដែលប្រកបរបរចិញ្ចឹមសត្វជាចំបង :** សំដៅទៅលើគ្រួសារដែលប្រកបរបរចិញ្ចឹមសត្វជាមុខរបរចំបង ដូចជាចិញ្ចឹមគោ-ក្របី ចៀម ពពែ យកសាច់និងទឹកដោះ ការចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ទាជាហ្វូង ឬជាកសិដ្ឋាន ដើម្បីយកពងឬសាច់លក់ រួមទាំងគ្រួសារណាដែលចិញ្ចឹម ត្រី ក្ដាម បង្គា បង្កង ជាមុខរបរចំបងផងដែរ ។

**ចំនួនគ្រួសារដែលប្រកបរបរចំបងពីអនុផលព្រៃឈើ :** សំដៅទៅលើគ្រួសារមួយចំនួនដែលប្រកបរបរចំបងពីអនុផលព្រៃឈើ ដូចជាបោចវល្លិ៍ ល្ពាក់ ឬស្សី ..... ។ល។

***សិប្បកម្ម (បើគ្មានបំពេញលេខសូន្យ)***

| | | |
|---|---|---|
| 43 | *ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មផលិតគ្រឿងសង្ហារឹមពីឈើ ផ្តៅ វល្លិ៍ ល្ពាក់ ឬស្សី* | *មាន........ គ្រួសារ* |
| 44 | *ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម កញ្ចក់* | *មាន........ គ្រួសារ* |
| 45 | *ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មផលិតគ្រឿងបរិភោគ(គុយទាវ ទឹកស៊ីអ៊ីវ ...)* | *មាន........ គ្រួសារ* |
| 46 | *ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មផលិតសំបកពោះវៀនកង់ ម៉ូតូ គ្រឿងជ័រផ្លាស្ទិក* | *មាន........ គ្រួសារ* |
| 47 | *ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មត្បាញរវៃ (ត្បាយក្រម៉ា ហូល ផាមួង សារុង កន្ទេល)* | *មាន........ គ្រួសារ* |
| 48 | *ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មផលិតផ្សេងៗ (ដែលគ្មានឈ្មោះខាងលើ)* | *មាន........ គ្រួសារ* |
| 49 | ***សរុបចំនួនគ្រួសារដែលប្រកបរបរ សិប្បកម្ម ជាចំបង*** | ***មាន........ គ្រួសារ*** |

**ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មផលិតគ្រឿងសង្ហារឹមពីឈើ ផ្តៅ វល្លិ៍ ល្ពាក់ ឬស្សី :** សំដៅទៅលើគ្រួសារមួយចំនួនដែលប្រកបមុខរបរចំបង ក្នុងការកែច្នៃពីរបស់អ្វីមួយទៅរបស់អ្វីមួយទៀត ដូចជាសិប្បកម្មធ្វើគ្រឿងសង្ហារឹមអំពីឈើ : តុ ទូ កៅអី ក្តារបន្ទះ ផលិតផលឈើអារផ្សេងៗ ។

**ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម កញ្ចក់ :** សំដៅទៅលើគ្រួសារណាដែលមានមុខរបរធ្វើសិប្បកម្ម ផលិតទ្វា បង្អួចដែក ទូកញ្ចក់ អាលុយមីញ៉ូម ... ។

**ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មផលិតគ្រឿងបរិភោគ :** សំដៅទៅលើគ្រួសារណាដែលមានមុខរបរធ្វើសិប្បកម្ម ដូចជាសិប្បកម្មផលិតនំបញ្ចុក

បាញ់ហាយ នំដុត គុយទាវ មី ស្ករគ្រាប់ ការ៉េម បិទស្រា សៀង ទឹកស៊ីអ៊ីវ ទឹកត្រី ទឹកបរិសុទ្ធ ធ្វើទឹកកក ទឹកគ្រួច។ល។

**ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មផលិតផ្សេងៗ** : សំដៅទៅលើគ្រួសារណាដែលមានមុខរបរធ្វើសិប្បកម្ម ដូចជាសិប្បកម្មឡអិដ្ឋ ក្បឿង ការសំលាប់និងសំអាតកែច្នៃស្បែក សិប្បកម្មធ្វើម្សៅមី ចំណីសត្វ...។ល។

**សរុបចំនួនគ្រួសារដែលប្រកបរបរសិប្បកម្មជាចំបង** = ចំនួនគ្រួសារដែលប្រកបរបរសិប្បកម្ម ផលិតគ្រឿងសង្ហារឹមពីឈើ ផ្តៅ វល្លិ៍ ល្ពាក់ ឫស្សី + ចំនួនគ្រួសារប្រកបរបរសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម កញ្ចក់ + ចំនួនគ្រួសារប្រកបរបរសិប្បកម្មផលិតគ្រឿងបរិភោគ + ចំនួនគ្រួសារប្រកបរបរសិប្បកម្មផលិតសំបកពោះវៀនកង់ម៉ូតូ គ្រឿងជ័រផ្លាស្ទិក + ចំនួនគ្រួសារប្រកបរបរសិប្បកម្មត្បាញរវៃ + ចំនួនគ្រួសារប្រកបរបរសិប្បកម្មផលិតផ្សេងៗ ។

***សេវាកម្ម ( បើគ្មានបំពេញលេខសូន្យ)***

| | | |
|---|---|---|
| *50* | *ចំនួនគ្រួសារដែលប្រកបរបរ **ធ្វើជំនួញ** ជាចំបង* | *មាន........... គ្រួសារ* |
| *51* | *ចំនួនគ្រួសារដែលប្រកបរបរ **ធ្វើជាងជួសជុល** ជាចំបង* | *មាន........... គ្រួសារ* |
| *52* | *ចំនួនគ្រួសារដែលប្រកបរបរ **ដឹកជញ្ជូន** ជាចំបង* | *មាន........... គ្រួសារ* |
| *53* | *ចំនួនគ្រួសារដែលប្រកបរបរ **សេវាកម្មផ្សេងៗ** ជាចំបង* | *មាន........... គ្រួសារ* |

**ចំនួនគ្រួសារដែលប្រកបរបរធ្វើជំនួញជាចំបង** : សំដៅទៅលើគ្រួសារមួយចំនួនដែលប្រកបរបរក្នុងការលក់ដុំឬលក់រាយជាចំបង ។ ការលក់ដុំឬរាយមានដូចជា គ្រឿងចាប់ហួញ ភេសជ្ជៈ លក់ត្រី សាច់ បន្លែ ផ្លែឈើ លក់គ្រឿងសំអាង ប្រាក់ មាស ពេជ្រ ប្តូរប្រាក់ សំលៀកបំពាក់ ស្បែកជើង

លក់គ្រឿងសំណង់ យានយន្តគ្រឿងបន្លាស់ គ្រឿងប្រដាប់ប្រដារដើរដោយអគ្គិសនី គ្រឿងម៉ាស៊ីន សំភារសិក្សា..... ។ល។

**ចំនួនគ្រួសារដែលប្រកបរបរធ្វើជាងជួសជុល :** សំដៅទៅលើគ្រួសារមួយចំនួនដែលប្រកបរបរចំបងធ្វើជាង ឬជាងជួសជុលដូចជា ជាងជួសជុលកង់ម៉ូតូ ជាងជួសជុលគ្រឿងអេឡិចត្រូនិក (វិទ្យុ ម៉ាញេ ទូរទស្សន៍ ទូទឹកកក ម៉ាស៊ីនត្រជាក់ ទូរសព្ទ កុំព្យូទ័រ។ល។) ជាងជួសជុលគ្រឿងម៉ាស៊ីន(រថយន្ត ត្រាក់ទ័រ គោយន្ត ម៉ាស៊ីនបូមទឹក) ជាងដែក ជាងភ្លើង ជាងឈើ ជាងមាស ប្រាក់ ជាងកាត់សក់ អ៊ុតសក់ កាត់ដេរ ជាងចម្លាក់ឈើ ថ្ម .... ។ល។

**ចំនួនគ្រួសារដែលប្រកបរបរដឹកជញ្ជូនជាចំបង :** សំដៅទៅលើគ្រួសារដែលមានមុខរបរចំបងក្នុងការដឹកជញ្ជូន(ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស) ដូចជារត់ម៉ូតូឌុប ត្រីចក្រយានយន្ត ធាក់ស៊ីក្លូ ស៊ីឈ្នួល ឬបើកឡានតាក់ស៊ី ឡានដឹកទំនិញ គ្រឿងសំណង់ បើកកាណូត រត់ទូកដរ ..... ។ល។

**ចំនួនគ្រួសារដែលប្រកបរបរសេវាកម្មផ្សេងៗជាចំបង :** សំដៅទៅលើគ្រួសារដែលមានមុខរបរជាម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ឬក្រុមហ៊ុនសេវាកម្មផ្សេងៗដែលជាមុខរបរសំខាន់របស់គ្រួសារ ។ ការកត់ត្រានេះរួមបញ្ចូលផងដែរនូវគ្រួសារណាដែលមានមុខរបរចំបង(ទទួលប្រាក់ខែ) ពីធ្វើការងារជា កម្មករឬបុគ្គលិក របស់អង្គការ ឬក្រុមហ៊ុនឯកជននានា ។

| | | |
|---|---|---|
| 54 | *ចំនួនគ្រួសារដែលមានសមាជិកជា* ***មន្ត្រី-បុគ្គលិក-កម្មករ*** *ក្នុងក្របខ័ណ្ឌរដ្ឋ* | *មាន .......... គ្រួសារ* |
| 55 | *ចំនួនគ្រួសារដែលមានសមាជិកជា* ***បុគ្គលិក-កម្មករ*** *ក្នុងក្របខ័ណ្ឌឯកជន* | *មាន .......... គ្រួសារ* |

**ចំនួនគ្រួសារដែលមានសមាជិកជាមន្ត្រី-បុគ្គលិក-កម្មករក្នុងក្របខ័ណ្ឌរដ្ឋ :** សំដៅទៅលើគ្រួសារណានៅក្នុងភូមិ ដែលមានសមាជិកម្នាក់ឬច្រើននាក់ ក្នុងគ្រួសារជាមន្ត្រីរាជការ ឬបំរើ ការងារក្នុងក្របខណ្ឌ័រដ្ឋ ដូចជា គ្រូបង្រៀន ទាហាន ប៉ូលីស ប៉េអឹម ស្មៀនឃុំ .....។ ដោយឡែក ចំពោះសមាជិកក្រុមប្រឹក្សាឃុំមិនត្រូវកត់ត្រាឡើយ ។

**ចំនួនគ្រួសារដែលមានសមាជិកជាបុគ្គលិក-កម្មករក្នុងក្របខ័ណ្ឌឯកជន :** សំដៅលើគ្រួសារនៅក្នុងភូមិ ដែលមានសមាជិកម្នាក់ឬច្រើននាក់ក្នុងគ្រួសារទៅបំរើការងារឯកជន ដូចជាកម្មករ រោងចក្រ កាត់ដេរ រោងចក្រស្បែកជើង រោងចក្រម្សៅមី កម្មករសំណង់ បុគ្គលិកក្រុមហ៊ុន សណ្ឋាគារ ភោជនីយដ្ឋាន ... ។ល។

ចំពោះគ្រួសារមួយមានសមាជិកជាមន្ត្រីរាជការ និងសមាជិកផ្សេងទៀតបំរើការងារក្នុងក្របខណ្ឌ័ឯកជន ករណីនេះត្រូវកត់ត្រាក្នុងសំណួរទាំងពីរខាងលើ ។

| | | | |
|---|---|---|---|
| *56* | *ចំនួនមនុស្សទៅរកស៊ី ឬបំរើការងារក្នុងក្រុមហ៊ុនរោងចក្រ (មុខរបរច្បាស់លាស់)* | *សរុប........ នាក់* | *ស្រី.... នាក់* |
| *57* | *ចំនួនមនុស្សទៅរកស៊ីមិនដឹងពីមុខរបរច្បាស់លាស់* | *សរុប........ នាក់* | *ស្រី.... នាក់* |
| *58* | ***សរុបចំនួនមនុស្សធ្វើចំណាកស្រុក*** | ***សរុប........ នាក់*** | ***ស្រី.... នាក់*** |

ការធ្វើចំណាកស្រុកទៅរកស៊ីដោយដឹងពីមុខរបរច្បាស់លាស់ឬមិនច្បាស់លាស់ អាស្រ័យទៅលើមេភូមិជាអ្នកកំណត់ ។ ការកត់ត្រាចំនួនមនុស្សធ្វើចំណាកស្រុក សំដៅទៅលើមនុស្សដែលនៅ ក្នុងភូមិបានចេញទៅរកការងារធ្វើ ឬទៅធ្វើការងារ ឬទៅរកស៊ី បាត់មុខពីភូមិរយៈពេលពេញ មួយឆ្នាំ ឬច្រើនឆ្នាំ

ដោយយកថ្ងៃខែស្រង់ទិន្នន័យធ្វើជាគោល ។ ដោយឡែក ចំពោះអ្នកធ្វើចំណាកស្រុក ដូចជានៅក្នុងរដូវប្រាំង ទៅរកការងារធ្វើនៅភ្នំពេញរយៈពេល១អាទិត្យ ១ខែ ឬច្រើនខែ ជា កម្មករសំណង់ ទៅរត់ម៉ូតូឌុប ធាក់ស៊ីក្លូ ... ហើយនៅរដូវធ្វើស្រែត្រឡប់មកធ្វើស្រែវិញ ជនធ្វើចំណាកស្រុកប្រភេទនេះ មេភូមិមិនត្រូវកត់ត្រាឡើយ ។

**សរុបចំនួនមនុស្សធ្វើចំណាកស្រុក =** ចំនួនមនុស្សទៅរកស៊ីឬបំរើការងារច្បាស់លាស់ ✚ ចំនួនមនុស្សទៅរកស៊ីមិនដឹងមុខរបរច្បាស់លាស់។

| | | | |
|---|---|---|---|
| *59* | *ចំនួនប្រជាជនចូលរួមក្នុងការងារសង្គមស៊ីវិល* | *សរុប....... នាក់* | *ស្រី..... នាក់* |
| *60* | *ចំនួនមនុស្សអាយុ១៨-៦០ ដែលគ្មានការងារធ្វើពិតប្រាកដនិងទៀងទាត់* | *សរុប....... នាក់* | *ស្រី..... នាក់* |

**ចំនួនប្រជាជនចូលរួមក្នុងការងារសង្គមស៊ីវិល** : សំដៅទៅលើចំនួនប្រជាជននៅក្នុងភូមិដែលបានចូលរួមបំពេញការងារផ្សេងៗក្នុងសង្គមស៊ីវិល ដូចជា គណៈកម្មការនានា សហគមន៍ សមាគមន៍ ដែលរៀបចំចាត់ចែងដឹកនាំសកម្មភាពនានា ទាក់ទងនឹងផលប្រយោជន៍សហគមន៍ឬប្រជាជន ឬក្រុមទោះជាមានឬគ្មានការទទួលស្គាល់ពីឃុំក៏ដោយ ។ ឧទាហរណ៍ : អ្នកស្មគ្រ័ចិត្តសុខភាពភូមិ កាកបាតក្រហម ....។

**ចំនួនមនុស្សអាយុ១៨-៦០ដែលគ្មានការងារធ្វើពិតប្រាកដនិងទៀងទាត់** : សំដៅមនុស្សមួយចំនួននៅក្នុងភូមិ ដែលពុំមានប្រកបរបរអ្វីជាដុំកំភួន ឬជួយរកចំណូលក្នុងគ្រួសារ ប៉ុន្តែដើរលេងល្បែង ស៊ីសង ជល់មាន់ ផឹកគ្រឿងស្រវឹងជាប្រចាំ ( ដោយពុំរាប់បញ្ចូលសិស្ស-និស្សិតដែលកំពុងបំពេញការសិក្សា ឬអ្នកមានជំងឺប្រចាំកាយឡើយ) ។ ជាតួលេខស្ថិតិដែលត្រូវលើកឡើងនៅក្នុងក្រុម

ប្រឹក្សាឃុំ-សង្កាត់ ដើម្បីរកមធ្យោបាយដោះស្រាយ ជាការបណ្ដុះបណ្ដាលឬតាមរយៈសកម្មភាពសង្គមផ្សេងៗ ។

# ស្ថានភាពផ្នែកកសិកម្មនិងធនធានធម្មជាតិ

*នៅក្នុងភូមិយើងខ្ញុំ ឆ្នាំនេះមាន :*

| | | | |
|---|---|---|---|
| 61 | ***សរុបចំនួនគ្រួសារកសិករដែលប្រកបរបរ ដាំដុះស្រូវជាចំបង (ដូចក្នុងបន្ទាត់លេខ៣៥ )*** | | *មាន ......... គ្រួសារ* |
| 62 | *ក្នុងនោះ* | *ចំនួនគ្រួសារមានដីស្រែតិចជាង១ហិកតា* | *មាន .......... គ្រួសារ* |
| 63 | | *ចំនួនគ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន* | *មាន .......... គ្រួសារ* |

**សរុបចំនួនគ្រួសារកសិករដែលប្រកបរបរដាំដុះស្រូវជាចំបង :** គឺសំដៅលើប្រភេទគ្រួសារដែលពឹងផ្អែកលើសកម្មភាពដាំដុះស្រូវជាចំបង ដើម្បីរកចំណូលមកចិញ្ចឹមគ្រួសារ ដូចដែលមានកត់ត្រារួចហើយ នៅក្នុងសំណួរទី៣៥ផ្នែកស្ថិតិមុខរបរ។ ការកត់ត្រានេះ ដើម្បីរំលេចឱ្យឃើញថា តើនៅក្នុងចំណោមគ្រួសារដែលមានមុខរបរដាំដុះស្រូវជាចំបងនោះ មានប៉ុន្មានគ្រួសារមានដីស្រែតិចជាងមួយហិកតា និងមានប៉ុន្មានគ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន ដោយធ្វើស្រែជួលដីរបស់គេ ឬធ្វើស្រែប្រវាស់ជាមួយម្ចាស់ដី ឬស៊ីឈ្នួលធ្វើស្រែឱ្យគេ ។

| | | |
|---|---|---|
| 64 | *ចំនួនគ្រួសារមានដីស្រែទទួលទឹកបានពីប្រព័ន្ធធារាសាស្ត្រ* | *មាន ....... គ្រួសារ* |
| 65 | *ចំនួនគ្រួសារមានអណ្ដូងទឹកសំរាប់ស្រោចស្រព (អណ្ដូងកសិកម្ម)* | *មាន ...... គ្រួសារ* |
| 66 | *ចំនួនអណ្ដូងទឹកសំរាប់ស្រោចស្រព(អណ្ដូងកសិកម្ម)* | *មាន ...... អណ្ដូង* |

**ចំនួនគ្រួសារមានដីស្រែទទួលទឹកបានពីប្រពន្ធ័ធារាសាស្ត្រ :** ការកត់ត្រាចំនួនគ្រួសារនេះ គឺសំដៅលើគ្រួសារដែលមានដីស្រែទទួលបានទឹកស្រោចស្រព ឬអាចបូមទឹកបាននៅពេលមានការរាំងស្ងួត ពីប្រពន្ធ័ប្រឡាយ ទំនប់ទឹក អាងទឹក

ឬប្រព័ន្ធធារាសាស្ត្រ ដូចជានៅតាមតំបន់ខ្លះ(តំបន់មាត់សមុទ្រ) សំរាប់ទប់ទឹកប្រៃកុំអោយចូលលិចស្រូវ និងសំរាប់បង្ហូរទឹកសាបចេញ ។ ការកត់ត្រានេះមិនបានកំណត់ថាទាល់តែគ្រួសារទាំងនោះ មានដីស្រែទាំងអស់ជាប់ប្រពន្ធ័ប្រឡាយឬទំនប់ធារាសាស្ត្រនោះទេ គឺឱ្យតែមានដីស្រែខ្លះបានទទួលទឹកពីប្រឡាយ ឬមានប្រភពទឹកអាចបូមពីប្រឡាយ ឬទទួលផលប្រយោជន៍ពីទំនប់ទាំងនោះក៏កត់ត្រាដែរ ព្រោះគ្រួសារទាំងនោះត្រូវមានភារៈកិច្ចរួមចំណែកថែទាំប្រឡាយ ឬទំនប់ទាំងនោះទៅថ្ងៃមុខដែរ ។

**ចំនួនអណ្តូងទឹកសំរាប់ស្រោចស្រព(អណ្តូងកសិកម្ម) :** គឺសំដៅទៅលើអណ្តូងទាំងឡាយណា ដែលកសាងឡើងបំរើឱ្យការស្រោចស្រពតែប៉ុណ្ណោះ ដូចជាអណ្តូងជីកនៅតាមវាលស្រែ ឬតាមចំការ ដែលសំរាប់ស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗ ។

ការស្រង់ស្ថិតិចំនួនអណ្តូងនេះ គឺដើម្បីយកទៅពិភាក្សាក្នុងក្រុមប្រឹក្សាឃុំសង្កាត់ ថាតើសំរាប់រយៈពេលយូរអង្វែងទៅមុខ ឃុំសង្កាត់គួរមានយុទ្ធសាស្ត្របែបណា ដើម្បីដោះស្រាយផ្នែកប្រភពទឹកស្រោចស្រព ជាពិសេសក្នុងករណីអណ្តូងទាំងអស់នោះពុំមានទឹកគ្រប់គ្រាន់ មានន័យថាប្រភពទឹកក្រោមដីត្រូវបានរីងស្ងួត ។ ត្រូវចងចាំថា ការប្រើអណ្តូងស្រោចស្រពគ្រាន់តែជាមធ្យោបាយបណ្តោះអាសន្នប៉ុណ្ណោះ ឃុំសង្កាត់មិនត្រូវចាត់ទុកថានេះជាយុទ្ធសាស្ត្រសមស្របយូរអង្វែងឡើយ ។

| | | |
|---|---|---|
| *67* | *ទិន្នផលស្រូវវស្សាជាមធ្យមក្នុង១ហិកតាមានប្រហែល ...................... តោន* | |
| *68* | *ទិន្នផលស្រូវប្រាំងជាមធ្យមក្នុង១ហិកតាមានប្រហែល ........................... តោន* | |
| *69* | *ក្នុងឆ្នាំនេះតំលៃស្រូវលក់ចេញក្នុង១គីឡូក្រាមមាន* | *តំលៃខ្ពស់បំផុត ............. រៀល* |
| *70* | | *តំលៃទាបបំផុត ............. រៀល* |

ការស្រង់ស្ថិតិនេះ មានសារៈសំខាន់សំរាប់លើកយកទៅពិភាក្សាក្នុង ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការគ្រោងរៀបចំវគ្គបណ្តុះបណ្តាលផ្នែកកសិកម្ម អំពីវិធីប្រើជីកំប៉ុស្តិ៍ ជីគីមី ថ្នាំសំលាប់សត្វល្អិត និងវិធីផ្សេងៗ ដែលអាចជួយបង្កើនទិន្នផលស្រូវនិងគុណភាពផលិតផលស្រូវ ព្រមទាំងតំលៃស្រូវផងដែរ។ ទិន្នន័យនេះ ជាការប៉ាន់ស្មានប្រហាក់ប្រហែល តាមទស្សនៈរបស់មេភូមិផ្ទាល់ ហើយអាចខុសគ្នាពីការប៉ាន់ស្មាននៅថ្នាក់ឃុំ និងថ្នាក់ស្រុក ដោយមន្ត្រីដែលមានជំនាញជាក់លាក់ ។ ដោយសារតំលៃស្រូវមានការប្រែប្រួល ទៅតាមពេលវេលានិមួយៗ ហេតុនេះ ការកត់ត្រាគឺសំដៅយកតំលៃដែលលក់ចេញបានខ្ពស់បំផុត និងទាបបំផុត ក្នុងរយៈពេល១២ខែកន្លងមកនេះ ។

| | | | |
|---|---|---|---|
| 71 | ***សរុបចំនួនគ្រួសារដែលប្រកបរបរធ្វើចំការជាចំបង (ដូចក្នុងបន្ទាត់លេខ៣៩)*** | | ***មាន ......... គ្រួសារ*** |
| 72 | *ក្នុងនោះ* | *ចំនួនគ្រួសារមានដីដាំដំណាំចំការតិចជាង១ហិកតា* | *មាន ......... គ្រួសារ* |
| 73 | | *ចំនួនគ្រួសារគ្មានដីធ្វើចំការផ្ទាល់ខ្លួន* | *មាន ......... គ្រួសារ* |

**សរុបចំនួនគ្រួសារដែលប្រកបរបរធ្វើចំការជាចំបង** : គឺសំដៅលើប្រភេទគ្រួសារដែលពឹងផ្អែកលើសកម្មភាពធ្វើចំការជាចំបង ដើម្បីរកចំណូលមកចិញ្ចឹមគ្រួសារដូចមានកត់ត្រានៅក្នុងសំណួរទី៣៩ស្ថិតិមុខរបរ ។ ដូចគ្នានឹងការធ្វើស្រែដែរ តើនៅក្នុងចំណោមគ្រួសារដែលប្រកបរបរធ្វើចំការជាចំបង មានប៉ុន្មានគ្រួសារដែលមានដីចំការតិចជាង១ហិកតា និងមានប៉ុន្មានគ្រួសារដែលគ្មានដីចំការផ្ទាល់ខ្លួន ដោយធ្វើចំការជួលដីគេ ឬធ្វើប្រវ៉ាស់ជាមួយម្ចាស់ដីចំការ ឬស៊ីឈ្នួលធ្វើចំការឱ្យគេ ។

ការស្រង់ស្ថិតិនេះ មានសារៈសំខាន់ចំពោះតំបន់ខ្ពង់រាប ដែលគ្រួសារភាគច្រើនប្រកបរបរធ្វើចំការ ។ ដោយឡែក ចំពោះគ្រួសារដែលមានដីធ្វើចំការ

តិចជាង១ហិកតា ក្រុមប្រឹក្សាឃុំសង្កាត់ គួរជួយណែនាំគាត់អោយប្រកបរបរផ្សេងទៀតជាបន្ថែម ដូចជាចិញ្ចឹមសត្វ សិប្បកម្ម លក់ដូរ ...។ល។ ឬចូលរួមក្នុងការងារ សហគមន៍ផ្សេងៗ ដើម្បីអាចមានចំនូលគ្រប់គ្រាន់ផ្គត់ផ្គង់គ្រួសារ ។ ចំពោះគ្រួសារជាកសិករធ្វើចំការជាចំបងហើយគ្មានដីធ្វើចំការផ្ទាល់ខ្លួនដោយជួលដីគេធ្វើ គ្រួសារប្រភេទនេះជាគ្រួសារដែលកំពុងជួបការលំបាកខ្លាំង ដែលក្រុមប្រឹក្សាឃុំ សង្កាត់ អាចជួយផ្គត់ផ្គង់និងស្វែងរកការគាំទ្រផ្តល់មុខរបរសមស្របណាមួយ សំរាប់យូរអង្វែងទៅអនាគត ។

***ក្នុងភូមិយើងខ្ញុំ ចំនួនគ្រួសារដែលនិយមប្រើប្រាស់ជីគីមីនិងថ្នាំគីមីសំលាប់សត្វល្អិតសំរាប់ការដាំដុះ ក្នុងឆ្នាំនេះមាន :***

| | | |
|---|---|---|
| 74 | *ចំនួនគ្រួសារដែលប្រើជីគីមី* | *មាន ..................... គ្រួសារ* |
| 75 | *ចំនួនគ្រួសារដែលប្រើថ្នាំគីមីសំលាប់សត្វល្អិត* | *មាន ..................... គ្រួសារ* |

# ការចិញ្ចឹមសត្វ

*ការកត់ត្រាចំនួនគ្រួសារចិញ្ចឹមសត្វនេះមិនសំដៅទាល់តែគ្រួសារនោះចិញ្ចឹមសត្វជាមុខរបរសំខាន់ឡើយ ។*

***ការចិញ្ចឹមគោ_ក្របី (បើគ្មានសូមដាក់លេខសូន្យ)***

| | | |
|---|---|---|
| 76 | *សរុបចំនួនគ្រួសារដែលចិញ្ចឹមគោ_ក្របី* | *មាន ................. គ្រួសារ* |
| 77 | *ចំនួនគ្រួសារដែលចិញ្ចឹមគោក្របីសំរាប់កំលាំងអូសទាញ* | *មាន ................. គ្រួសារ* |
| 78 | *ចំនួនគោ_ក្របីសរុបនៅក្នុងភូមិ* | *មាន ................. ក្បាល* |
| 79 | *ចំនួនកសិដ្ឋានចិញ្ចឹមគោ_ក្របី* | *មាន ................ កន្លែង* |

**ចំនួនគ្រួសារចិញ្ចឹមគោ_ក្របី :** សំដៅយកគ្រួសារទូទៅ ដែលមានគោ_ក្របីជាកម្មសិទ្ធរបស់ខ្លួន។

**ចំនួនគ្រួសារចិញ្ចឹមគោ-ក្របី សំរាប់កំលាំងអូសទាញ :** ជាការស្រង់ចំនួនគ្រួសារដែលនៅប្រើប្រាស់គោក្របីជាកំលាំងអូសទាញ ។ ចំនួននេះ ត្រូវតិចជាង ឬស្មើនឹងចំនួនគ្រួសារចិញ្ចឹមគោ-ក្របីសរុប ។

**ចំនួនគោ-ក្របីសរុបនៅក្នុងភូមិ :** ជាចំនួនគោ-ក្របីសរុបទាំងអស់ ទាំងញីទាំងឈ្មោល ទាំងតូច ទាំងធំដែលមាននៅក្នុងភូមិ ប៉ុន្តែមិនត្រូវរាប់បញ្ចូលចំនួនគោ-ក្របីដែលគេចិញ្ចឹមនៅក្នុងកសិដ្ឋានឡើយ ។

ស្ថិតិនេះ មានសារៈសំខាន់ ចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានស្នើសុំវ៉ាក់សាំងការពារ សត្វគោ-ក្របី ឬវគ្គបណ្តុះបណ្តាលអំពីការចិញ្ចឹមគោ-ក្របី ឬការរៀបចំធនាគារគោ-ក្របីជាដើម។ កន្លងមក ដោយសារគ្មានស្ថិតិនេះនៅតាមសំណើគំរោង ឃុំសង្កាត់ភាគច្រើនបានយកលេខចំនួនគ្រួសារទូទាំងឃុំមកដាក់ជាចំនួនគ្រួសារអ្នកទទួលផល ដែលធ្វើអោយតំលៃគំរោងប៉ាន់ស្មានមានចំនួនខ្ពស់អនេក ដែលពិបាកនិងគៀងគរវកការគាំទ្របាន ។

**ចំនួនកសិដ្ឋានចិញ្ចឹមគោ-ក្របី :** ជាកសិដ្ឋានដែលមានចិញ្ចឹមគោច្រើន ជាហ្វូងៗសំរាប់ធ្វើពាណិជ្ជកម្ម ដែលក្រុមប្រឹក្សាឃុំសង្កាត់អាចពិចារណាអំពីលទ្ធភាពប៉ះពាល់បរិស្ថាន ឬទំនាស់ផ្សេងៗជាមួយប្រជាជន។

## *ការចិញ្ចឹមសេះ (បើគ្មានសូមដាក់លេខសូន្យ)*

| | | |
|---|---|---|
| 80 | *ចំនួនគ្រួសារដែលចិញ្ចឹមសេះ* | *មាន ................ គ្រួសារ* |
| 81 | *ចំនួនសេះសរុបនៅក្នុងភូមិ* | *មាន .................. ក្បាល* |

**ចំនួនគ្រួសារចិញ្ចឹមសេះ :** នៅតំបន់មួយចំនួនការចិញ្ចឹមសេះ គឺជារបរសំខាន់មួយរបស់ប្រជាជន ដែលត្រូវការពិភាក្សាក្នុងក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការបង្កើតជាសហគមន៍ចិញ្ចឹមសេះ ធនាគារសេះ ឬការផ្តល់ឥណទានផ្សេងៗជាដើម ។ ស្ថិតិចំនួនសេះ អាចផ្តល់ជាគំនិតក្នុងការប៉ាន់ស្មានទំហំគំរោងដែលគ្រោងស្នើឡើង ។

## *ការចិញ្ចឹមជ្រូក (បើគ្មានសូមដាក់លេខសូន្យ)*

| | | |
|---|---|---|
| 82 | *សរុបចំនួនគ្រួសារដែលចិញ្ចឹមជ្រូក* | *មាន ...... គ្រួសារ* |
| 83 | *ចំនួនគ្រួសារដែលចិញ្ចឹមជ្រូក លើសពី៣-៤ក្បាលឡើងទៅ* | *មាន ..... គ្រួសារ* |
| 84 | *ចំនួនកសិដ្ឋានចិញ្ចឹមជ្រូក* | *មាន ..... កន្លែង* |

**សរុបចំនួនគ្រួសារចិញ្ចឹមជ្រូក :** សំដៅទៅលើគ្រួសារនៅក្នុងភូមិដែលកំពង់ចិញ្ចឹមជ្រូក ។ ការកត់ត្រានេះគិតរួមទាំងការចិញ្ចឹម១-២ក្បាលតាមគ្រួសាររហូតដល់ការចិញ្ចឹមច្រើនក្បាលដាក់ក្នុងទ្រុង សំរាប់ចំនួលគ្រួសារ។

**ចំនួនគ្រួសារចិញ្ចឹមជ្រូកលើសពី៣-៤ក្បាលឡើងទៅ :** ជាស្ថិតិគ្រួសារចិញ្ចឹមជ្រូកមានទ្រង់ទ្រាយធំបង្គួរ ដែលគិតដកស្រង់ចេញពីចំនួនគ្រួសារចិញ្ចឹមជ្រូកសរុបខាងលើ ។ ស្ថិតិគ្រួសារចិញ្ចឹមជ្រូកប្រភេទនេះ ដែលក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវការពិភាក្សា រកដំណោះស្រាយនិងជួយគាំទ្រ ដូចជា ការផ្តល់ឥណទាន ការបណ្តុះបណ្តាល ការដោះស្រាយទំនាស់ និងបញ្ហាបរិស្ថាន..ជាដើម ។

**កសិដ្ឋានចិញ្ចឹមជ្រូក ៖** ជាទីតាំងចិញ្ចឹមជ្រូកទ្រង់ទ្រាយធំ មានលក្ខណៈសិប្បកម្ម ឬឧស្សាហកម្ម ដែលមានបុគ្គលិកជំនាញពេទ្យសត្វនិងកម្មករប្រចាំការ ។ ភាគច្រើនកសិដ្ឋានទាំងនោះ ជាប្រភព ផ្តល់ពូជ ចំណី និងបច្ចេកទេសផ្សេងៗ ដល់ប្រជាជនរស់នៅក្បែរទីកន្លែងនោះ ក៏ប៉ុន្តែ ក៏អាចផ្តល់ផលអវិជ្ជមានមួយចំនួនដែរ ដូចជាជំងឺឆ្លង កាកសំណល់ ទំនាស់ផលប្រយោជន៍ ។ ហេតុនេះ ការផ្តល់ស្ថិតិចំនួនកសិដ្ឋានចិញ្ចឹមជ្រូក និងលើកយកបញ្ហាពាក់ព័ន្ធផ្សេងៗមកដោះស្រាយនៅក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ ពិតជាអាចបង្ការនិងទប់ស្កាត់បញ្ហាអវិជ្ជមានបានទាន់ពេលវេលា ។

## *ការចិញ្ចឹមពពែ_ចៀម (បើគ្មានសូមដាក់លេខសូន្យ)*

| | | |
|---|---|---|
| *85* | *ចំនួនគ្រួសារដែលចិញ្ចឹមពពែ_ចៀម* | *មាន ................. គ្រួសារ* |
| *86* | *ចំនួនកសិដ្ឋានចិញ្ចឹមពពែ_ចៀម* | *មាន .................. កន្លែង* |

**ចំនួនគ្រួសារដែលចិញ្ចឹមពពែ_ចៀម ៖** ជាការចិញ្ចឹមលក្ខណៈគ្រួសារសំរាប់ការកំសាន្ត និងលក់យកចំនូលគ្រួសារ ។ ជាទូទៅ ការចិញ្ចឹមរបៀបគ្រួសារអាចឬបានបង្កទំនាស់ជាច្រើន ដោយសារតែពពែឬចៀមទាំងនោះ អាចឬបានស៊ីផលដំណាំរបស់ប្រជាជនផ្សេងទៀត ។

**ចំនួនកសិដ្ឋានចិញ្ចឹមពពែ_ចៀម ៖** ជាការចិញ្ចឹមបែបទ្រង់ទ្រាយធំ ក្នុងកសិដ្ឋានផ្ទាល់ខ្លួន ដែលបិទជិត ដោយពុំប៉ះពាល់ផលដំណាំឬផលប្រយោជន៍របស់ប្រជាជនឡើយ ។

## *ការចិញ្ចឹមមាន់ (បើគ្មានសូមដាក់លេខសូន្យ)*

| | | |
|---|---|---|
| 87 | *សរុបចំនួនគ្រួសារដែលចិញ្ចឹមមាន់* | *មាន ....... គ្រួសារ* |
| 88 | *ក្នុងនោះចំនួនគ្រួសារដែលមានចិញ្ចឹមមាន់ មេពីពក្បាលឡើងទៅ* | *មាន ....... គ្រួសារ* |
| 89 | *ចំនួនកសិដ្ឋានចិញ្ចឹមមាន់* | *មាន ........ កន្លែង* |

**សរុបចំនួនគ្រួសារដែលចិញ្ចឹមមាន់** : គឺសំដៅទៅលើគ្រួសារណាដែលមាន់ចិញ្ចឹមមាន់ចាប់ ពី**មួយ**ក្បាលឡើងទៅ ។

**ចំនួនគ្រួសារដែលមានចិញ្ចឹមមាន់មេពីពក្បាលឡើងទៅ** : សំណួរនេះ ដើម្បីធ្វើការរំលេចឱ្យឃើញកាន់តែច្បាស់ថា តើនៅក្នុងចំនួនគ្រួសារចិញ្ចឹមមាន់ខាងលើ មានប៉ុន្មានគ្រួសារដែលមានចិញ្ចឹមមាន់មេពី**ព**ក្បាលឡើងទៅ ? ។ មាន់មេ សំដៅទៅលើមេមាន់ពូជ ដែលអ្នកភូមិមានទំលាប់ថែរក្សាទុក ទោះបីមានការលក់ដូរ ក៏អ្នកភូមិមិនលក់ដែរ ព្រោះមេមាន់ប្រភេទនេះ ច្រើនតែជាមេមាន់ឈ្នះជំងឺ ។

ស្ថិតិនេះមាន សារៈសំខាន់សំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ រៀបចំបង្កើតជាសមាគមន៍ឬសហគមន៍ចិញ្ចឹមមាន់ ឬស្នើសុំវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម ការធ្វើចំណី ការព្យាបាលជំងឺ និងបច្ចេកទេសសំខាន់ៗ រួមទាំងការបង្កើតភ្នាក់ងារពេទ្យសត្វភូមិជាដើម ។

**កសិដ្ឋានចិញ្ចឹមមាន់** : សំដៅទៅលើកសិដ្ឋានទាំងឡាយណាដែលមានទីតាំងស្ថិតនៅក្នុងភូមិ ដោយមិនគិតពីម្ចាស់កសិដ្ឋានឡើយ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវដឹងច្បាស់អំពីចំនួនកសិដ្ឋានចិញ្ចឹមមាន់ និងពិភាក្សាអំពីបញ្ហាមួយចំនួនដូចជា ជំងឺឆ្លង ផលប៉ះពាល់ដល់បរិស្ថាន ដើម្បីពិភាក្សាជាមួយ ឬរាយការណ៍ជូនមន្ទីរជំនាញ ដើម្បីជួយអន្តរាគមន៍ទាន់ពេលវេលា ។ កសិដ្ឋានចិញ្ចឹមមាន់

គឺជាការចិញ្ចឹមបែបទ្រង់ទ្រាយធំ ដែលប្រើដើមទុនច្រើនរហូតដល់ទៅរាប់ពាន់ដុល្លារ ។

## *ការចិញ្ចឹមទា (បើគ្មានសូមដាក់លេខសូន្យ)*

| | | |
|---|---|---|
| 90 | *សរុបចំនួនគ្រួសារចិញ្ចឹមទា* | *មាន ............... គ្រួសារ* |
| 91 | *ក្នុងនោះចំនួនគ្រួសារដែលចិញ្ចឹមមេទាពី៥ក្បាលឡើងទៅ* | *មាន ............... គ្រួសារ* |
| 92 | *ចំនួនកសិដ្ឋានចិញ្ចឹមទា* | *មាន ................ កន្លែង* |

**សរុបចំនួនគ្រួសារដែលចិញ្ចឹមទា :** សំដៅទៅលើគ្រួសារណាដែលមានចិញ្ចឹមទាចាប់ពីមួយឬពីរក្បាលឡើងទៅគឺតទាំងទាចិញ្ចឹមយកពង និងទាកាប៉ា។

**ចំនួនគ្រួសារដែលចិញ្ចឹមមេទាពី៥ក្បាលទៅ :** សំណួរនេះ ដើម្បីធ្វើការរំលេចឱ្យឃើញកាន់តែច្បាស់ថា តើនៅក្នុងចំនួនគ្រួសារចិញ្ចឹមទាខាងលើ មានប៉ុន្មានគ្រួសារដែលមានចិញ្ចឹមមេទា ពី៥ក្បាលឡើងទៅ ? ។ មេទា គឺតរួមទាំងមេទាសំពៅ(ទាចិញ្ចឹមយកពង)និងមេទាកាប៉ា ។

**កសិដ្ឋានចិញ្ចឹមទា :** សំដៅទៅលើចំនួនកន្លែងចិញ្ចឹមទាជាហ្វូង មានលក្ខណៈទ្រង់ទ្រាយធំឬបង្គូរ ដោយបោះទីតាំងនៅ តាមវាលស្រែឬនៅកន្លែងណាដែលមានទឹក ។ ការកត់ត្រានេះ គឺតបញ្ចូលផង ដែរនូវកសិដ្ឋានទាំងឡាយណាដែលមានទីតាំងច្បាស់លាស់(ស្ថិតនៅមួយកន្លែង)ដែលមាននៅក្នុងភូមិ ដោយមិនគឹតពីម្ចាស់កសិដ្ឋានឡើយ ។

## *ការចិញ្ចឹមត្រី (បើគ្មានសូមដាក់លេខសូន្យ)*

| | | |
|---|---|---|
| 93 | *ចំនួនគ្រួសារចិញ្ចឹមត្រីក្នុងស្រះ ឬក្នុងស្រែ ឬស្រះជាប់ស្រែ* | *មាន ......... គ្រួសារ* |
| 94 | *ចំនួនស្រះចិញ្ចឹមត្រី* | *មាន ............ ស្រះ* |
| 95 | *ចំនួនគ្រួសារចិញ្ចឹមត្រីក្នុងប៉ែ* | *មាន ......... គ្រួសារ* |
| 96 | *ចំនួនប៉ែចិញ្ចឹមត្រី* | *មាន ............ ប៉ែ* |

**ចំនួនគ្រួសារចិញ្ចឹមត្រីក្នុងស្រះឬក្នុងស្រែ :** ជាស្ថិតិរាប់ចំនួនគ្រួសារទាំងអស់ ដែលបានចិញ្ចឹមត្រីក្នុងស្រះ ឬក្នុងស្រែ ឬស្រះជាប់ជាមួយស្រែ ឬចិញ្ចឹមត្រី តាមបែបលក្ខណៈធម្មជាតិ (ដើរចាប់កូនត្រីយកមកចិញ្ចឹម) ដើម្បីជាអាហារ ឬ លក់ដូរសំរាប់ចំណូលគ្រួសារ ។ ស្ថិតិនេះ មានសារៈសំខាន់ចំពោះ ក្រុមប្រឹក្សា ឃុំ-សង្កាត់ ក្នុងការលើកស្នើឡើងនូវគំរោងបណ្តុះបណ្តាល ការផ្តល់ឥណទាន ការបង្កើតសហគមន៍ និងការផលិតពូជត្រីសំរាប់ផ្គត់ផ្គង់ជាដើម ។ ជាទូទៅ ពត៌មានចំនួនគ្រួសារមិនគ្រប់គ្រាន់សំរាប់ការរៀបចំកសាងផែនការឡើយ ហេតុនេះចាំបាច់ត្រូវមានពត៌មានអំពីចំនួនស្រះ ដែលបានប្រើសំរាប់ចិញ្ចឹមត្រី ទៀត ។

**ចំនួនគ្រួសារចិញ្ចឹមត្រីក្នុងបែ :** ការចិញ្ចឹមត្រីក្នុងស្រះនិងក្នុងបែ មានលក្ខណៈ ខុសគ្នាយ៉ាងខ្លាំង ខាងផ្នែកបច្ចេកទេស ហើយការប្រើប្រាស់ដើមទុនក៏ខុសគ្នា ច្រើនដែរ ។ ហេតុនេះ ចាំបាច់ត្រូវញែកគ្នារវាងការចិញ្ចឹមត្រីក្នុងស្រះនិងក្នុង បែ។ ម្យ៉ាងទៀត ការចិញ្ចឹមត្រីក្នុងបែច្រើនមានទំនាស់ជាមួយប្រជាជនដែល ប្រើប្រាស់ទឹកបឹង-ស្ទឹង-ទន្លេដែលតំរូវឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើការដោះ ស្រាយតាមរបៀបណាមួយដ៏សមស្រប ។

## *ការចិញ្ចឹមបង្កា (បើគ្មានសូមបំពេញលេខសូន្យ)*

| | | | |
|---|---|---|---|
| *97* | *ចំនួនគ្រួសារចិញ្ចឹមបង្កាក្នុងស្រែ* | | *មាន ................. គ្រួសារ* |
| *98* | *ចំនួនស្រែបង្កា* | *មាន ......... ស្រែ* | *ត្រូវជា ................ ហ.ត* |

**ចំនួនគ្រួសារចិញ្ចឹមបង្កាក្នុងស្រែ :** ជាស្ថិតិដែលចាំបាច់សំរាប់តំបន់មាត់សមុទ្រ តំរូវអោយឃុំ-សង្កាត់ ពិចារណានៅក្នុងផែនការ ដើម្បីអភិរក្សធនធានធម្មជាតិ ព្រោះថាការចិញ្ចឹមបង្កាច្រើនហួស នឹងនាំអោយមានការកាប់ឆ្ការព្រៃកោងកាង

បន្ថែមឬបង្កអោយមានជំងឺ ដែលធ្វើអោយប្រជាពលរដ្ឋ មានការខាតបង់ថវិកា។ មធ្យោបាយសមស្របសំរាប់ដោះស្រាយបញ្ហា គឺត្រូវធ្វើការអប់រំ អោយមានការយល់ដឹង ដោយផ្តល់វគ្គបច្ចេកទេសចិញ្ចឹមតាមបែបធម្មជាតិ ឬធ្វើកិច្ចសន្យាផ្សេងៗជាដើម។ ប៉ុន្តែស្ថិតិចំនួនគ្រួសារចិញ្ចឹមបង្គាក្នុងស្រែប្រហែលជាពុំគ្រប់គ្រាន់សំរាប់ការពិភាក្សាឡើយ ហេតុនេះ ចាំបាច់ត្រូវស្រង់ចំនួនស្រែចិញ្ចឹមបង្គា និងផ្ទៃដីចិញ្ចឹមបង្គាបន្ថែមទៀត ដើម្បីកំណត់សមាមាត្រអោយបានសមស្រប រវាងផ្ទៃដីចិញ្ចឹមបង្គា និងផ្ទៃដីដែលត្រូវរក្សាទុកទំនេរ ។

***ការចិញ្ចឹមបង្កង (បើគ្មានសូមដាក់លេខសូន្យ)***

| | | |
|---|---|---|
| *99* | *ចំនួនគ្រួសារចិញ្ចឹមបង្កងក្នុងស្រះឬស្រែ* | *មាន ................. គ្រួសារ* |
| *100* | *ចំនួនស្រះចិញ្ចឹមបង្កង* | *មានចំនួន ............. ស្រះ* |
| *101* | *ចំនួនគ្រួសារចិញ្ចឹមបង្កងក្នុងប៉ែ* | *មាន ................. គ្រួសារ* |
| *102* | *ចំនួនប៉ែចិញ្ចឹមបង្កង* | *មានចំនួន ................ ប៉ែ* |

***ការចិញ្ចឹមក្រពើ (បើគ្មានសូមដាក់លេខសូន្យ)***

| | | |
|---|---|---|
| *103* | *ចំនួនគ្រួសារចិញ្ចឹមក្រពើ* | *មាន ................. គ្រួសារ* |

# ធនធានធម្មជាតិនិងបរិស្ថាន

| | | | |
|---|---|---|---|
| *104* | *ចំនួនគ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ* | *......... គ្រួសារ* | *មាន ...... នាក់* |
| *105* | *ចំនួនគ្រួសារដែលរស់នៅក្នុងបរិវេណតំបន់ការពារឬអភិរក្ស* | | *មាន ... គ្រួសារ* |

**ចំនួនគ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ** : សំដៅទៅលើគ្រួសារដែលរងគ្រោះដោយទឹកជំនន់ ខ្យល់ព្យុះ ភាពរាំង ស្ងួត .. ។ **រងគ្រោះដោយទឹកជំនន់** មានដូចជាបាក់ច្រាំងទន្លេអស់ផ្ទះ អស់ដីភូមិ ដោយខ្សែកចំពោះតំបន់ ឬកន្លែងណាដែលមានប្រពៃណី លិចទឹកជាប្រចាំនៅរដូវទឹកឡើង ហើយគ្រួសារ

ទាំងនោះតែងតែផ្លាស់ទីលំនៅមករកទូលសុវត្ថិភាព មិនត្រូវកត់ត្រាជាគ្រួសារដែលរងគ្រោះដោយធម្មជាតិឡើយ ។ **គ្រួសារដែលរងគ្រោះដោយខ្យល់ព្យុះ** មានដូចជា បាក់ឬរលំផ្ទះ រន្ទះបាញ់ ... ។ល។ **គ្រួសារដែលរងគ្រោះដោយភាពរាំងស្ងួត** ការកត់ត្រាគ្រួសារប្រភេទនេះ មេភូមិត្រូវធ្វើការពិចារណានៅពេលស្រង់ស្ថិតិថា តើនៅក្នុងឆ្នាំនេះមានប៉ុន្មានគ្រួសារ ដែលទទួលផលប៉ះពាល់ពីការរាំងស្ងួត ដូចជាគ្មានទឹកធ្វើស្រែ ស្រូវស្លក សត្វល្អិតបំផ្លាញជាដើម ។ ដោយសារចំនួនគ្រួសារមិនបានបង្ហាញចំនួនជាក់លាក់ សំរាប់គ្រោងថវិកាជួយសង្គ្រោះ ហេតុនេះត្រូវតែមានតួលេខស្ថិតិចំនួនមនុស្សជាក់លាក់បន្ថែមទៀត ។

ស្ថិតិនេះស្រង់ឡើងដើម្បីលើកយកទៅពិភាក្សាក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីត្រៀមរកដំណោះស្រាយនៅឆ្នាំក្រោយៗទៀត ដូចជាស្វែងរកជំនួយសង្គ្រោះបន្ទាន់ ការលើកទឹកចិត្ត និងកិច្ចការពារពិសេសពីអាជ្ញាធរមូលដ្ឋាន ក្នុងគោលបំណងរក្សាកុំអោយគ្រួសារទាំងនេះធ្លាក់ក្នុងឧបាយកលបោកប្រាស់ រំលោភបំពាន និងអំពើជួញដូរផ្សេងៗ ។

**ចំនួនគ្រួសារដែលរស់នៅក្នុងបរិវេណតំបន់ការពារឬអភិរក្ស** ៖ ស្ថិតិនេះមានសារៈសំខាន់បំផុត ក្នុងការពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីស្វែងរកដំណោះស្រាយសមស្រប សំរាប់អោយប្រជាជនទាំងនោះ ចូលរួមថែរក្សាការពារព្រៃឈើ សត្វព្រៃ និងអាចប្រើប្រាស់អនុផលព្រៃឈើ ដោយស្រប ច្បាប់ប្រកបដោយនិរន្តរភាព ។ ប្រការសំខាន់ គឺការអប់រំអោយគ្រួសារទាំងនោះយល់អំពីសារៈសំខាន់នៃការអភិរក្សតំបន់នោះ ។

| | | |
|---|---|---|
| 106 | ចំនួនគ្រួសារមានសេវាសំរាមប្រមូលតាមផ្ទះ | មាន ............... គ្រួសារ |
| 107 | ចំនួនគ្រួសារដែលទទួលការពិបាកពីការបំពុលបរិស្ថាន | មាន ............... គ្រួសារ |

ចំនួនគ្រួសារដែលទទួលការពិបាកពីការបំពុលបរិស្ថាន គឺសំដៅទៅលើគ្រួសារមួយចំនួនដែលរស់នៅជាប់ ឬក្បែរកន្លែងឧស្សាហកម្ម សិប្បកម្ម ឬទីកន្លែងចាក់សំរាម..។ល។

# ស្ថិតិលំនៅស្ថាន

*នៅក្នុងឆ្នាំនេះភូមិយើងខ្ញុំមានលំនៅស្ថានជាច្រើនប្រភេទ ដូចខាងក្រោម :*

| | ប្រភេទផ្ទះ | ចំនួនផ្ទះសរុបមាន | ចំនួនផ្ទះមានបណ្ដាញអគ្គីសនី | ចំនួនផ្ទះមានអាគុយសំរាប់បំភ្លឺ | ចំនួនផ្ទះមានទូរទស្សន៍ |
|---|---|---|---|---|---|
| 108 | ផ្ទះប្រក់ ស្លឹក ស្បូវ | ........ ផ្ទះ | ........... ផ្ទះ | ........... ផ្ទះ | ........ ផ្ទះ |
| 109 | ផ្ទះប្រក់សង្កសី ហ្វីប្រូស៊ីម៉ងត៍ | ........ ផ្ទះ | ........... ផ្ទះ | ........... ផ្ទះ | ........ ផ្ទះ |
| 110 | ផ្ទះប្រក់ក្បឿង | ........ ផ្ទះ | ........... ផ្ទះ | ........... ផ្ទះ | ........ ផ្ទះ |
| 111 | ផ្ទះល្វែង (ច្រើនគ្រួសាររស់នៅ) | ........ ផ្ទះ | ........... ផ្ទះ | ........... ផ្ទះ | ........ ផ្ទះ |
| 112 | ផ្ទះថ្ម ផ្ទះល្វែង (មួយគ្រួសាររស់នៅ) | ........ ផ្ទះ | ........... ផ្ទះ | ........... ផ្ទះ | ........ ផ្ទះ |
| 113 | ផ្ទះភូមិគ្រឹះ | ........ ផ្ទះ | ........... ផ្ទះ | ........... ផ្ទះ | ........ ផ្ទះ |
| 114 | **សរុបរួម** | **........ ផ្ទះ** | **........... ផ្ទះ** | **........... ផ្ទះ** | **........ ផ្ទះ** |

ចំនួនខ្នងផ្ទះ គឺរាប់តែខ្នងផ្ទះណាដែលមេភូមិទទួលស្គាល់ថា គ្រួសារដែលរស់នៅក្នុងផ្ទះនោះ ជាសមាជិកភូមិរស់នៅក្នុងភូមិខ្លួន ។ ចំពោះផ្ទះដែលគេធ្វើសំរាប់ចាំដី មិនត្រូវរាប់បញ្ចូលឡើយ ។ ដោយឡែកចំពោះគ្រួសារណាដែល

មានផ្ទះពីរឬ៣ត្រូវរាប់តែផ្ទះមួយប៉ុណ្ណោះ គឺរាប់យកតែផ្ទះណា ដែលធំជាងគេ។
ឧ.គ្រួសារមួយមានផ្ទះក្បឿង ហើយគាត់បានសង់ផ្ទះតៀមប្រក់សង្កសីនៅពីមុខផ្ទះជាប់នឹងផ្លូវដើម្បីលក់ដូរអីវ៉ាន់ ហើយជារឿយៗ ពួកគាត់តែងតែស្នាក់នៅផ្ទះតៀម ។ ការរាប់ខ្នងផ្ទះសំរាប់គ្រួសារនេះគឺរាប់យកផ្ទះក្បឿង ចំពោះផ្ទះតៀមប្រក់សង្កសីមិនត្រូវរាប់បញ្ចូលឡើយ។ ដូចគ្នានេះដែរ ចំពោះគ្រួសារណាដែលមានផ្ទះពីរ ផ្ទះមួយនៅក្នុងភូមិ និងផ្ទះមួយទៀតនៅចំការ ដែលមានរូបរាងប្រហាក់ប្រហែលគ្នា រាប់យកតែមួយគឺយកផ្ទះនៅក្នុងភូមិជាគោល។ ក្នុងករណីគ្រួសារដែលមានផ្ទះពីរ គឺផ្ទះមួយកំពុងសាងសង់ ហើយផ្ទះមួយទៀតកំពុងស្នាក់នៅ គឺត្រូវយកផ្ទះដែលកំពុងស្នាក់នៅធ្វើជាគោល ។ ការកំណត់នេះគឺដើម្បីអោយមានការឯកភាពគ្នាទូទាំងប្រទេស និងមានចំនួនខ្នងផ្ទះសមស្របតាមចំនួនគ្រួសារ ។

**១.ផ្ទះប្រក់ស្លឹក ស្បូវ បន្ទះកៅស៊ូ :** សំដៅទៅលើប្រភេទផ្ទះដែលសង់ផ្ទាល់ដីឬខ្ពស់ពីដីដែលមានដំបូលប្រក់ស្លឹក/ស្បូវ ដោយមិនគិតពីជញ្ជាំងឡើយ ។ ការគិតបែបនេះ គឺដើម្បីផ្តល់ភាពងាយស្រួលដល់មេភូមិ ក្នុងការស្រង់ស្ថិតិ ព្រោះថាតាមទំលាប់ខ្មែរយើងច្រើនគិតពីដំបូលមុន ហើយការប្រក់ស្លឹក ឬប្រក់ស្បូវ ជាការប្រក់បណ្តោះអាសន្នប៉ុណ្ណោះ នៅពេលជីវភាពគ្រួសារបានធូរធារ ប្រជាជនទាំងនោះនិងផ្លាស់ប្តូរទៅប្រក់សង្កសី ហ្វីប្រូស៊ីម៉ងត៍ ឬក្បឿងជំនួសវិញ។ មានន័យថា ចំនួនផ្ទះប្រក់ស្លឹកឬស្បូវ ជាទិន្នន័យសំរាប់បញ្ជាក់ពីស្ថានភាពជីវភាពប្រជាជន ដែលមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ទៅតាមល្បឿននៃការអភិវឌ្ឍន៍មូលដ្ឋាន ។ គួរជៀសវាងការស្រង់ស្ថិតិ ផ្ទះដំបូលស្បូវ ដែលជាការប្រក់ដើម្បីលំអរប៉ុណ្ណោះ ដូចដំបូលផ្ទះភូមិគ្រឹះឬផ្ទះកំសាន្តមួយចំនួន ។

**២.ផ្ទះមានដំបូលប្រក់សង្កសី/ហ្វីប្រូស៊ីម៉ង់** : សំដៅលើប្រភេទផ្ទះសង់ផ្ទាល់ដី ឬខ្ពស់ពីដី និងមានដំបូលប្រក់សង្កសី/ហ្វីប្រូស៊ីម៉ង់ ដោយមិនគិតពីប្រភេទជញ្ជាំងឡើយ ។ ផ្ទះប្រភេទនេះផ្តល់សុវត្ថិភាព ប្រសើរជាងផ្ទះប្រក់ស្លឹក/ស្បូវ ។

**៣.ផ្ទះមានដំបូលប្រក់ក្បឿង** : គឺជាប្រភេទផ្ទះដែលមានសរសរឈើ ឬសរសរស៊ីម៉ង់ត៍ សង់ខ្ពស់ពីដី មានជំហរខ្ពស់ផុតក្បាល(ផ្ទះកាតាំង..)ឬនៅផ្ទាល់នឹងដី ហើយមានដំបូលប្រក់ក្បឿងដែលផ្តល់សុវត្ថិភាពល្អប្រសើរ ដែលជាទូទៅអ្នកភូមិហៅកាត់ខ្លីថាផ្ទះក្បឿង ។

**៤.ផ្ទះល្វែង(ច្រើនគ្រួសាររស់នៅ)** : សំដៅទៅលើផ្ទះថ្មល្វែងច្រើនជាន់ ដែលមានច្រើនគ្រួសាររស់នៅ ហើយគ្រួសារទាំងនោះជាម្ចាស់កម្មសិទ្ធដោយឡែកទៅតាមជាន់ ឬល្វែងនិមួយៗដែលរស់នៅចាប់ពីជាន់ខាងក្រោមរហូតដល់ជាន់ខាងលើ ។ ការរាប់ចំនួនផ្ទះល្វែងអាស្រ័យទៅតាមម្ចាស់កម្មសិទ្ធិនៃគ្រួសារដោយឡែក ចំពោះផ្ទះល្វែងជាន់ណាមួយដែលមាន២ឬ៣គ្រួសាររស់នៅជាមួយគ្នា ត្រូវកត់ត្រាតែជាផ្ទះមួយប៉ុណ្ណោះ ។ ចំពោះផ្ទះនៅជាន់លើបំផុតដែលមានគ្រួសាររស់នៅ ហើយជំរកនោះមានដំបូលប្រក់ស្លឹកឬស្បូវ ឬបន្ទះកៅស៊ូ ត្រូវកត់ត្រានៅក្នុងស្ថិតិផ្ទះប្រភេទទី១ បើប្រក់សង្កសីឬហ្វីប្រូស៊ីម៉ង់ ត្រូវកត់ត្រាចូលទៅក្នុងផ្ទះប្រភេទទី២វិញ ។ ដោយឡែកចំពោះផ្ទះល្វែងច្រើនជាន់ ហើយជាកម្មសិទ្ធតែមួយគ្រួសារ ត្រូវកត់ត្រានៅក្នុងស្ថិតិផ្ទះប្រភេទទី៥ (សំណួរទី១១២) ខាងក្រោមនេះ ។

**៥.ផ្ទះថ្ម ល្វែង(មួយគ្រួសាររស់នៅ)** : សំដៅទៅលើផ្ទះដែលសង់ពីថ្ម ដំបូលបេតុង ឬប្រក់ហ្វីប្រូស៊ីម៉ងត៍ ឬក្បឿងបន្ថែម ដើម្បីកុំអោយជ្រាបទឹក ដែលអ្នកភូមិហៅយ៉ាងសាមញ្ញថាផ្ទះថ្មៗ ។ ចំពោះផ្ទះល្វែងច្រើនជាន់ មានម្ចាស់កម្មសិទ្ធិរស់នៅតែមួយក្រុមគ្រួសារ ពីក្រោមរហូតដល់ជាន់លើបំផុត ត្រូវរាប់បញ្ចូលក្នុង

ស្ថិតិជាផ្ទះតែមួយបានហើយ មិនត្រូវរាប់១ជាន់ជាផ្ទះមួយនោះទេ ព្រោះនាំអោយចំនួនផ្ទះកើនលើសចំនួនគ្រួសារពិតប្រាកដ ។

**៦.ភូមិគ្រឹះ :** គឺជាផ្ទះដែលសង់ក្នុងដីឡូតិ៍ មានទីធ្លាធំទូលាយ ដោយមានសួនច្បារ អាងហែលទឹក ដែលមានម៉ូត្រប្លែកៗពីគ្នា ។

**ចំនួនផ្ទះមានបណ្តាញអគ្គីសនី :** ជាការកត់ត្រាចំនួនផ្ទះ តាមប្រភេទនិមួយៗ ដែលមានតភ្ជាប់ចរន្តអគ្គីសនី២២០វុល ពីបណ្តាញរដ្ឋឬឯកជននានា ឬម៉ាស៊ីនភ្លើងក្នុងភូមិ ។

**ចំនួនផ្ទះមានអាគុយសំរាប់បំភ្លឺ :** ជាស្ថិតិកត់ត្រាចំនួនផ្ទះ តាមប្រភេទ និមួយៗ ដែលបានប្រើប្រាស់អំពូលចាប់អាគុយ១២វុល(៣០អំពែរ) សំរាប់បំភ្លឺក្នុងគ្រួសាររបស់ខ្លួន ដោយកត់ត្រាបញ្ចូលផងដែរនូវគ្រួសារណាដែលប្រើចង្កៀងប្រេងកាត ឬខ្លាញ់ម្តងកាល ឬជាបណ្តោះអាសន្នដោយសារអាគុយខូច មិនទាន់បាន ទៅទិញ ។

**ចំនួនផ្ទះមានទូរទស្សន៍ :** ជាចំនួនផ្ទះដែលកំពង់មានទូរទស្សន៍ប្រើប្រាស់ ។ ក្នុងតារាងនេះអាចបញ្ជាក់ប្រាប់យើងថា ប្រសិនបើផ្ទះណាប្រើអាគុយ នោះទូរទស្សន៍ជាប្រភេទស_ខ្មៅ ចំណែកឯផ្ទះដែលមានបណ្តាញអគ្គសនីវិញ នោះទូរទស្សន៍មុខជាប្រភេទទូរទស្សន៍ពណ៌ ។

| | | |
|---|---|---|
| *115* | *ចំនួនកន្លែងសាកបញ្ចូលភ្លើងអាគុយនៅក្នុងភូមិ* | *មាន ............... កន្លែង* |

**ចំនួនកន្លែងសាកបញ្ចូលភ្លើងអាគុយនៅក្នុងភូមិ :** ជាទីកន្លែងដែលប្រជាជនយកអាគុយទៅសាកបញ្ចូលភ្លើងបន្ថែម នៅពេលអស់ភ្លើង ។ ស្ថិតិនេះបញ្ជាក់កាន់តែច្បាស់តាមរយៈស្ថិតិប្រើអាគុយតាមផ្ទះនិមួយៗ បើអ្នកភូមិប្រើ

អាគុយសំរាប់បំភ្លឺច្រើននោះចំនួនកន្លែងបញ្ចូលអាគុយនៅក្នុងភូមិ ក៏អាចមានច្រើនដែរ។

ស្ថិតិដែលបានស្រង់ខាងលើ គឺអាចយកទៅពិភាក្សាក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ អំពីការវិវត្តន៍រីកចំរើននៅមូលដ្ឋាន ដែលប្រែប្រួលផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ ។ ឧ. ពីមុនផ្ទះនិមួយៗពុំសូវមានទូរទស្សន៍ឡើយ ប៉ុន្តែឆ្នាំនេះចំនួនទូរទស្សន៍កើនឡើង១៥គ្រឿង ។ ចំនួនផ្ទះស្បូវ បានផ្លាស់ប្តូរទៅជា ផ្ទះក្បឿងចំនួន១០ខ្នង ។ល។

# ស្ថានភាពផ្នែកដឹកជញ្ជូន

*តាមការរាប់ជាក់ស្តែងនៅក្នុងឆ្នាំនេះ ភូមិយើងខ្ញុំមានមធ្យោបាយដឹកជញ្ជូនដូចខាងក្រោម :*

| | | |
|---|---|---|
| *116* | *ចំនួនត្រាក់ទ័រ សំរាប់ភ្ជួរស្រែ* | *មាន ............ គ្រឿង* |
| *117* | *ចំនួនគោយន្តសំរាប់ភ្ជួរស្រែ* | *មាន ............ គ្រឿង* |

**ចំនួនត្រាក់ទ័រសំរាប់ភ្ជួរស្រែ :** ជាចំនួនត្រាក់ទ័រសរុបដែលជាកម្មសិទ្ធិរបស់អ្នកភូមិ ដោយមិនរាប់បញ្ចូលត្រាក់ទ័រ ដែលមករកស៊ីក្នុងភូមិតែមួយរយៈពេលខ្លីឡើយ ប៉ុន្តែបើមានត្រាក់ទ័រអ្នកភូមិចេញទៅរកស៊ីនៅភូមិផ្សេងឬកន្លែងដ៏ទៃត្រូវរាប់បញ្ចូលដែរ ។ ការធ្វើបែបនេះ គឺដើម្បីចៀសវាងការកត់ត្រាស្ថិតិត្រួតគ្នាពីរដង ។ ចំពោះត្រាក់ទ័រចាស់ខូចមិនអាចដំណើរការបាន មិនត្រូវកត់ចូលក្នុងស្ថិតិឡើយ ។

**ចំនួនគោយន្តសំរាប់ភ្ជួរស្រែ :** ក៏ដូចចំនួនត្រាក់ទ័រដែរ ចំនួនគោយន្តត្រូវកត់ត្រាពីគោយន្តរបស់ អ្នកភូមិផ្ទាល់ ដើម្បីកុំអោយមានការស្រង់ស្ថិតិត្រួតគ្នាពីរដង ។

ទោះបីជាគោយន្តនោះត្រូវយកទៅបូមទឹក ភ្ជួរស្រែ ឬដឹកជញ្ជូនក៏ដោយ ក៏នៅតែរាប់មួយគ្រឿងដែរ មិនត្រូវរាប់ត្រួតគ្នានោះឡើយ ។

| | | |
|---|---|---|
| 118 | ចំនួនរថយន្តដែលកែច្នៃក្នុងស្រុក | មាន .......... គ្រឿង |
| 119 | ចំនួនរថយន្តដឹកទំនិញធុនតូច (១,៥ តោនចុះ) | មាន .......... គ្រឿង |
| 120 | ចំនួនរថយន្តដឹកទំនិញធុនធំ (ចំណុះលើសពី១,៥តោន) | មាន .......... គ្រឿង |
| 121 | ចំនួនរថយន្តដឹកអ្នកដំណើរធុនតូច(១២កៅអីចុះ) | មាន .......... គ្រឿង |
| 122 | ចំនួនរថយន្តដឹកអ្នកដំណើរធុនធំ (លើសពី១២កៅអី) | មាន .......... គ្រឿង |
| 123 | ចំនួនរថយន្តសំរាប់ប្រើប្រាស់ក្នុងគ្រួសារ | មាន .......... គ្រឿង |
| 124 | **សរុបចំនួនរថយន្តដែលមាននៅក្នុងភូមិ** | **មាន ......... គ្រឿង** |

**រថយន្តដែលកែច្នៃក្នុងស្រុក :** សំដៅទៅលើរថយន្ត ដែលជាងក្នុងស្រុកកែច្នៃតំឡើងតាមតំរូវការរបស់ប្រជាជនសំរាប់ដឹកជញ្ជូនទំនិញផលិតផលផ្សេងៗ ដែលពុំមានម៉ាកសំគាល់ ដូចរថយន្តនាំចូលពីបរទេសឡើយ ដោយមិនគិតពីទំហំ ឬចំណុះឡើយ ។

**រថយន្តដឹកជញ្ជូនទំនិញចំណុះលើសពី ១,៥ តោន :** ជាប្រភេទរថយន្តដឹកជញ្ជូនធុនធ្ងន់ អាចប៉ះពាល់ជាខ្លាំងដល់ផ្លូវថ្នល់ជនបទ ដែលត្រូវលើកយកទៅពិភាក្សាក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយពុំត្រូវរាប់បញ្ចូលរថយន្តកែច្នៃ ។

**រថយន្តដឹកអ្នកដំណើរធុនតូច(១២កៅអីចុះ) :** ជារថយន្តធុនតូច មធ្យម ឬច្នៃបន្ថែមចំនួនកៅអី ដែលប្រជាជនក្នុងភូមិបានប្រើប្រាស់សំរាប់ជារថយន្តដឹកជញ្ជូនយកប្រាក់ឈ្នួលធ្វើដំណើរទៅទីជិត ឬឆ្ងាយ...។ល។ សូមកត់ត្រាតែរថយន្តជាកម្មសិទ្ធរបស់អ្នកភូមិផ្ទាល់ប៉ុណ្ណោះ ចំពោះរថយន្តដែលមកពីភូមិផ្សេង

គ្រាន់តែឈប់សំចតដឹកអ្នកដំណើរ មិនត្រូវកត់ត្រាឡើយ ដើម្បីជៀងវាងការកាត់ត្រាត្រួតគ្នា ។

**រថយន្តប្រើប្រាស់ក្នុងគ្រួសារ :** ជាចំនួនរថយន្តដែលប្រើប្រាស់សំរាប់ធ្វើដំណើរប្រចាំគ្រួសារ ពុំមែនសំរាប់ធ្វើអាជីវកម្មជារថយន្តឈ្នួលដឹកអ្នកដំណើរឡើយ ដោយមិនគិតពីទំហំឬប្រភេទរថយន្តឡើយ ។ សូមកុំស្រង់ស្ថិតិរថយន្តដែលប្រើជាប្រភេទតាក់ស៊ីដឹកជញ្ជូនអ្នកដំណើរ ដែលបានស្រង់រួចខាងលើ មកដាក់បញ្ចូលបន្ថែម ព្រោះនាំអោយតួលេខស្ថិតិសរុបច្រើនហួសចំនួនជាក់ស្តែង ។

**សរុបចំនួនរថយន្តដែលមាននៅក្នុងភូមិ =** ចំនួនរថយន្តដែលកែច្នៃក្នុងស្រុក **+** ចំនួនរថយន្តដឹកទំនិញធុនតូច(១,៥តោនចុះ) **+** ចំនួនរថយន្តដឹកទំនិញធុនធំ(ចំណុះលើសពី១,៥តោន) **+** ចំនួនរថយន្តដឹកអ្នកដំណើរធុនតូច(១២កៅអីចុះ) **+** ចំនួនរថយន្តដឹកអ្នកដំណើរធុនធំ(លើសពី១២កៅអី) **+** ចំនួនរថយន្តសំរាប់ប្រើប្រាស់ក្នុងគ្រួសារ ។

| | | |
|---|---|---|
| *125* | *ចំនួនគ្រឿងយន្ត គ្រឿងចក្រ ផ្សេងៗ* | *មាន .......... គ្រឿង* |
| *126* | *ចំនួនម៉ាស៊ីនបោកស្រូវ* | *មាន .......... គ្រឿង* |

**ចំនួនគ្រឿងយន្ត គ្រឿងចក្រផ្សេងៗ :** សំដៅទៅលើប្រភេទគ្រឿងយន្តផ្សេងៗដែលមាននៅក្នុងភូមិ ដូចជា ត្រាក់ទ័រឈូសដី ឬកាយដី(អេស្កាវ៉ាទ័រ) អាឡូកិនដី .... ។ល។

| | | | |
|---|---|---|---|
| 127 | ចំនួនរទេះគោ និង រទេះសេះ | | មាន ........ គ្រឿង |
| 128 | ចំនួនម៉ូតូ | | មាន ........ គ្រឿង |
| 129 | ក្នុងនោះ | ម៉ូតូអូសរ៉ឺម៉ក | មាន ........ គ្រឿង |
| 130 | ចំនួនម៉ូតូកង់បី (ត្រីចក្រយានយន្ត ឡាំប្រេតា) | | មាន ........ គ្រឿង |
| 131 | ចំនួនកង់និងកង់រ៉ឺម៉ក (កង់ដែលអាចប្រើប្រាស់បាន) | | មាន ........ គ្រឿង |

**ចំនួនរទេះគោ និង រទេះសេះ :** ជាចំនួនរទេះគោឬរទេះសេះ ដែលកំពុងប្រើប្រាស់រាល់ថ្ងៃដោយអ្នកភូមិ ។ មិនត្រូវកត់ត្រាចំនួនរទេះគោ_រទេះសេះ ដែលអ្នកភូមិឈប់ប្រើប្រាស់ ហើយទុកចោលនៅផ្ទះនោះឡើយ ។

**ម៉ូតូអូសរ៉ឺម៉ក :** សំដៅទៅលើម៉ូតូណាដែលមានរ៉ឺម៉កអូស ។ គោលដៅសំខាន់ គេយកទៅអូសរ៉ឺម៉ក ដើម្បីធ្វើការដឹកជញ្ជូនអ្នកធ្វើដំណើរ ឬដឹកជញ្ជូនរបស់របរ ហើយម៉ូតូប្រភេទនេះ គេអាចជិះបាន ធម្មតានៅពេលណាគេដោះរ៉ឺម៉កចេញ ។ ដើម្បីស្ថិតិនេះកាន់តែច្បាស់ ត្រូវកត់ត្រាចំនួនម៉ូតូប៉ុន្មាន ដែលអ្នកភូមិប្រើសំរាប់អូសរ៉ឺម៉ក ។

**ម៉ូតូកង់បី (ត្រីចក្រយានយន្ត) :** ជាប្រភេទម៉ូតូភ្ជាប់ជាមួយរ៉ឺម៉ក ដែលមិនអាចដោះផ្តាច់ចេញពីគ្នាបាន សំរាប់ដឹកអ្នកដំណើរ ឬភ្ញៀវទេសចរណ៍ចំងាយជិតៗ ។ បច្ចុប្បន្ន ម៉ូតូកង់បីនេះ មានចរាចរជាច្រើននៅទីក្រុងភ្នំពេញ តំបន់ជាយក្រុងភ្នំពេញ និងតាមបណ្តាខេត្តក្រុងមួយចំនួន ។

**ចំនួនកង់និងកង់រ៉ឺម៉ក :** ជាមធ្យោបាយធ្វើដំណើរដោយប្រើកំលាំងមនុស្ស ហើយពុំអាចធ្វើដំណើរឆ្ងាយៗបានឡើយ ។ ចំពោះកង់ខូចដែលទុកចោលឈប់ប្រើប្រាស់មិនត្រូវកត់ត្រាឡើយ ។

| | | |
|---|---|---|
| 132 | ទូកចែវ_ទូកអុំ សំរាប់នេសាទ | មាន ........... គ្រឿង |
| 133 | ទូកចែវ_ទូកអុំ សំរាប់ធ្វើដំណើរ/ទេសចរណ៍ | មាន ........... គ្រឿង |
| 134 | **សរុបចំនួនទូកចែវនិងអុំ ដែលមាននៅក្នុងភូមិ** | **មាន ........... គ្រឿង** |

**សរុបចំនួនទូកចែវនិងអុំដែលមាននៅក្នុងភូមិ : =** ទូកចែវ_ទូកអុំសំរាប់នេសាទ **+** ទូកចែវ_ទូកអុំសំរាប់ធ្វើដំណើរ/ទេសចរណ៍ ។

| | | |
|---|---|---|
| 135 | ទូកម៉ាស៊ីន_កាណូត សំរាប់នេសាទ | មាន ........... គ្រឿង |
| 136 | ទូកម៉ាស៊ីន_កាណូត សំរាប់ទេសចរណ៍/ដឹកអ្នកដំណើរ | មាន ........... គ្រឿង |
| 137 | ទូកម៉ាស៊ីន_កាណូត ដឹកទំនិញចំណុះ១តោន | មាន ........... គ្រឿង |
| 138 | ទូកម៉ាស៊ីន_កាណូត ដឹកទំនិញចំណុះលើសពី១តោន | មាន ........... គ្រឿង |
| 139 | **សរុបចំនួនទូកម៉ាស៊ីននិងកាណូតដែលមាននៅក្នុងភូមិ** | **មាន ............. គ្រឿង** |

**ចំនួនទូកចែវនិងអុំ :** ជាមធ្យោបាយធ្វើដំណើរផ្លូវទឹក ដោយប្រើកំលាំងមនុស្ស សំរាប់តំបន់ជិតៗមានចំណុះតិច ។ ប្រសិនបើទូកទាំងនេះ មានជើងបំពាក់ម៉ាស៊ីន ហើយត្រូវម្ចាស់កម្មសិទ្ធដោះចេញជាបណ្តោះអាសន្ន នោះមិនត្រូវចាត់ទុកថាជាទូកចែវ_អុំដោយកំឡាំងមនុស្សឡើយ ប៉ុន្តែត្រូវចាត់ជាប្រភេទទូកម៉ាស៊ីន( ប្រៀបដូចកង់និងម៉ូតូ) ។ ការកត់ត្រាគឺបែងចែកទៅតាមប្រភេទទូកសំរាប់នេសាទ និងទូកសំរាប់ដឹកភ្ញៀវទេសចរណ៍ ឬអ្នកដំណើរ ។

**ចំនួនទូកម៉ាស៊ីន_កាណូតផ្សេងៗ :** ជាមធ្យោបាយធ្វើដំណើរផ្លូវទឹក ដោយប្រើកំឡាំងម៉ាស៊ីន ដែលអាចដឹកជញ្ជូនឬធ្វើដំណើរឆ្ងាយៗ ឬសំរាប់ធ្វើការនេសាទ។

**ទូកម៉ាស៊ីន_កាណូតសំរាប់នេសាទ និងសំរាប់ដឹកអ្នកដំណើរ/ទេសចរណ៍** ការកត់ត្រាមិនគិតទៅលើចំណុះទូកឡើយ( ទំហំ) តែត្រូវកត់ត្រាបែងចែកទៅតាមប្រភេទទូកសំរាប់ការធ្វើនេសាទនិងទូកសំរាប់ដឹកអ្នកដំណើរ/ភ្ញៀវ ទេសចរណ៍។

ក្នុងករណីទូកណាមួយធ្វើការនេសាទផងនិងដឹកអ្នកដំណើរផង ការកត់ត្រាត្រូវគិតទៅលើការប្រើប្រាស់ណាមួយសំខាន់ជាង តើការនេសាទសំខាន់ជាង ឬការដឹកអ្នកដំណើរសំខាន់ជាង ? ។ ដោយឡែកចំពោះ **ទូកម៉ាស៊ីន-កាណូតសំរាប់ដឹកទំនិញ** ការកត់ត្រាត្រូវគិតទៅតាមចំណុះ គឺប្រភេទទូកម៉ាស៊ីន-កាណូតមានចំណុះ១តោន និងប្រភេទទូកមានចំណុះលើសពី១តោន ។

**សរុបចំនួនទូកម៉ាស៊ីននិងកាណូតដែលមាននៅក្នុងភូមិ =** ចំនួនទូកម៉ាស៊ីនកាណូតសំរាប់នេសាទ **+** ចំនួនទូកម៉ាស៊ីនកាណូតសំរាប់ទេសចរណ៍ ឬដឹកអ្នកដំណើរ **+** ចំនួនទូកម៉ាស៊ីនកាណូតដឹកទំនិញចំណុះ១តោន **+** ចំនួនទូកម៉ាស៊ីនកាណូតដឹកទំនិញចំណុះលើសពី១តោន ។

ស្ថិតិនេះមានផលប្រយោជន៍ចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការវាយតំលៃពីភាពរីកចំរើននៃជីវភាពប្រជាជនក្នុងភូមិ-ឃុំ និងការកើនឡើងនៃមធ្យោបាយភ្ជួររាស់ ដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក ពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីគិតប្រមាណទៅថ្ងៃអនាគតក្នុងការរៀបចំចំណតរថយន្ត ឬកំពង់ផែ ក៏ដូចជាការគិតគូរពីទំហំផ្លូវថ្នល់ផងដែរ ។

***ចំងាយជាមធ្យម(គិតជាគីឡូម៉ែត្រ) ពីចំនុចកណ្តាលភូមិទៅកាន់ទីផ្សារដែលនៅជិតបំផុត :***

| | | |
|---|---|---|
| *140* | *.... គ.ម* | *ផ្សារនោះមានទីតាំងនៅក្នុងភូមិ ....... ឃុំ ..... ស្រុក ..... ខេត្ត .........*<br>*លេខកូតភូមិ ........................ ផ្សារនោះឈ្មោះ ........................*<br>*(សូមមន្ទីរផែនការជួយបំពេញលេខកូតភូមិដែលមានផ្សារនោះអោយផង )* |

*សំគាល់ : បើផ្សារនៅក្នុងភូមិ ចំងាយគឺសូន្យគីឡូម៉ែត្រ។*

*ផ្សារដែលកត់ត្រានេះ មិនមែនជាផ្សារក្រមួន ឬផ្ទះលក់ទំនិញមួយពីរទេ គឺជាផ្សារដែលមានលក់ទំនិញពេញមួយថ្ងៃ ជាផ្សារដែលអាចទិញទំនិញបាន*

*គ្រប់មុខ ដូចជាបន្លែ ផ្លែឈើ ត្រីសាច់ គ្រឿង ឧបភោគបរិភោគ សំលៀកបំពាក់ ឧបករណ៍អគ្គីសនី ឧបករណ៍កសិកម្ម ...។ល។*

***ចំងាយនិងរយៈពេលជាមធ្យមពីចំនុចកណ្តាលភូមិទៅផ្លូវថ្នល់ដែលអាចបើកឡានទៅមកពេញ១ឆ្នាំ :***

| | | |
|---|---|---|
| 141 | *ផ្លូវថ្នល់នោះស្ថិតនៅចំងាយ...... គ.ម ពីចំនុច កណ្តាលភូមិ* | *រយៈពេល...... ម៉ោង* |

*សំគាល់ : ប្រសិនបើភូមិនៅជាប់ផ្លូវ រយៈពេលធ្វើដំណើរដល់ផ្លូវនោះ គឺ**សូន្យ** ហើយ ចំងាយក៏**សូន្យ**ដែរ ។ ចំងាយនោះ ត្រូវគិតត្រឹមចំនុចដែលនៅជិតបំផុត ។ ផ្លូវដែលអាចមានរថយន្តឈ្នួល(តាក់ស៊ី) បើកទៅមកបានរាល់ថ្ងៃ ត្រូវចាត់ទុកថាជាផ្លូវអាចបើកឡានពេញ១ឆ្នាំ ។*

***ចំងាយជាមធ្យមពីចំណុចកណ្តាលភូមិទៅសាលាឃុំ/សង្កាត់ សាលាស្រុក/ខណ្ឌ សាលាខេត្ត/ក្រុង :***

| | | |
|---|---|---|
| 142 | *ចំងាយជាមធ្យមពីចំណុចកណ្តាលភូមិទៅសាលាឃុំ/សង្កាត់* | *មាន .......... គ.ម* |
| 143 | *ចំងាយជាមធ្យមពីចំណុចកណ្តាលភូមិទៅសាលាស្រុក/ខណ្ឌ* | *មាន .......... គ.ម* |
| 144 | *ចំងាយជាមធ្យមពីចំណុចកណ្តាលភូមិទៅសាលាខេត្ត/ក្រុង* | *មាន .......... គ.ម* |

ស្ថិតិនេះ មានសារៈសំខាន់ចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការពិភាក្សាអំពីស្ថានភាពផ្លូវ និងទីផ្សារ ដែលមានការប្រែប្រួលសំរាប់រយៈពេលវែង ។

# ស្ថានភាពផ្នែកសុខភាពនិងអនាម័យ

*នៅក្នុងភូមិយើងខ្ញុំមាន :*

| | | |
|---|---|---|
| 145 | *ចំនួន **ឆ្មបបុរាណ** ចេះតគ្នាឬបានទទួលការបណ្តុះបណ្តាលតិចតួច* | *មាន ...... នាក់* |
| 146 | *ចំនួន **ពេទ្យឆ្មប** ដែលមានរស់នៅក្នុងភូមិ* | *មាន ...... នាក់* |
| 147 | *ចំងាយពីចំនុចកណ្តាលភូមិទៅមណ្ឌលសុខភាព* | *មាន ....... គ.ម* |

*សំគាល់ : ប្រសិនបើមណ្ឌលសុខភាពមានទីតាំងនៅក្នុងភូមិ ចំងាយគឺ **សូន្យ** គ.ម ។*

**ឆ្មបបុរាណ :** សំដៅដល់ឆ្មបដែលមិនបានឬបានទទួលការបណ្តុះបណ្តាលតិចតួចពីអង្គការនានា ឬពីមណ្ឌលសុខភាព ។

**ពេទ្យឆ្មប :** សំដៅដល់ឆ្មបដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈត្រឹមត្រូវនិងទទួលស្គាល់ដោយក្រសួងសុខាភិបាល ។ ការកត់ត្រានេះ សំដៅទៅលើពេទ្យឆ្មបដែលរស់នៅជាអចិន្ត្រៃយ៍នៅក្នុងភូមិ គឺមិនសំដៅទៅលើពេទ្យឆ្មបណាដែលមកធ្វើការនៅក្នុងភូមិឬឃុំឡើយ ។

ស្ថិតិនេះ ត្រូវប្រើជាមួយតួលេខស្ថិតិខាងក្រោម ដើម្បីធ្វើការបកស្រាយថា តើបណ្តាលមកពីមូលហេតុអ្វី បានជាស្ត្រីភាគច្រើននៅក្នុងភូមិប្រើប្រាស់សេវាឆ្មបបុរាណ ? ។ ការស្រង់ស្ថិតិនេះ អាចជួយអោយក្រុមប្រឹក្សាឃុំ-សង្កាត់រៀបចំគំរោងឬកម្មវិធីបង្កើនសុវត្ថិភាពក្នុងពេលសំរាលកូន ដើម្បីកាត់បន្ថយអគ្រាគ្រោះថ្នាក់នានា ដូចជា:

- ការបណ្តុះបណ្តាលឆ្មបបុរាណ ការបង្កើតមធ្យោបាយដឹកជញ្ជូនស្ត្រីឆ្លងទន្លេពេលមានអាសន្ន ។
- ការផ្តល់កញ្ចប់សំភារៈចំពោះស្ត្រីមានផ្ទៃពោះ ការផ្តល់សេវាពិគ្រោះនិងពិនិត្យផ្ទៃពោះ ។

- យុទ្ធនាការអប់រំសុខភាពស្ត្រីមានផ្ទៃពោះ ការចុះអប់រំណែនាំស្ត្រីមានផ្ទៃពោះដល់ផ្ទះ ...។ល។

***នៅក្នុងឆ្នាំនេះ ក្នុងភូមិយើងខ្ញុំមានស្ត្រីសំរាលកូនដូចខាងក្រោម :***

| | បរិយាយ | ឆ្មបបុរាណ | ពេទ្យឆ្មប | សរុប |
|---|---|---|---|---|
| 148 | ចំនួនស្ត្រីដែលបានឆ្លងទន្លេ (សំរាលកូន) | ......... នាក់ | ....... នាក់ | ..... នាក់ |
| 149 | ចំនួនមរណភាពមាតាបន្ទាប់ពីសំរាលកូនក្នុងចន្លោះ០_១ខែ | ......... នាក់ | ....... នាក់ | ..... នាក់ |
| 150 | ចំនួនទារកដែលកើតរស់ | ......... នាក់ | ....... នាក់ | ..... នាក់ |
| 151 | ចំនួនទារកដែលបានស្លាប់ (គិតពីអាយុ០ថ្ងៃដល់១ខែ) | ......... នាក់ | ....... នាក់ | ..... នាក់ |

| | | |
|---|---|---|
| 152 | ចំនួនមរណភាពកុមារអាយុក្រោម៥ឆ្នាំ (គិតពីអាយុ១ខែឡើង) | មាន ....... នាក់ |

**ស្ត្រីដែលឆ្លងទន្លេដោយពេទ្យឆ្មប** មិនសំដៅតែទៅលើស្ត្រីទាំងឡាយដែលបានសំរាលកូននៅមណ្ឌលសុខភាព ឬនៅតាមមន្ទីរពេទ្យរដ្ឋឬឯកជនឡើយ ។ ទោះបីស្ត្រីនោះសំរាលកូននៅតាមផ្ទះក៏ដោយ សំខាន់បំផុតនៅពេលដែលស្ត្រីនោះសំរាលកូន ឆ្មបដែលជួយបង្កើតគឺជាពេទ្យឆ្មបដែលបានរៀនសូត្រជំនាញពេទ្យមានវិជ្ជាជីវៈត្រឹមត្រូវដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាល មេភូមិត្រូវកត់ត្រាជាស្ត្រីសំរាលកូនដោយពេទ្យឆ្មប ។ ការកត់ត្រាចំនួនស្ត្រីសំរាលកូនត្រូវកត់បញ្ចូល ផងដែរចំពោះករណីស្ត្រីសំរាលកូនដោយការវះកាត់ គឺកត់ត្រាទៅក្នុងផ្នែកស្ត្រីបានសំរាលកូនដោយពេទ្យឆ្មប ។ ដោយឡែកចំពោះស្ត្រីដែលមានកូនស្លាប់ក្នុងពោះ ហើយត្រូវការវះកាត់ មិនត្រូវកត់ត្រាបញ្ចូលទៅ

ក្នុងចំនួនស្ត្រីបានសំរាលកូនទេ ហើយទារកស្លាប់ក្នុងផ្ទៃនោះ ក៏មិនត្រូវកត់ត្រាចូលទៅក្នុងចំនួនមរណភាពទារកក្នុងចន្លោះអាយុ ០-១ខែដែរ។

**ចំនួនមរណភាពមាតាបន្ទាប់ពីសំរាលកូនក្នុងចន្លោះពី០ថ្ងៃដល់១ខែ** ការ កត់ត្រាត្រូវរាប់បញ្ចូលចំពោះស្ត្រីដែលបានសំរាលកូនបានប៉ុន្មាននាទីហើយបានស្លាប់ ឬស្លាប់នៅពេលសំរាលកូន ។

**ចំនួនទារកកើតរស់**អាចមានចំនួនច្រើនជាងចំនួនស្ត្រីដែលបានសំរាលកូន (ករណីកូនភ្លោះ)តែមិនអាចតិចជាងចំនួនស្ត្រីដែលបានឆ្លងទន្លេ(សំរាលកូន) ឡើយ ។ ការកត់ត្រាត្រូវកត់ផងដែរ ចំពោះទារកដែលម្តាយសំរាលកូនដោយការវះកាត់ ។

**ចំនួនទារកដែលបានស្លាប់គិតពីអាយុ០ថ្ងៃដល់១ខែ** : សំដៅទៅលើទារកណាដែលបានស្លាប់ក្នុងចន្លោះអាយុ១ខែ ឬក្រោមមួយខែ ទោះបីជាទារកនោះកើតមកបាន១នាទី ហើយស្លាប់ទៅវិញក៏ដោយ ក៏ត្រូវកត់ត្រាដែរ។ ដោយឡែកចំពោះទារកដែលស្លាប់ក្នុងពោះ ដែលម្តាយត្រូវធ្វើការវះកាត់យកចេញមិនត្រូវកត់ត្រាឡើយ ។

**ចំនួនមរណភាពកុមារអាយុក្រោម៥ឆ្នាំ** : សំដៅទៅលើកុមារដែលបានស្លាប់ក្នុងចន្លោះអាយុលើសពី១ខែឡើងទៅដល់អាយុ៥ឆ្នាំ ព្រោះចំនួនមរណភាពកុមារនៅក្នុងចន្លោះអាយុពី០ថ្ងៃទៅ ដល់១ខែបានកត់ត្រានៅផ្នែកខាងលើរួចហើយ ។

***នៅក្នុងឆ្នាំនេះ ក្នុងភូមិយើងខ្ញុំមាន :***

| | | |
|---|---|---|
| 153 | *ចំនួនទារកដែលបានចុះសំបុត្រកំណើត* | *មាន ...... នាក់* |
| 154 | *ចំនួនកុមារដែលមានអាយុ ចន្លោះពី៩ខែ-១២ខែ* | *មាន ...... នាក់* |
| 155 | *ចំនួនកុមារអាយុចន្លោះពី៩ខែ-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន (៦ឬ៧មុខ)* | *មាន ...... នាក់* |

**ចំនួនទារកដែលបានចុះសំបុត្រកំណើត :** គឺកត់ត្រាតែទារកបានកើតក្នុងឆ្នាំនេះ បានចុះសំបុត្រកំណើតតែប៉ុណ្ណោះ ។ ចំពោះទារកដែលកើតពីឆ្នាំទៅ ហើយទើបបានចុះសំបុត្រកំណើតក្នុងឆ្នាំនេះ មិនត្រូវកត់ត្រាបញ្ចូលឡើយ ។ ការកត់ត្រាស្ថិតិនេះ គឺដើម្បីរាយការណ៍ជូនឃុំ-សង្កាត់ ថាតើប្រជាជនមានការយល់ដឹងពីច្បាប់អត្រានុកូលដ្ឋានបានប៉ុន្មាននាក់ ។ បើចំនួននេះនៅមានកំរិតទាបតើបណ្តាលមកពីមូលហេតុអ្វី ? ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវដោះស្រាយតាមវិធីណាដែលល្អប្រសើរ ? ដូចជាចុះពន្យល់ណែនាំដល់គ្រួសារទាំងនោះផ្ទាល់ ...។ល។

**ចំនួនកុមារដែលមានអាយុចន្លោះ៩-១២ខែ :** សំដៅទៅលើកុមារដែលបានកើតនៅកំឡុងខែមករា-មិនាក្នុងឆ្នាំស្រង់ស្ថិតិ។ បន្ទាប់មកគិតក្នុងចំណោមកុមារទាំងនោះ តើមានចំនួនប៉ុន្មាននាក់ដែលបានចាក់ថ្នាំបង្ការជំងឺបានគ្រប់មុខ។ ការស្រង់ស្ថិតិបែបនេះ អាចឱ្យយើងគិតជាភាគរយថា តើនៅក្នុងភូមិមានកុមារប៉ុន្មានភាគរយ ដែលបានទទួលថ្នាំបង្ការគ្រប់មុខ ។

**កុមារដែលបានចាក់ថ្នាំបង្ការគ្រប់ចំនួន :** ដើម្បីជួយជំរុញអោយកុមារទាំងអស់នៅក្នុងភូមិទទួលបាននូវការចាក់វ៉ាក់សាំងគ្រប់ចំនួន(៧មុខ) សំរាប់ការពារ ជំងឺផ្សេងៗដូចជា ជំងឺរបេង រលាកថ្លើម ប្រភេទបេ គ្រុនស្វិតដៃជើង ខាន់ស្លាក់ ក្អកមាន់ តេតាណូស និងជំងឺកញ្ជ្រឹល ។ ការចាក់ថ្នាំបង្ការត្រូវធ្វើឡើងចាប់ពីកុមារទើបកើត រហូតដល់កុមារអាយុបាន៩ខែ (ការចាក់ថ្នាំការពារ កញ្ជ្រឹលចុងក្រោយនៅពេលកុមារអាយុ៩ខែ) ។ ចំនួនកុមារអាយុចន្លោះ៩ខែ-១ឆ្នាំ ប្រហែលជាមានមិនច្រើន ប៉ុន្មានទេក្នុងភូមិនិមួយៗ ប៉ុន្តែវាមានសារៈសំខាន់បំផុត ដើម្បីក្រុមប្រឹក្សាឃុំ-សង្កាត់ ជាពិសេសជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារ ដឹងថាកន្លងមកមានកុមារអាយុចន្លោះ៩ខែ-១ឆ្នាំសរុបប៉ុន្មាននាក់ ហើយមានចំនួន

ប៉ុន្មាននាក់ដែលបានទទួលថ្នាំបង្កាគ្រប់ចំនួន នៅសល់ប៉ុន្មាននាក់ដែលមិនបានទទួលគ្រប់ចំនួន ហេតុអ្វី ? ។ នៅពេលដឹងច្បាស់ពីមូលហេតុ ដែលមានកុមារមិនបានទទួលថ្នាំបង្ការគ្រប់ចំនួន ក្រុមប្រឹក្សាឃុំ-សង្កាត់ ជាពិសេសជនបង្គោលស្ត្រីនិងកុមារ អាចរៀបចំសកម្មភាពជាក់ស្តែង ដើម្បីអនុវត្តផ្ទាល់ជាមួយគ្រួសារកុមារទាំងនោះ ដូចជាការពន្យល់ណែនាំ យុទ្ធនាការអប់រំសុខភាព ឬផ្តល់ការលើកទឹកចិត្តផ្សេងៗ ។ តាមការពិត កុមារដែលមានអាយុ១ឆ្នាំជាកំរិតអាយុដែលហួសពេលនិងត្រូវទទួលថ្នាំវ៉ាក់សាំងហើយ ប៉ុន្តែសកម្មភាពដែលត្រូវធ្វើគឺជាមួយគ្រួសារកុមារដែលមានអាយុតិចជាង៩ខែ ។ ការស្រង់ស្ថិតិនេះ គឺជាការរំលឹកឡើងវិញ និងដើម្បីពិភាក្សារកវិធីដោះស្រាយនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ដែលជួយជំរុញអោយកុមារទាំងអស់ទទួលបានវ៉ាក់សាំងគ្រប់ចំនួនគ្រប់ៗគ្នា ព្រោះការចាក់វ៉ាក់សាំងមិនមានបង់ប្រាក់ឡើយ ។

# ការប្រើប្រាស់ទឹកក្នុងភូមិ

*តាមការរាប់ជាក់ស្តែងក្នុងឆ្នាំនេះ នៅក្នុងភូមិយើងខ្ញុំមាន :*

***អណ្តូងស្នប់ ឬអណ្តូងចំរុះ*** *(បើគ្មានបំពេញលេខសូន្យ) :*

| | | |
|---|---|---|
| 156 | *ចំនួនអណ្តូងស្នប់ ឬអណ្តូងចំរុះដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ* | *មាន....... អណ្តូង* |
| 157 | *ចំនួនអណ្តូងស្នប់ឬអណ្តូងចំរុះដែល**មិន**អាចប្រើប្រាស់បាននៅ រដូវប្រាំង (ទឹកមិនចេញ)* | *មាន....... អណ្តូង* |
| 158 | ***សរុបចំនួនអណ្តូងស្នប់ ឬអណ្តូងចំរុះដែលមាននៅក្នុងភូមិ*** | ***មាន....... អណ្តូង*** |
| 159 | *ចំនួនអណ្តូងស្នប់ ចំរុះដែលត្រូវការចាំបាច់ ធ្វើការជួសជុលឬស្តារឡើងវិញ* | *មាន....... អណ្តូង* |

***អណ្ដូងលូ*** *(បើគ្មានបំពេញលេខសូន្យ)* **:**

| | | |
|---|---|---|
| *160* | *ចំនួនអណ្ដូងលូដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ* | *មាន....... អណ្ដូង* |
| *161* | *ចំនួនអណ្ដូងលូដែល**មិន**អាចប្រើប្រាស់បាននៅរដូវប្រាំង (ទឹកមិនចេញ)* | *មាន....... អណ្ដូង* |
| *162* | ***សរុបចំនួនអណ្ដូងលូដែលមាននៅក្នុងភូមិ*** | ***មាន....... អណ្ដូង*** |
| *163* | *ចំនួនអណ្ដូងលូដែលត្រូវការចាំបាច់ ធ្វើការជួសជុស ឬស្ដារឡើងវិញ* | *មាន....... អណ្ដូង* |

***អណ្ដូងដៃមិនដាក់លូឬមិនរៀបឥដ្ឋ*** *(បើគ្មានបំពេញលេខសូន្យ)* **:**

| | | |
|---|---|---|
| *164* | *ចំនួនអណ្ដូងដៃមិនដាក់លូឬមិនរៀបឥដ្ឋ ដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ* | *មាន....... អណ្ដូង* |
| *165* | *ចំនួនអណ្ដូងដៃមិនដាក់លូឬមិនរៀបឥដ្ឋ ដែល**មិន**អាចប្រើប្រាស់បាននៅរដូវប្រាំង (ទឹកមិនចេញ)* | *មាន....... អណ្ដូង* |
| *166* | ***សរុបចំនួនអណ្ដូងដៃមិនដាក់លូឬមិនរៀបឥដ្ឋ ដែលមាននៅក្នុងភូមិ*** | ***មាន....... អណ្ដូង*** |

**អណ្ដូងដែលមិនអាចប្រើប្រាស់បាននៅរដូវប្រាំង :** គឺជាអណ្ដូង (អណ្ដូងស្នប់ អណ្ដូងចំរុះ អណ្ដូងលូ) ដែលនៅរដូវប្រាំង ជារៀងរាល់ឆ្នាំមិនអាចប្រើប្រាស់បាន (រីង គ្មានទឹក) ។ ករណីអណ្ដូងដែលរីងគ្មានទឹកម្ដងម្កាលដោយសារការរាំងស្ងួតនៃឆ្នាំណាមួយនោះ មិនត្រូវកត់ត្រាបញ្ចូលក្នុងផ្នែកនេះឡើយ គឺត្រូវចាត់ទុកជាអណ្ដូងដែលអាចប្រើប្រាស់បានជារៀងរាល់ឆ្នាំ (ទាំងរដូវវស្សា និងរដូវ ប្រាំង)។

**សរុបចំនួនអណ្ដូង** គឺជាអណ្ដូងសរុបដែលមាននៅក្នុងភូមិ ដោយគិតទាំងអណ្ដូងសហគមន៍ និងអណ្ដូងឯកជន តែមិនត្រូវកត់ត្រាបញ្ចូលអណ្ដូងណាដែលឈប់ប្រើ ដូចជាអណ្ដូងទឹកដែលមានជាតិអាសេនិចជាដើម ។

**អណ្ដូងដែលត្រូវជួសជុលឬស្ដារ :** សំដៅទៅលើអណ្ដូងទឹកប្រើរួមដែលមេភូមិយល់ថា ការជួសជុលឬថែទាំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឃុំ ឬក្រុម

ប្រើប្រាស់ទឹកស្អាតនិងអានាម័យ ។ ចំពោះអណ្តូងដែលខូច ស្ថិតនៅក្នុងការគ្រប់គ្រងរបស់ឯកជន មិនត្រូវកត់ត្រាបញ្ចូលឡើយ ។

**អណ្តូងទឹកដែលជីកដោយដៃ :** ជាប្រភេទអណ្តូងទឹកជីកតាមគ្រួសារដោយគ្មានដាក់ខ្នោះ ឬ អណ្តូងគ្មានរៀបអិដ្ឋ។

***ស្រះទឹកធម្មតា*** *( បើគ្មានបំពេញលេខសូន្យ)* **:**

| | | |
|---|---|---|
| *167* | *ចំនួនស្រះទឹកដែលអ្នកភូមិប្រើប្រាស់និងទទួលទានដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ* | *មាន ........ ស្រះ* |
| *168* | *ចំនួនស្រះទឹកដែលអ្នកភូមិប្រើប្រាស់និងទទួលទានដែលមិនអាចប្រើប្រាស់បានពេញមួយឆ្នាំ* | *មាន ........ ស្រះ* |
| *169* | ***សរុបចំនួនស្រះទឹកដែលអ្នកភូមិប្រើប្រាស់និងទទួលទានដែលមាននៅក្នុងភូមិ*** | *មាន* ***........ ស្រះ*** |
| *170* | *ចំនួនស្រះទឹកដែលអ្នកភូមិប្រើប្រាស់និងទទួលទានដែលចាំបាច់ត្រូវស្តារឬជួសជុល* | *មាន ........ ស្រះ* |

**ចំនួនស្រះទឹកដែលអ្នកភូមិប្រើប្រាស់និងសំរាប់ទទួលទានដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ :** ចំនួនស្រះទឹកសំរាប់ហូបនិងប្រើប្រាស់នេះ សំដៅទៅលើស្រះទឹកណា ដែលប្រជាពលរដ្ឋទៅដងទឹកសំរាប់ទទួលទាននិងប្រើប្រាស់ប្រចាំថ្ងៃ ដែលប្រើប្រាស់ជារៀងរាល់ឆ្នាំ (ទាំងរដូវប្រាំង និងវស្សា) ដូចជាស្រះទឹកសាធារណៈ ឬស្រះទឹកនៅក្នុងវត្តជាដើម ។ ក្នុងចំនុចនេះកត់ត្រាបញ្ចូលផងដែរ ចំពោះស្រះទឹកណាដែលគោគរីងម្តងម្កាលដោយសារភាពរាំងស្ងួតក្នុងឆ្នាំណាមួយនោះ ។ ចំពោះស្រះទឹកសំរាប់ចិញ្ចឹមត្រី ឬសំរាប់ស្រោចបន្លែ ឬសំរាប់បោកគក់ម្តងម្កាល ដែលមាននៅតាមមុខផ្ទះ ឬក្រោយផ្ទះ មិនត្រូវកត់ត្រារាប់បញ្ចូលឡើយ។

**ចំនួនស្រះទឹកដែលអ្នកភូមិប្រើប្រាស់និងទទួលទានដែលមិនអាចប្រើប្រាស់បាននៅរដូវប្រាំង :** សំដៅទៅលើស្រះទឹកណាដែលប្រជាជនប្រើប្រាស់និងសំរាប់ទទួលទានបានតែក្នុងរដូវវស្សា ហើយនៅក្នុងរដូវប្រាំងត្រូវរីងស្ងួតគ្មានទឹក ឬមានទឹកដែរ តែកករល្អក់ប្រើមិនកើត ។

**ចំនួនស្រះទឹកដែលត្រូវស្តារ :** សំដៅទៅលើស្រះទឹកដែលស្ថិតនៅក្រោមការគ្រប់គ្រងថែរក្សារបស់សហគមន៍ ដែលមេភូមិដែលឃើញថាចាំបាច់ត្រូវស្តារ ដោយជីកឱ្យជ្រៅដើម្បីធានាមានទឹកប្រើប្រាស់ពេញមួយឆ្នាំ ។

***ស្រះទឹកប្រពន្ធ័ចំរោះ*** *( បើគ្មានបំពេញលេខសូន្យ)* **:**

| | | |
|---|---|---|
| *171* | *ចំនួនស្រះទឹកប្រពន្ធ័ចំរោះដែលអ្នកភូមិប្រើប្រាស់និងទទួលទានដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ* | *មាន ........ ស្រះ* |
| *172* | *ចំនួនស្រះទឹកប្រពន្ធ័ចំរោះដែលអ្នកភូមិប្រើប្រាស់និងទទួលទានដែលមិនអាចប្រើប្រាស់បានពេញមួយឆ្នាំ* | *មាន ......... ស្រះ* |
| *173* | ***សរុបចំនួនស្រះទឹកប្រពន្ធ័ចំរោះដែលអ្នកភូមិប្រើប្រាស់និងទទួលទាន ដែលមាននៅក្នុងភូមិ*** | *មាន ......... **ស្រះ*** |
| *174* | *ចំនួនស្រះទឹកប្រពន្ធ័ចំរោះដែលអ្នកភូមិប្រើប្រាស់និងទទួលទានដែលចាំបាច់ត្រូវស្តារឬជួសជុល* | *មាន .......... ស្រះ* |

**ស្រះទឹកប្រពន្ធ័ចំរោះ :** សំដៅទៅលើស្រះទឹកមួយចំនួន ដែលមានរៀបចំប្រពន្ធ័ច្រោះទឹក ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ ស្រះទឹកប្រភេទនេះ ច្រើនមានស្នប់សំរាប់សប់យកទឹក គេមិនដងទឹកក្នុងស្រះផ្ទាល់តែម្តងទេ ។

ស្ថិតិនេះមានសារៈសំខាន់ ដើម្បីអោយក្រុមប្រឹក្សាឃុំ-សង្កាត់ អាចប៉ាន់ស្មានទំហំការងារនិងថវិកាដែលត្រូវការ សំរាប់ធានាអោយប្រជាជនមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ តាមរយៈការដោះស្រាយជាជំហាន១ ក៏ដូចជាស្វែងរកការគាំទ្រ ឬការចូលរួមរបស់ប្រជាជនមូលដ្ឋានផងដែរ ។ ចំនួនស្ថិតិអណ្តូង

និងស្រះទឹកខាងលើ ត្រូវប្រើប្រាស់រួមគ្នាជាមួយស្ថិតិចំនួនគ្រួសារតាមប្រភពទឹកប្រើប្រាស់ឆ្ងាយឬជិតជាង១៥០ម៉ែត្រពីផ្ទះ ។

### *ប្រភពទឹកប្រើប្រាស់ (បើគ្មានបំពេញលេខសូន្យ)*

| | | |
|---|---|---|
| 175 | *ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកបានឆ្លងកាត់ប្រពន្ធ័ធ្វើទឹកឱ្យស្អាត* | *មាន ........ គ្រួសារ* |
| 176 | *ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកពីប្រភពទឹកអណ្តូងស្នប់ អណ្តូងចំរុះ* | *មាន ........ គ្រួសារ* |
| 177 | *ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកពីប្រភពទឹកអណ្តូងលូ អណ្តូងជីកដៃ* | *មាន ........ គ្រួសារ* |
| 178 | *ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកស្រះ* | *មាន ........ គ្រួសារ* |
| 179 | *ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកពីអាងស្តុកទឹកភ្លៀង (ប្រចាំគ្រួសារ)* | *មាន ........ គ្រួសារ* |
| 180 | *ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកពីប្រភពទឹកទន្លេ ស្ទឹង បឹង ត្រពាំង អាងស្តុកទឹក* | *មាន ........ គ្រួសារ* |

*សំគាល់ : ផលបូកចំនួនគ្រួសារដែលប្រើប្រាស់ប្រភពទឹកខាងលើនេះ ត្រូវស្មើចំនួនគ្រួសារសរុបក្នុងភូមិ ។*

### *ការប្រើប្រាស់ទឹកសំរាប់ទទួលទាននៅរដូវប្រាំង*

| | | |
|---|---|---|
| 181 | *ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកសំរាប់ទទួលទាននៅរដូវប្រាំងពីប្រភពទឹក **ស្អាត*** | *មាន........ គ្រួសារ* |
| 182 | *ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកសំរាប់ទទួលទាននៅរដូវប្រាំងពីប្រភពទឹក **មិនស្អាត*** | *មាន........ គ្រួសារ* |

*សំគាល់ : ផលបូកចំនួនគ្រួសារដែលប្រើប្រាស់ទឹកសំរាប់ទទួលទានខាងលើនេះ ត្រូវស្មើចំនួនគ្រួសារសរុបក្នុងភូមិ។*

**ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកសំរាប់ទទួលទាននៅរដូវប្រាំងពីប្រភពទឹកស្អាត :** គឺសំដៅទៅលើគ្រួសារដែលដងទឹកពីអណ្តូងស្នប់ ឬអណ្តូងចំរុះ ដែលមានស្នប់មកទទួលទានតែម្តង ។

**ចំនួនគ្រួសារដែលនិយមប្រើប្រាស់ទឹកសំរាប់ទទួលទាននៅរដូវប្រាំងពីប្រភពទឹកមិនស្អាត :** គឺសំដៅទៅលើគ្រួសារដែលបានដងទឹកមកទទួលទានផ្ទាល់តែម្តងពីទឹកអណ្តូងចំហ (អណ្តូងខ្នោះ ឬអណ្តូង ជីកដោយដៃ) ទឹកស្រះ ត្រពាំង ព្រែក បឹង ទន្លេ ទឹកភ្លៀង.....។ល។

ចំនួនដែលស្រង់ឡើងនេះ សំដៅទៅលើលទ្ធភាពនៃការប្រើប្រាស់ទឹកទទួលទាននៅរដូវប្រាំង ដែលជារដូវពិបាកក្នុងការរកទឹកទទួលទានសំរាប់គ្រួសារនិមួយៗ ហើយការកត់ត្រានេះ គឺរាប់តាមការជាក់ស្តែងនៅក្នុងឆ្នាំនេះ ។ ស្ថិតិនេះគ្រាន់តែជាចំនួនសរុប ដើម្បីឱ្យដឹងថាតើនៅក្នុងភូមិនៅក្នុងរដូវប្រាំងនេះ មានប៉ុន្មានគ្រួសារដែលប្រើប្រាស់ទឹកស្អាតសំរាប់ទទួលទាន នឹងមានប៉ុន្មានគ្រួសារ ដែលមានទំលាប់ទទួលទានទឹកពីប្រភពទឹកមិនស្អាត ។ ប្រសិនបើមានតួលេខស្ថិតិនេះ ជាការងាយស្រួលក្នុងការប៉ាន់ស្មានទំហំគំរោង ចុះអប់រំដល់មូលដ្ឋានជាក់ស្តែងតើមានប៉ុន្មានគ្រួសារដែលឃុំ-សង្កាត់ត្រូវធ្វើការអប់រំ។ ប្រសិនបើមានជំងឺរាគរូសជាពិសេសកុមារ យើងអាចប៉ាន់ស្មានថា ប្រហែលជាមកពីការប្រើទឹកមិនស្អាតនេះហើយ ។

***អនាម័យនៃការទទួលទានទឹក***

| | | |
|---|---|---|
| *183* | *ចំនួនគ្រួសារដែលនិយមប្រើប្រាស់ឧបករណ៍ចំរោះទឹកសំរាប់ទទួលទាន* | *មាន ......... គ្រួសារ* |
| *184* | *ចំនួនគ្រួសារដែលមានទំលាប់ទទួលទានទឹកដាំពុះ* | *មាន ......... គ្រួសារ* |

**គ្រួសារដែលនិយមប្រើប្រាស់ឧបករណ៍ចំរោះទឹកសំរាប់ទទួលទាន :** សំដៅទៅលើគ្រួសារទាំងឡាយ ដែលមានទំលាប់ទទួលទានទឹកដោយឆ្លងកាត់ឧបករណ៍ចំរោះទឹក ទោះបីទឹកនោះយកមកពីប្រភពណាក៏ដោយ(ទឹកប្រភពពីអណ្តូងស្នប់ អណ្តូងចំរោះ អណ្តូងលូ ទឹកស្រះ ត្រពាំង ទឹកភ្លៀង ស្ទឹង) ។

**គ្រួសារដែលមានទំលាប់ទទួលទានទឹកដាំពុះ :** សំដៅទៅលើគ្រួសារទាំងឡាយ ដែលមានទំលាប់ទទួលទានទឹកបានដាំទឹកឱ្យពុះ ទោះបីទឹកនោះបានឆ្លងកាត់ឧបករណ៍ចំរោះទឹករួចហើយក៏ដោយ ។ ការកត់ត្រានេះសំដៅទៅលើគ្រួសារដែលមានទំលាប់ទទួលទានទឹកដាំពុះ ទោះបីនៅក្នុងសមាជិកគ្រួសារនោះមិនបានទទួលទានទឹកដាំពុះបានគ្រប់គ្នាក៏ដោយ ។

ក្នុងករណីគ្រួសារមួយបានប្រើប្រាស់ឧបករណ៍ចំរុះទឹក ប៉ុន្តែមុនទទួលទានបានដាំទឹកឱ្យពុះ ក្នុងករណីនេះ ត្រូវកត់ត្រាទាំងពីរក្នុងសំណួរខាងលើ ។

***ចំងាយប្រភពទឹកប្រើប្រាស់ក្នុងរដូវប្រាំងនិងវស្សា***

| | | |
|---|---|---|
| *185* | *គ្រួសារដែលមានទឹកអណ្តូងស្នប់ ឬអណ្តូងលូ ឬបំពង់ទុយោប្រើប្រាស់ដល់ក្នុងផ្ទះ ឬចំងាយជិតជាង១៥០ម៉ែត្រពីផ្ទះ* | *មាន ....... គ្រួសារ* |
| *186* | *គ្រួសារដែលមានទឹកអណ្តូងស្នប់ ឬអណ្តូងលូ ឬបំពង់ទុយោប្រើប្រាស់ ដែលមានចំងាយឆ្ងាយជាង១៥០ម៉ែត្រពីផ្ទះ* | *មាន ....... គ្រួសារ* |

***តាមការរាប់ជាក់ស្តែងរបស់យើងខ្ញុំ ក្នុងឆ្នាំនេះក្នុងភូមិទាំងមូលមាន :***

| | | |
|---|---|---|
| *187* | *ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួន* | *មាន ....... គ្រួសារ* |

**ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួន :** គឺកត់ត្រាយកតែគ្រួសារណាដែលមានបង្គន់ នៅតាមលំនៅដ្ឋានផ្ទាល់ខ្លួនដែលមានការបិទបាំងជិតល្អ (បង្គន់ចាក់ទឹក) ។ ចំពោះគ្រួសារណាដែលប្រើប្រាស់បង្គន់រួម ដូចជាបង្គន់

នៅតាមសាលារៀន នៅតាមវត្តអារ៉ាម នៅតាមសាលាឃុំ ឬនៅតាមទីសាធារណៈ មិនត្រូវកត់ត្រាបញ្ចូលឡើយ ។

ការកត់ត្រានេះមានសារៈសំខាន់ សំរាប់អោយក្រុមប្រឹក្សាឃុំ-សង្កាត់ ប៉ាន់ស្មានចំនួនគ្រួសារប្រជាជន ដែលត្រូវធ្វើការអប់រំផ្នែកអនាម័យ និងលើកគំរោងសាងសង់បង្គន់អនាម័យ តាមរូបភាពផ្តល់ទាំងស្រុង១០០% ឬផ្តល់ត្រឹមកំរិតណាមួយល្មមសមស្រប ។

# ស្ថានភាពផ្នែករដ្ឋបាលនិងសន្តិសុខសង្គម

***នៅក្នុងឆ្នាំនេះ ភូមិយើងខ្ញុំមានបញ្ហាអសន្តិសុខសង្គមនិងទំនាស់នានា ដែលកើតមានឡើងគួរអោយកត់សំគាល់ដូចខាងក្រោម :***

| | | |
|---|---|---|
| *188* | *ចំនួនករណីឃាតកម្ម ប្លន់ ចាប់ជំរិត* | *.......... លើក* |
| *189* | *ចំនួនករណីលួច* | *.......... លើក* |
| *190* | *ចំនួនករណីទំនាស់ដីធ្លី* | *......... លើក* |

**ចំនួនករណីឃាតកម្ម ប្លន់ ចាប់ជំរិត** :ការស្រង់ស្ថិតិនេះធ្វើឡើង សំរាប់លើកយកទៅពិភាក្សា នៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីចាត់វិធានការទប់ស្កាត់ ។ កន្លងមកនៅក្នុងសំណើគំរោងឃុំ-សង្កាត់ មានលើកឡើងពីការពង្រឹងប្រជាការពារ សង់ប៉ុស្តិ៍យាម ប៉ុន្តែនៅក្នុងស្ថិតិពុំឃើញមានករណីប្លន់ លួច កើតមានឡើងនៅក្នុងភូមិ-ឃុំទាល់តែសោះ (សូន្យករណី)។

**ចំនួនករណីលួច** : ដូចជាលួចមាន់ទា គោក្របី ធ្វើការកត់ត្រាតែចំនួនសរុបប៉ុណ្ណោះ ។

**ចំនួនករណីទំនាស់ដីធ្លី** : គឺជាទំនាស់ដីធ្លីគ្រប់ប្រភេទដូចជា ដីផ្ទះ ដីចំការ ឬដីស្រែ ដែលមានលក្ខណៈជាឯកជនឬជាសមូហភាព ។ ការកត់ត្រានេះ គឺកត់

ត្រាតែទំនាស់ដីធ្លីដែលកើតមានឡើងនៅក្នុងឆ្នាំនេះ បន្ថែមពីលើទំនាស់ចាស់ដែលកើតមានក្នុងឆ្នាំកន្លងមកហើយ ដែលមិនទាន់បានដោះស្រាយចប់នៅឡើយមកទល់ឆ្នាំនេះ ។ ចំពោះករណីទំនាស់ដែលបានដោះស្រាយរួច មិនត្រូវកត់បញ្ចូលឡើយ ។

ការកត់ត្រាចំនួនទំនាស់ដីធ្លី គឺដើម្បីលើកយកទៅពិភាក្សាក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ រិះរកវិធីដោះស្រាយ និងជំរុញល្បឿនដំណោះស្រាយ ករណីដែលមិនទាន់ដោះស្រាយចប់ ។

| | | |
|---|---|---|
| *191* | *ចំនួនករណីទំនាស់ផ្សេងៗ ទំនាស់មានកំរិតព្រហ្មទណ្ឌ* | ..... *លើក* |
| *192* | *ចំនួនករណីទំនាស់ផ្សេងៗ ទំនាស់មានកំរិតរដ្ឋប្បវេណី* | ..... *លើក* |
| *193* | ***សរុបចំនួនករណីទំនាស់ផ្សេងៗ ដែលមានកើតឡើងនៅក្នុងភូមិ*** | ........ ***លើក*** |

**ចំនួនករណីទំនាស់ផ្សេងៗ** : រាប់បញ្ចូលរាល់ទំនាស់ទាំងអស់ដែលបានកើតមានឡើងនៅក្នុងភូមិ ក្រៅពីទំនាស់ដីធ្លី ព្រោះបានកត់ត្រាខាងលើរួចហើយ ។ ករណីទាំងនោះមាន ដូចជា ជំលោះរវាង បងប្អូន ផ្ទះជិតគ្នា ក្រុមបងតូចបងធំ ការផឹកស៊ី ដែលបង្ករឱ្យមានរបួសស្នាម(កំរិតព្រហ្មទណ្ឌ) ឬ គ្មានរបួសស្នាម(កំរិតរដ្ឋប្បវេណី) ហើយដែលបានមកប្តឹងអោយមេភូមិដោះស្រាយ។ ស្ថិតិនេះមានសារៈសំខាន់ជាមូលដ្ឋាន សំរាប់ការលើកស្នើវគ្គបណ្តុះបណ្តាលអំពីនីតិវិធីដោះស្រាយជំលោះក្រៅប្រព័ន្ធតុលា ដល់មេភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ។

**សរុបចំនួនករណីទំនាស់ផ្សេងៗដែលមានកើតឡើងនៅក្នុងភូមិ =** ចំនួនករណីទំនាស់កំរិតព្រហ្មទណ្ឌ(បង្កររបួសស្នាម) **+** ចំនួនករណីទំនាស់កំរិតរដ្ឋប្បវេណី (គ្មានរបួសស្នាម) ។

| | | |
|---|---|---|
| 194 | ចំនួនគ្រួសារដែលជួបប្រទះអំពើហឹង្សាក្នុងគ្រួសារ | ........ គ្រួសារ |
| 195 | ចំនួនគ្រួសារដែលមានសមាជិកក្នុងគ្រួសារប្រើប្រាស់គ្រឿងញៀន | ....... គ្រួសារ |

**អំពើហឹង្សាក្នុងគ្រួសារ :** គឺជាការប្រើហឹង្សា ឬការរំលោភបំពានដែលប្រព្រឹត្តឡើងក្នុងគ្រួសារ ។ ការប្រើហឹង្សា ឬការរំលោភបំពាននេះ អាចបង្កឡើងដោយមនុស្សម្នាក់ឬច្រើននាក់ ដែលរួមបញ្ចូលទាំងប្រើហឹង្សាលើរូបរាងកាយ ផ្លូវភេទឬផ្លូវចិត្ត( ដោយបង្ខំនិងដោយឱ្យនៅឯកោ) និងការគៀបសង្កត់ផ្នែកសេដ្ឋកិច្ចរវាងសមាជិកគ្រួសារ ជាពិសេសរវាងប្តី ប្រពន្ធ និងបណ្តាលឱ្យមានស្នាមរបួសលើរូបរាងកាយ ឬធ្វើឱ្យប៉ះពាល់ផ្លូវចិត្តនិងអារម្មណ៍របស់ជនរងគ្រោះ ។ ការកត់ត្រានេះ គឺកត់ត្រាតែចំនួនគ្រួសារប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលគ្រប់ករណីដែលកើតឡើងដដែលៗក្នុងគ្រួសារនោះឡើយ ។ មានន័យថាទោះបីជាក្នុងគ្រួសារណាមួយកើតមានអំពើហឹង្សានេះច្រើនដងក៏ដោយ ក៏ធ្វើការកត់ត្រាតែ១គ្រួសារនោះដដែល ។

ស្ថិតិនេះ មានសារៈសំខាន់បំផុត សំរាប់លើកឡើងនូវវិធានការដោះស្រាយតាមវិធីច្បាប់ ឬតាមរយៈការអប់រំ រួមទាំងការរៀបចំបណ្តាញគាំទ្រចំពោះស្ត្រីនិងកុមារ ។ ប្រសិនបើមានពត៌មានប្រភេទនេះច្បាស់លាស់ ក្រុមប្រឹក្សាឃុំ-សង្កាត់ អាចស្នើសុំការគាំទ្រពីប្រភពផ្សេងៗបាន ។

**ចំនួនគ្រួសារដែលមានសមាជិកគ្រួសារប្រើប្រាស់គ្រឿងញៀន :** គឺកត់ត្រាតែគ្រួសារណាដែលជួបប្រទះការលំបាក មានទុក្ខព្រួយ( មេភូមិបានដឹង) ដោយសារសមាជិកក្នុងគ្រួសារនោះមានការប្រើប្រាស់គ្រឿងញៀន ។ ការដាក់បញ្ចូលបញ្ហាគ្រឿងញៀនទៅក្នុងការពិភាក្សារបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដើម្បីរកដំណោះស្រាយបាន លុះត្រាតែយើងមានតួលេខសំរាប់បង្ហាញជូនអង្គប្រជុំ ។

ជូនកាលអ្នកប្រើប្រាស់គ្រឿងញៀន ក៏បានបង្កបញ្ហាអសន្តិសុខ ជំលោះ ឬអំពើហឹង្សាផ្សេងៗ ដល់គ្រួសារ និងអ្នកភូមិផងដែរ ។

***ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន***

| | | | | |
|---|---|---|---|---|
| 196 | *ចំនួនគ្រួសារផ្លាស់លំនៅផ្លានចូល (អចិន្ត្រៃយ៍)* | *..... គ្រួសារ* | *សរុប...នាក់* | *ស្រី..... នាក់* |
| 197 | *ចំនួនគ្រួសារផ្លាស់លំនៅផ្លានចេញ (អចិន្ត្រៃយ៍)* | *..... គ្រួសារ* | *សរុប ...នាក់* | *ស្រី .... នាក់* |
| 198 | *ចំនួនគ្រួសារចូលមកស្នាក់នៅបណ្តោះអាសន្ន* | *.... គ្រួសារ* | *សរុប ...នាក់* | *ស្រី .... នាក់* |

**ចំនួនគ្រួសារផ្លាស់លំនៅផ្លានចូល(អចិន្ត្រៃយ៍)** : ជាស្ថិតិស្រង់តាមចំនួនជាក់ស្តែងក្នុងឆ្នាំ អំពីចំនួនគ្រួសារប្រជាជន ដែលផ្លាស់ទីលំនៅចូលមកស្នាក់នៅជាអចិន្ត្រៃយ៍(ជាប្រចាំរយៈពេលច្រើនឆ្នាំ) ដែលមេភូមិទទួលស្គាល់ជាប្រជាជនមូលដ្ឋាន ។ ប៉ុន្តែត្រូវកត់ត្រាតែក្នុងឆ្នាំរាយការណ៍(១២ខែកន្លងមក) មិនមែនសរុបបូកបញ្ចូលគ្នាពីឆ្នាំមុនៗមកទេ ។ មេភូមិគួរសហការជាមួយសមត្ថកិច្ចនគរបាលបន្ថែមទៀត ដើម្បីផ្ទៀងផ្ទាត់តួលេខស្ថិតអោយបានត្រូវគ្នា ។

**ចំនួនគ្រួសារផ្លាស់លំនៅផ្លានចេញ(អចិន្ត្រៃយ៍)** : ជាស្ថិតិស្រង់តាមចំនួនជាក់ស្តែងក្នុងឆ្នាំ អំពីចំនួនគ្រួសារប្រជាជនដែលផ្លាស់ទីលំនៅចេញទៅរស់ នៅទីកន្លែងផ្សេង ហើយដែលមេភូមិឈប់ទទួលស្គាល់ជាប្រជាជនមូលដ្ឋានទៀតហើយ ។ ប៉ុន្តែត្រូវកត់ត្រាតែក្នុងឆ្នាំរាយការណ៍(១២ខែកន្លងមក) មិនមែនបូកបញ្ចូលគ្នាជាមួយចំនួនគ្រួសារដែលបានផ្លាស់ចេញពីឆ្នាំមុនៗមកទេ។

**ចំនួនគ្រួសារចូលមកស្នាក់នៅបណ្តោះអាសន្ន** : ស្រង់តាមចំនួនជាក់ស្តែងក្នុងឆ្នាំ(១២ខែកន្លងមក) អំពីចំនួនគ្រួសារដែលបានចូលមកជួលផ្ទះអ្នកភូមិស្នាក់

នៅបណ្តោះអាសន្ន ដើម្បីប្រកបរបរជំនួញ ឬធ្វើជាបុគ្គលិក-កម្មកររបស់អង្គការ ក្រុមហ៊ុនផ្សេងៗ ឬមកធ្វើការនៅក្នុងភូមិដែលមិនមានចុះបញ្ជីគ្រួសារ ។ ការកត់ត្រាចំនួនគ្រួសារប្រភេទនេះ សំដៅតែគ្រួសារណាដែលមកស្នាក់នៅបណ្តោះអាសន្ន និងមានមុខនៅពេលស្រង់ទិន្នន័យ ។ ដោយឡែកចំពោះគ្រួសារដែលមកស្នាក់នៅជាបណ្តោះអាសន្នក្នុងរយៈពេល៥ឬ៦ខែ តែនៅពេលស្រង់ទិន្នន័យ(ខែ១២)បានចាកចេញទៅវិញអស់ហើយនោះ គ្រួសារដែលមកស្នាក់នៅប្រភេទនេះ មេភូមិមិនត្រូវកត់ត្រាទេ ព្រោះពួកគេបានចេញទៅបាត់អស់ហើយ ។

| | | |
|---|---|---|
| *199* | *ចំនួនគ្រួសារដែលមានផ្ទះរស់នៅលើដីសាធារណៈ* | *មាន ............ គ្រួសារ* |
| *200* | *ចំនួនមនុស្សជាជនអាណាថា គ្មានផ្ទះសំបែងពិតប្រាកដ* | *មាន ............... នាក់* |

**ចំនួនគ្រួសារដែលមានផ្ទះរស់នៅលើដីសាធារណៈ** ៖ សំដៅលើគ្រួសារដែលចូលមករស់នៅតាមទីសាធារណៈ ប្រឡាយទឹក ដងផ្លូវ របងឬនៅក្នុងវត្ត សាលារៀន...។ល។ ដោយគ្មានសណ្ដាប់ធ្នាប់ ដោយគ្រាន់តែប្រក់បន្ទះកៅស៊ូ ឬបិទបាំងបន្តិចបន្តួច ។ ស្ថិតិនេះ មានសារៈសំខាន់ណាស់ សំរាប់ការពិភាក្សាក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីរិះរកវិធីដោះស្រាយអោយទាន់ពេលវេលា ពុំត្រូវរង់ចាំរហូតទាល់តែចំនួនគ្រួសារប្រភេទនេះ កើនឡើងច្រើននោះឡើយ ។

**ចំនួនមនុស្សជាជនអាណាថា គ្មានផ្ទះសំបែងពិតប្រាកដ** ៖ ចំនួនស្ថិតិមនុស្សប្រភេទនេះ ត្រូវការចាំបាច់សំរាប់គ្រោងរៀបចំថវិកា អនុវត្តសកម្មភាពនានាដែលបានឯកភាពក្នុងអង្គប្រជុំ ។

ស្ថិតិនេះ មានសារៈសំខាន់ចំពោះក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការបាន់ស្មានអំពីចលនាប្រជាជន និងហេតុផលនានាទាក់ទងនិងបញ្ហាសន្តិសុខសុវត្ថិភាពរបស់ប្រជាជនក្នុងមូលដ្ឋាន ។ ស្ថិតិនេះ ក៏អាចជំរុញអោយមានការពិភាក្សាគ្នា អំពីបញ្ហាសុខភាពនិងអនាម័យ ដែលត្រូវដោះស្រាយនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ផងដែរ ។

## ក្រុមជនងាយរងគ្រោះឬកំពុងជួបការលំបាក

| | | |
|---|---|---|
| *201* | *ចំនួនគ្រួសារដែលមានសមាជិកក្នុងគ្រួសារផ្ទុកជំងឺអេដស៍ឬកើតជំងឺអេដស៍* | ......... *គ្រួសារ* |
| *202* | *ចំនួនកុមារកំព្រាអាយុក្រោម១៨ឆ្នាំ ដែលឪពុកឬម្តាយ ឬឪពុកម្តាយស្លាប់ ដោយសារជំងឺអេដស៍* | *មាន* ....... *នាក់* |

**ចំនួនគ្រួសារដែលមានសមាជិកគ្រួសារផ្ទុកជំងឺអេដស៍ឬកើតជំងឺអេដស៍ :** គឺកត់ត្រាតែគ្រួសារណា ដែលជួបប្រទះការលំបាក មានទុក្ខព្រួយដោយសារសមាជិកក្នុងគ្រួសារនោះមានផ្ទុកឬកើតជំងឺអេដស៍ ។ ស្ថិតិនេះ អាចស្រង់ជាចំនួនជាក់ស្តែងទៅតាមការដឹងរបស់មេភូមិ ឬពត៌មានពីប្រជាជនក្នុងភូមិ ។ ស្ថិតិនេះ មានសារៈសំខាន់ក្នុងការពិភាក្សាក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីស្វែងរកមធ្យោបាយជួយគាំទ្រ លើកទឹកចិត្តអោយគ្រួសារឬបុគ្គលនោះ ចូលរួមក្នុងសង្គម ឬការងារអភិវឌ្ឍន៍ ចៀសវាងការរើសអើង ស្អប់ខ្ពើមនានា ។

**ចំនួនកុមារកំព្រាអាយុក្រោម១៨ឆ្នាំដែលឪពុកឬម្តាយ ឬឪពុកម្តាយស្លាប់ដោយសារជំងឺអេដស៍ :** សំដៅទៅលើកុមារទាំងឡាយដែលមានអាយុក្រោម១៨ឆ្នាំ ដែលឪពុកឬម្តាយ ឬឪពុកម្តាយបានស្លាប់ចោល ហើយមេភូមិឬភូមិបានដឹងថា ឪពុកឬម្តាយ ឬឪពុកម្តាយកុមារទាំងនោះ បានស្លាប់ដោយសារជំងឺអេដស៍ ។

ស្ថិតិនេះមានសារៈសំខាន់ ក្នុងការពិភាក្សា នៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីរិះរកមធ្យោបាយជួយគាំទ្រជាបន្ទាន់ ព្រោះកុមារប្រភេទនេះងាយនឹងបោះបង់ការសិក្សា ងាយរងគ្រោះដោយការបោកប្រាស់យកទៅលក់ ងាយចូលក្នុងក្រុមក្មេងពាល ប្រើប្រាស់គ្រឿងញៀន ក្លាយជាក្មេងអនាថា និងប្រព្រឹត្តអំពើល្មើសច្បាប់ផ្សេងទៀត...។ល។

***កុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំ (បើគ្មានបំពេញលេខសូន្យ)***

| | | |
|---|---|---|
| *203* | *ចំនួនកុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំ ដែលមានអាណាព្យាបាលត្រឹមត្រូវ* | *មាន ....... នាក់* |
| *204* | *ចំនួនកុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំ ដែលគ្មានអាណាព្យាបាលត្រឹមត្រូវពិតប្រាកដ* | *មាន ....... នាក់* |
| *205* | *ចំនួនកុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំ ដែលរស់នៅដោយឯកឯង* | *មាន ....... នាក់* |
| *206* | ***សរុបចំនួនកុមារឬក្មេងកំព្រា អាយុក្រោម១៨ឆ្នាំ*** | ***មាន ....... នាក់*** |

**ចំនួនកុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំ :** សំដៅទៅលើកុមារដែលមានអាយុក្រោម១៨ឆ្នាំ ដែលឪពុកម្តាយបានស្លាប់ទាំងពីរ និងកុមារដែលឪពុកឬម្តាយបោះបង់ចោល ហើយកុមារទាំងនោះរស់នៅជាមួយបងប្អូនជាសាច់ញាតិ (ជីដូន ជីតា អ៊ំ ពូ មីង មា ) ឬជាមួយអ្នកដ៏ទៃដែលមិនមែនជាសាច់ញាតិរបស់ខ្លួន ។ កុមារដែលឪពុកឬម្តាយបោះបង់ចោល អាចមានច្រើនករណីដូចជា : កុមារដែលមានឪពុកស្លាប់ឬម្តាយស្លាប់ ហើយឪពុកឬម្តាយដែលនៅរស់នោះ ទៅយកប្រពន្ធឬប្តីទៅនៅស្រុកឆ្ងាយដោយទុកកូនចោល ឬកុមារនោះត្រូវបានឪពុកម្តាយលែងលះគ្នា ហើយឪពុកម្តាយទៅយកគ្រួសារថ្មីរៀងៗខ្លួនដោយទុកកូនចោលរស់នៅតែលតោលគ្មានទីពឹង ។ ចំពោះកុមារកំព្រា ដែលបានប្រមូលផ្តុំចិញ្ចឹមនៅមណ្ឌលកុមារកំព្រា ឬនៅតាមទីកន្លែងផ្សេងៗរបស់

អង្គការមួយចំនួន ដែលមានទីតាំងនៅក្នុងឃុំសង្កាត់ មិនត្រូវរាប់បញ្ចូលឡើយ ព្រោះកុមារទាំងនោះមិនស្ថិតក្នុងប្រធានបទ ដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវលើកមកពិភាក្សារកដំណោះស្រាយឡើយ ។ មានមន្ទីរជំនាញនិងអង្គការសង្គមស៊ីវិលជាច្រើន ដែលកំពុងធ្វើការទាក់ទងនឹងការជួយគាំទ្រដល់កុមារដែលងាយរងគ្រោះទាំងនេះ ដែលក្រុមប្រឹក្សាឃុំ-សង្កាត់អាចទាក់ទងស្នើសុំកិច្ចសហការបាន ។ ប្រការសំខាន់នៅត្រង់ថា តើបញ្ហានេះមានលើកយកមកពិភាក្សាក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ឬគ្មានតែប៉ុណ្ណោះ ។

**កុមារកំព្រាមានអាណាព្យាបាលត្រឹមត្រូវ** : សំដៅទៅលើកុមារកំព្រាទាំងឡាយដែលរស់នៅជាមួយសាច់ញាតិ ឬអ្នកដទៃ ដែលមានចិត្តធម៌ ទំនុកបំរុងឱ្យបានរៀនសូត្រស្រឡាញ់ដូចកូនបង្កើត។

**កុមារកំព្រាគ្មានអាណាព្យាបាលត្រឹមត្រូវពិតប្រាកដ** : សំដៅទៅលើកុមារកំព្រាទាំងឡាយដែលរស់នៅជាមួយសាច់ញាតិឬអ្នកដទៃ តែមិនសូវចិត្តធម៌ ពេលនឹកអាណឹតហៅមកនៅជាមួយ ពេលខឹងដេញកុមារនោះមិនឱ្យនៅជាមួយ ធ្វើឱ្យកុមារទាំងនោះផ្លាស់ប្តូរលំនៅជាញឹកញាប់( ម្តងនៅជាមួយអ្នកនេះ ម្តងនៅជាមួយអ្នកនោះ )ដែលធ្វើឱ្យកុមារមិនមានឱកាសបានរៀនសូត្រឡើយ ។

**កុមារកំព្រារស់នៅដោយឯកឯង** : កុមារកំព្រាប្រភេទនេះ ភាគច្រើនជាកុមារកំព្រាដែលឪពុកម្តាយស្លាប់ចោលដោយសារគ្រោះថ្នាក់អ្វីមួយ ហើយបានបន្សល់ទុកនូវកេរ្តិ៍មរតក ដូចជាដីភូមិ ផ្ទះ គោ-ក្របី ដីស្រែ .. ឱ្យគ្រប់គ្រង ។

**សរុបចំនួនកុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំ =** ចំនួនកុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំដែលមានអាណាព្យាបាលត្រឹមត្រូវ + ចំនួនកុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំដែលគ្មានអាណាព្យាបាលត្រឹមត្រូវពិតប្រាកដ + ចំនួនកុមារឬក្មេងកំព្រាអាយុក្រោម១៨ឆ្នាំដែលរស់នៅដោយឯកឯង។

***ការចាប់រំលោភនិងជួញដូរ (បើគ្មានបំពេញលេខសូន្យ) :***

| | **បរិយាយ** | **អាយុក្រោម ១៨ឆ្នាំ** | **អាយុ១៨ ឆ្នាំឡើង** | **សរុប** |
|---|---|---|---|---|
| *207* | *ចំនួនជនរងគ្រោះដោយសារការចាប់រំលោភ* | *........ នាក់* | *...... នាក់* | *.. នាក់* |
| *208* | *ចំនួនជនរងគ្រោះដោយសារការជួញដូរ* | *........ នាក់* | *....... នាក់* | *.... នាក់* |

**ការរំលោភផ្លូវភេទ :** គឺជាសកម្មភាពបង្ខិតបង្ខំ ឬបោកបញ្ឆោតក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ច ជាពិសេសកុមារនិងស្ត្រីឱ្យរួមភេទ ។ **ការបង្ខិតបង្ខំ** គឺសំដៅលើការគំរាមកំហែង ការប្រើប្រាស់កំលាំង ការចាប់ពង្រត់ ការរំលោភបំពានដោយប្រើអំណាច ឬក៏ដាក់ក្នុងស្ថានភាពដែលងាយរងគ្រោះ ។ **ការកេងប្រវ័ញ្ច** រួមមាន ការបំពានផ្លូវភេទដោយឆបោក ក្លែងបន្លំ សំដៅយកចំណេញលើផ្នែកណាមួយនៃសរីរាង្គកាយ ។ ករណីនេះកើតមាននៅពេលដែលកុមារ (ពេលខ្លះសូម្បីក្មេងចាប់ពីអាយុ៣ឆ្នាំឡើងទៅនិងទារក) ត្រូវបានយកទៅ ឬបង្ខំឱ្យបំរើផ្លូវភេទជាមួយនឹងអ្នកដែលមានវ័យចាស់ជាង ។ សកម្មភាពទាំងនេះរួមបញ្ចូលអ្វីៗដែលប្រឈមនឹងអំពើអាសអាភាស ចាប់តាំងពីការស្ទាបអង្អែលកេ្តិ៍ភេទក្នុងរបៀបរួមភេទនិងការចាប់រំលោភ ។ ការកត់ត្រានេះផ្តោតសំខាន់ទៅលើចំនួនអ្នកដែលរងគ្រោះ ដែលមេភូមិបានដឹង ទោះបីការចាប់រំលោភនោះគ្មានការប្តឹងជាផ្លូវការក៏ដោយ ។ បច្ចុប្បន្ន មានមន្ទីរជំនាញនិងអង្គការនានាកំពុងធ្វើការងារជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីលុបបំបាត់បញ្ហានេះ ប៉ុន្តែចំនួនតួលេខពិតប្រាកដនៃជនរងគ្រោះមិនទាន់មានការកត់ត្រាជាប្រចាំ នៅក្នុងសៀវភៅស្ថិតិភូមិឬឃុំ-សង្កាត់ឡើយ ។ **ចំនួនជនរងគ្រោះ(កុមារីនិងស្ត្រី) ដោយសារការជួញដូរ :** គឺជាចំនួនកុមារីនិងស្ត្រីដែលរងការបង្ខិតបង្ខំ គំរាមកំហែង ការប្រើប្រាស់កំលាំង ការចាប់ពង្រត់ ការក្លែងបន្លំ ការឆបោក យកទៅលក់ឱ្យ

មនុស្សទី៣ ឬទី៤ ទី៥.. ។ ការកត់ត្រានេះ អាស្រ័យទៅលើមេភូមិដែលដឹងឮនៅក្នុងឆ្នាំនិមួយៗ តែមិនត្រូវកត់ត្រាក្នុងករណីមានលក់ឬទិញ(ថ្លៃទឹកដោះ)កូនយកមកចិញ្ចឹមឡើយ។

ការដោះស្រាយបញ្ហាទាំងប៉ុន្មានខាងលើនេះអាចធ្វើឡើងតាមច្រើនរូបភាព ដូចជាវិធានការច្បាប់ចំពោះជនល្មើស ការជួយផ្តល់ជំរកការពារភាពសុខសាន្តដល់ជនរងគ្រោះ ការផ្តល់ភាពកក់ក្តៅលួងលោមផ្លូវចិត្តដល់ជនរងគ្រោះ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបរផ្សេងៗដល់ជនរងគ្រោះ និងការបង្កើតបណ្តាញការពារស្ត្រីនិងកុមារជាដើម។ ទំហំនៃកម្មវិធី ឬ គំរោង ឬ ទីតាំងអនុវត្តសកម្មភាពដែលត្រូវរៀបចំឡើងតាមឃុំ-សង្កាត់ អាស្រ័យទៅតាមចំនួនស្ថិតិជាក់ស្តែង ដែលភូមិបានកត់ត្រា នៅក្នុងសៀវភៅស្ថិតិភូមិនេះ។

***ជនពិការ (បើគ្មានបំពេញលេខសូន្យ) :***

| | ***បរិយាយ*** | ***សរុប*** | ***ស្រី*** |
|---|---|---|---|
| ***209*** | *ចំនួនជនពិការអាចរកចំណូលបាន (រកស៊ីប៉ះកង់ កាត់សក់ សិប្បកម្ម ម៉ាស្សា..)* | ........ *នាក់* | ........ *នាក់* |
| ***210*** | *ចំនួនជនពិការមិនអាចធ្វើការរកចំណូលបាន (រួមទាំងជនពិការដើរសុំទាន)* | ........ *នាក់* | ........ *នាក់* |
| ***211*** | *ក្នុងនោះ ជនពិការអាយុក្រោម១៨ ឆ្នាំ* | ........ *នាក់* | ........ *នាក់* |

**ជនពិការ :** គឺសំដៅលើប្រជាពលរដ្ឋនៅក្នុងភូមិ ដែលទទួលរងនូវការមើលមិនឃើញ ស្តាប់មិនឮ និយាយមិនកើត ដើរមិនបាន បាត់សតិវិកលចរិក ឬបាត់បង់នូវលទ្ធភាពការងារមួយចំនួនឬទាំងស្រុង ដូចជា បាត់បង់អវយវៈ ភ្នែក ដែលបណ្តាលមកពីសង្គ្រាម ការផ្ទុះមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ គ្រោះថ្នាក់ចរាចរ គ្រោះថ្នាក់ក្នុងពេលបំពេញការងារ ដោយសារជំងឺដង្កាត់ផ្សេងៗនិងពីកំណើត ។

**ចំនួនជនពិការដែលអាចធ្វើការរកចំណូលបាន** : សំដៅទៅលើជនពិការដែលមានប្រកបមុខរបរ ឬមានជំនាញវិជ្ជាជីវៈ ដូចជា កាត់សក់ ប៉ះកង់ ជួសជុលម៉ូតូ ជាងចម្លាក់ឈើ ថ្ម ...។ល ។ ចំពោះជនពិការដែលបានប្រមូលផ្តុំចិញ្ចឹមនៅមជ្ឈមណ្ឌលជនពិការ ឬនៅតាមទីកន្លែងផ្សេងៗរបស់អង្គការមួយចំនួនដែលមានទីតាំងនៅក្នុងឃុំសង្កាត់មិនត្រូវរាប់បញ្ចូលឡើយ ព្រោះជនពិការទាំងនោះ ត្រូវស្ថិតនៅក្រោមការថែរក្សាដោយអង្គការផ្ទាល់ មិនទាមទារក្រុមប្រឹក្សាឃុំ-សង្កាត់ ពិភាក្សារកដំណោះស្រាយឡើយ ។

**ចំនួនជនពិការដែលមិនអាចធ្វើការរកចំណូលបាន** : សំដៅទៅលើជនពិការដែលនៅក្មេង ឬមិនទាន់មានមុខរបរ គ្មានជំនាញវិជ្ជាជីវៈ និងគ្មានលទ្ធភាពធ្វើការតែម្តង ។ ការកត់ត្រាចំនួនជនពិការប្រភេទនេះ ត្រូវកត់ត្រារួមទាំងជនពិការដើរសុំទានគេផង ព្រោះការដើរសុំទានគេមិនមែនជាមុខរបរឬជាជំនាញវិជ្ជាជីវៈឡើយ ។ ស្ថិតិនេះមានសារៈសំខាន់ ក្នុងការពិភាក្សាក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីស្វែងរកការជួយឧបត្ថម្ភគាំទ្រចំពោះជនពិការទាំងនោះ ដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់ឥណទាន ការផ្តល់លទ្ធភាពពលកម្ម។ល។

| | | |
|---|---|---|
| *212* | *ចំនួនមនុស្សចាស់ជរាដែលគ្មានទីពឹង* | *មាន ............... នាក់* |
| *213* | *ចំនួនជនរងគ្រោះដោយសារមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ* | *មាន ............... នាក់* |
| *214* | *ចំនួនករណីផ្ទុះមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ* | *មាន ........... ករណី* |

**មនុស្សចាស់ជរាដែលគ្មានទីពឹង** : សំដៅទៅជនជរាដែលគ្មានកូនចៅរស់នៅជាមួយ រស់នៅដោយឯកឯង ឯកកោរ គ្មានទីពឹង គ្មានការគាំពារ ដែលកំពុងរស់នៅក្នុងស្ថានភាពយ៉ាងលំបាកវេទនា ។ ស្ថិតិនេះ ត្រូវការផ្តល់ចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីអំពាវនាវស្វែងរកសប្បុរសជន ជួយទំនុកបំរុង ឬឧបត្ថម្ភជាសំភារៈផ្សេងៗ ។

**ចំនួនជនរងគ្រោះដោយសារមីន ឬគ្រាប់មិនទាន់ផ្ទុះ :** ការកត់ត្រាផ្នែកនេះ សំដៅទៅលើប្រជាជននៅក្នុងភូមិ ដែលទទួលរងគ្រោះថ្នាក់ដោយសារផ្ទុះមីន ឬដោយសារគ្រាប់យុទ្ធភណ្ឌផ្សេងៗ ដូចជា គ្រាប់បែក គ្រាប់កាំភ្លើង ... ។ល។ ដែលកើតមានឡើងនៅក្នុងឆ្នាំនេះតែប៉ុណ្ណោះ ។ ចំពោះប្រជាជនដែលមកពីក្រៅ ហើយមានគ្រោះថ្នាក់នៅក្នុងភូមិមិនត្រូវកត់ត្រាបញ្ចូលឡើយ ។ ស្ថិតិនេះ ត្រូវការចាំបាច់សំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ធ្វើការពិភាក្សានិងស្វែងរកការគាំទ្រពីអង្គការនានាដែលធ្វើការងារនេះ។

**ចំនួនករណីផ្ទុះមីនឬគ្រាប់មិនទាន់ផ្ទុះ** : ការកត់ត្រានេះ ដើម្បីធ្វើការបញ្ជាក់ឱ្យកាន់តែច្បាស់ថា តើនៅក្នុងភូមិមានការផ្ទុះគ្រាប់មីនឬគ្រាប់យុទ្ធភណ្ឌផ្សេងៗ ប៉ុន្មានដង មានជនរងគ្រោះប៉ុន្មាននាក់ ?។ ឧ. ក្នុងករណីខ្លះនៅក្នុងភូមិមានផ្ទុះគ្រាប់មីន៣លើក ប៉ុន្តែចំនួនជនរងគ្រោះគ្មាន មានន័យថាអ្នករងគ្រោះមកពីភូមិផ្សេងៗដែលមិនដឹងថាតំបន់នេះមានគ្រាប់មីន ។

# ទិន្នន័យភូមិបន្ថែម

*អត្ថន័យពាក្យ **ជនជាតិដើមភាគតិច** គឺសំដៅក្រុមអ្នកស្រុកដែលមានប្រវត្តិតាំងនិវេសនដ្ឋានមុនគេ(ចាស់បុរាណ)តាមតំបន់ក្នុងប្រទេស ដែលប្រកាន់យកទំនៀមទំលាប់ ប្រពៃណី វប្បធម៌ ភាសា និងរបៀបរស់នៅប្រចាំថ្ងៃ ដោយឡែករបស់ពួកគេ។*

## ១.ជនជាតិដើមភាគតិច

| | ជនជាតិដើមភាគតិច | ចំនួនគ្រួសារ | អាយុពី ០ ដល់ ១៧ ឆ្នាំ | | អាយុពី ១៨ ឆ្នាំឡើង | | ចំនួនប្រជាជនសរុប |
|---|---|---|---|---|---|---|---|
| | | | ប្រុស | ស្រី | ប្រុស | ស្រី | |
| *215* | ព្នង | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *216* | កួយ | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *217* | ស្ទៀង | ....... គ្រួសារ | .... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *218* | មិល | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | ......... នាក់ |
| *219* | ក្រោល | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *220* | ថ្មូន | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *221* | ខោញ | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *222* | ទំពួន | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *223* | ចារាយ | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *224* | គ្រឹង | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *225* | កាវ៉ែត | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *226* | ស្អូច | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *227* | លន់ | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *228* | កាចក់ | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *229* | ព្រៅ | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |
| *230* | ផ្សេងៗ | ....... គ្រួសារ | ..... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | .......... នាក់ |

សំគាល់ ៖ ផ្សេងៗសំដៅទៅលើជនជាតិដើមភាគតិចដែលមិនមានឈ្មោះនៅក្នុងតារាងខាងលើ ។

## ជនជាតិភាគតិច

| | ជនជាតិភាគតិច | ចំនួនគ្រួសារ | អាយុពី ០ ដល់ ១៧ ឆ្នាំ | | អាយុពី ១៨ ឆ្នាំឡើង | | ចំនួនប្រជាជនសរុប |
|---|---|---|---|---|---|---|---|
| | | | ប្រុស | ស្រី | ប្រុស | ស្រី | |
| *231* | ខ្មែរឥស្លាម | ....... គ្រួសារ | .... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | ....... នាក់ |
| *232* | វៀតណាម | ....... គ្រួសារ | .... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | ....... នាក់ |
| *233* | ឡាវ | ....... គ្រួសារ | .... នាក់ | .... នាក់ | ...... នាក់ | ...... នាក់ | ....... នាក់ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីពន្យល់ខ្លឹមសារសំណួរក្នុងសៀវភៅទិន្នន័យឃុំ/សង្កាត់

## សំរាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់

រៀបចំដោយក្រុមការងារសិលានិងសិទ្ធិកុមារ ក្រសួងផែនការ

គាំទ្រដោយៈ STF/PLG, Seth Koma Programme of UNICEF

ឆ្នាំ២០០៦

# ស្ថិតិថ្នាក់ឃុំ

*ដោយមូលហេតុភូមិពុំទាន់មានព្រំប្រទល់ច្បាស់លាស់នៅឡើយ នាំឱ្យមានការពិបាកក្នុងការញែកស្ថិតិមួយចំនួនឱ្យដាច់តាមភូមិបាន ហេតុនេះនាំឱ្យមានការកត់ត្រាសរុបស្ថិតិទាំងនោះ ធ្វើនៅថ្នាក់ឃុំ-សង្កាត់វិញ ដោយចាត់ទុកថាជាធនធានសរុបរួមរបស់ឃុំ-សង្កាត់ ។*

***<u>ផ្នែកអប់រំ</u>***

| ល.រ | ប្រភេទសាលា | ចំនួនសាលា ឬទីតាំង | ចំនួន បន្ទប់រៀន | ចំនួន ថ្នាក់រៀន |
|---|---|---|---|---|
| 234 | មត្តេយ្យសហគមន៍ក្នុងឃុំ | ....... កន្លែង | ......... បន្ទប់ | ..... ថ្នាក់ |
| 235 | សាលាមត្តេយ្យរដ្ឋក្នុងឃុំ | ....... សាលា | ......... បន្ទប់ | ..... ថ្នាក់ |
| 236 | សាលាបឋមសិក្សានៅក្នុងឃុំ | ....... សាលា | ......... បន្ទប់ | ..... ថ្នាក់ |
| 237 | សាលាអនុវិទ្យាល័យនៅក្នុងឃុំ | ....... សាលា | ......... បន្ទប់ | ..... ថ្នាក់ |
| 238 | សាលាវិទ្យាល័យនៅក្នុងឃុំ | ....... សាលា | ......... បន្ទប់ | ..... ថ្នាក់ |
| 239 | សាលាបង្រៀនឯកជន (គិតត្រឹមវិទ្យាល័យចុះក្រោម) | ....... សាលា | ......... បន្ទប់ | ..... ថ្នាក់ |

*សំគាល់ : ចំនួនថ្នាក់រៀនអាចច្រើនជាងចំនួនបន្ទប់រៀនព្រោះអាចរៀនលើសពី១វេន ។*

មត្តេយ្យសហគមន៍ សំដៅទៅលើថ្នាក់មត្តេយ្យទាំងឡាយណាដែលគ្រូបង្រៀននោះមិនមែនជាគ្រូក្នុងក្របខណ្ឌរដ្ឋ ។

ការកត់ត្រាចំនួនបន្ទប់រៀន និងចំនួនថ្នាក់រៀន គឺគិតទៅលើម្ចាស់កម្មសិទ្ធនៃអាគារសិក្សា **ឧទាហរណ៍ :** សាលាអនុវិទ្យាល័យនៅជាមួយសាលាបឋមសិក្សាមាន៣ថ្នាក់ (អនុវិទ្យាល័យខ្ចីបន្ទប់សាលាបឋមសិក្សា) ការកត់ត្រាចំនួនសាលា គឺ ១ សាលា ចំនួនបន្ទប់រៀន **សូន្យ** ចំនួនថ្នាក់មាន ៣ ថ្នាក់ មាន

ន័យថា នៅក្នុងឃុំមានសាលាអនុវិទ្យាល័យមានសិស្សរៀន៣ថ្នាក់ ប៉ុន្តែសាលាអនុវិទ្យាល័យមិនទាន់បានសង់ ហើយសាលាអនុវិទ្យាល័យបានខ្ចីបន្ទប់របស់សាលាបឋមសិក្សា ដូចនេះចំនួនបន្ទប់រៀនសិស្សថ្នាក់អនុវិទ្យាល័យមិនត្រូវកត់ត្រាឡើយ ព្រោះបន្ទប់នេះជាកម្មសិទ្ធិរបស់សាលាបឋមសិក្សា ។

ផ្ទុយទៅវិញ ប្រសិនបើសាលាអនុវិទ្យាល័យនៅជាមួយសាលាបឋមសិក្សា ហើយមានអាគារសិក្សារៀងៗខ្លួន (ហេតុផលដោយសារគ្មានដីកន្លែងផ្សេង ហើយដីសាលាបឋមសិក្សាធំ ទូលាយ) ការកត់ត្រាចំនួនសាលា ចំនួនបន្ទប់រៀន និងចំនួនថ្នាក់រៀនមានរៀងៗខ្លួន គឺអាស្រ័យទៅលើម្ចាស់កម្មសិទ្ធិនៃអាគារសិក្សា ។

ដូចគ្នានេះដែរ ការកត់ត្រាចំនួនសាលា ចំនួនបន្ទប់រៀន និងចំនួនថ្នាក់រៀន ចំពោះសាលាវិទ្យាល័យនៅជាមួយសាលាអនុវិទ្យាល័យ ឬសាលាមត្តេយ្យរដ្ឋខ្ចីបន្ទប់សាលាបឋមសិក្សា ។

**សាលាបង្រៀនឯកជន(កំរិតត្រឹមវិទ្យាល័យចុះក្រោម) :** សំដៅយកសាលារៀនឯកជនទាំងឡាយណាដែលបានបើកធ្វើអាជីវកម្មស្របច្បាប់លើវិស័យអប់រំ ដែលគិតសរុបបញ្ចូលគ្នាទាំងសាលាមត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ។ ឧទាហរណ៍ : សាលាឯកជនមួយកន្លែង(១សាលា) មានបង្រៀនកំរិតមត្តេយ្យសិក្សា**២**ថ្នាក់ កំរិតបឋមសិក្សា**៤**ថ្នាក់ និងកំរិតសិក្សាអនុវិទ្យាល័យមាន**១**ថ្នាក់ ការកត់ត្រាគឺមាន១សាលា មាន**៧**ថ្នាក់ ចំនួនបន្ទប់អាស្រ័យលើ

ភាពជាក់ស្តែង ព្រោះចំនួនបន្ទប់រៀនអាចមានតិចជាងចំនួនថ្នាក់ ប៉ុន្តែមិនត្រូវគិតបញ្ចូលថ្នាក់បង្រៀនគួរក្រៅម៉ោងថាជាសាលាឡើយ ។

***ចំនួនគ្រូបង្រៀនផ្ទាល់នៅតាមសាលារៀន ដោយមិនរាប់បញ្ចូលចំនួនបុគ្គលិកធ្វើការងារក្នុងការិយាល័យ មាន :***

| | | | |
|---|---|---|---|
| 240 | *ចំនួនគ្រូបង្រៀនផ្ទាល់នៅមត្តេយ្យសហគមន៍ក្នុងឃុំ* | *សរុប ... នាក់* | *ស្រី ... នាក់* |
| 241 | *ចំនួនគ្រូបង្រៀនផ្ទាល់នៅសាលាមត្តេយ្យរដ្ឋក្នុងឃុំ* | *សរុប ... នាក់* | *ស្រី ... នាក់* |
| 242 | *ចំនួនគ្រូបង្រៀនផ្ទាល់នៅសាលាបឋមសិក្សាក្នុងឃុំ* | *សរុប .... នាក់* | *ស្រី ... នាក់* |
| 243 | *ចំនួនគ្រូបង្រៀនផ្ទាល់នៅសាលាអនុវិទ្យាល័យក្នុងឃុំ* | *សរុប .... នាក់* | *ស្រី ... នាក់* |
| 244 | *ចំនួនគ្រូបង្រៀនផ្ទាល់នៅសាលាវិទ្យាល័យក្នុងឃុំ* | *សរុប .... នាក់* | *ស្រី ... នាក់* |
| 245 | *ចំនួនគ្រូបង្រៀននៅសាលាឯកជន (កំរិតត្រឹមវិទ្យាល័យចុះក្រោម)* | *សរុប .... នាក់* | *ស្រី ... នាក់* |

ស្ថិតិនេះមិនសំដៅលើចំនួនគ្រូបង្រៀន ដែលរស់នៅក្នុងឃុំឡើយ គឺជាស្ថិតិចំនួនគ្រូដែលផ្តល់សេវាបង្រៀនសិស្សនៅក្នុងដែនរដ្ឋបាលឃុំប៉ុណ្ណោះ ដើម្បីជៀសវាងការកត់ត្រាស្ថិតិត្រួត គ្នា។ ឧ. បើគ្រូបង្រៀនម្នាក់រស់នៅក្នុងឃុំ"ក" ប៉ុន្តែបានទៅបង្រៀនសិស្សនៅឃុំ"ខ" នោះឃុំ"ខ"ជាអ្នកចុះចំនួនស្ថិតិ ចំណែកឃុំ"ក" មិនត្រូវចុះស្ថិតិឡើយ ។ ហេតុផលគឺថានៅក្នុង ឃុំ"ក" គាត់ជាប្រជាជនធម្មតា ប៉ុន្តែពេលទៅធ្វើការនៅឃុំ"ខ" ទើបគាត់ក្លាយជាគ្រូបង្រៀន ហេតុនេះស្ថិតិត្រូវកត់ត្រានៅឃុំ"ខ" ។ ធ្វើបែបនេះ ដើម្បីយើងអាចបូកតួលេខស្ថិតិគ្រប់ឃុំនៅក្នុងស្រុក ដើម្បីបានជាតួលេខថ្នាក់ស្រុក ។ ចំពោះគ្រូបង្រៀន

ដែលខ្ចីពីកំរិតសិក្សាផ្សេង មិនត្រូវកត់បញ្ចូលឡើយ ដើម្បីកុំអោយត្រួតចំនួនតួលេខស្ថិតិសរុប។

**ការកត់ត្រាចំនួនគ្រូបង្រៀននៅសាលាឯកជន** គឺកត់ត្រាចំនួនគ្រូដែលបង្រៀនផ្ទាល់ ដោយរួមបញ្ចូលគ្នានូវគ្រូបង្រៀនផ្ទាល់ថ្នាក់មត្តេយ្យ ថ្នាក់បឋមសិក្សា ថ្នាក់អនុវិទ្យាល័យ និងថ្នាក់វិទ្យាល័យ ទោះបីគ្រូបង្រៀននោះ ជាគ្រូបង្រៀនមកពីសាលារដ្ឋក៏ដោយ តែមិនត្រូវរាប់បញ្ចូលបុគ្គលិកការិយាល័យឡើយ ។

***ថ្នាក់អក្ខរកម្មកំពុងដំណើរការនៅក្នុងឆ្នាំនេះ*** *(បើគ្មានបំពេញលេខសូន្យ)*

| | ថ្នាក់អក្ខរកម្មបើកដោយ : | ចំនួនថ្នាក់ | ចំនួនគ្រូអក្ខរកម្ម | | សិស្សចូលរៀនថ្នាក់អក្ខរកម្ម | |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី |
| 246 | មន្ទីរអប់រំ | ...... ថ្នាក់ | .... នាក់ | .... នាក់ | ........ នាក់ | ........ នាក់ |
| 247 | អង្គការនានា | ...... ថ្នាក់ | .... នាក់ | .... នាក់ | ........ នាក់ | ........ នាក់ |
| 248 | កម្មវិធីផ្សេងៗ | ...... ថ្នាក់ | .... នាក់ | .... នាក់ | ........ នាក់ | ........ នាក់ |
| 249 | **សរុប** | **...... ថ្នាក់** | **..... នាក់** | **..... នាក់** | **........ នាក់** | **........ នាក់** |

***ថ្នាក់អក្ខរកម្មបានបញ្ចប់នៅក្នុងឆ្នាំនេះ*** *(បើគ្មានបំពេញលេខសូន្យ)*

| | ថ្នាក់អក្ខរកម្មបានបញ្ចប់ដោយ : | ចំនួនថ្នាក់ | ចំនួនសិស្សបានចូលរៀន | | សិស្សបានប្រឡងជាប់ | |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី |
| 250 | មន្ទីរអប់រំ | ....... ថ្នាក់ | ....... នាក់ | ....... នាក់ | ...... នាក់ | ...... នាក់ |
| 251 | អង្គការនានា | ....... ថ្នាក់ | ....... នាក់ | ....... នាក់ | ...... នាក់ | ...... នាក់ |
| 252 | កម្មវិធីផ្សេងៗ | ....... ថ្នាក់ | ....... នាក់ | ....... នាក់ | ...... នាក់ | ...... នាក់ |
| 253 | **សរុប** | **....... ថ្នាក់** | **....... នាក់** | **....... នាក់** | **...... នាក់** | **...... នាក់** |

# ផ្នែកកសិកម្ម

*នៅក្នុងឃុំឆ្នាំនេះ ការងារបង្កបង្កើនផលស្រូវបានផលដូចខាងក្រោម (បើគ្មានបំពេញលេខសូន្យ) :*

| ស្រូវប្រាំង | | | |
|---|---|---|---|
| 254 | **សរុបផ្ទៃដីស្រូវប្រាំងក្នុងឃុំ មាន** | | **ចំនួន ........... ហិកតា** |
| 255 | **ផ្ទៃដីដែលបានដាំដុះស្រូវប្រាំងជាក់ស្តែង** | | **ចំនួន ........... ហិកតា** |
| 256 | *ក្នុងនោះ* | *ស្រូវប្រដេញទឹក* | *ចំនួន ........... ហិកតា* |
| 257 | | *ដោយបញ្ចូលទឹកទាំងស្រុង* | *ចំនួន ........... ហិកតា* |
| 258 | *ទិន្នផលស្រូវប្រាំងជាមធ្យមក្នុងមួយហិកតា* | | *.............. តោន* |
| 259 | *សរុបបរិមាណផលិតផលស្រូវប្រាំង (ប៉ាន់ស្មានក្នុងឆ្នាំ)* | | *ចំនួន ............ តោន* |

**ផ្ទៃដីស្រូវប្រាំងស្រូវប្រដេញទឹក** : ជាប្រភេទដីស្រែស្រូវប្រាំងដែលភ្ជួររាស់ដកស្ទូងប្រដេញតាមទឹកស្រក ពេលស្រូវលូតលាស់បែកគុម្ព ទើបបញ្ចូលទឹក ឬបូមទឹកដាក់ បើខ្វះទឹក ។

**ផ្ទៃដីស្រូវប្រាំងដោយបញ្ចូលទឹកទាំងស្រុង** : សំដៅទៅលើដីស្រែប្រាំងដែលធ្វើការបញ្ចូលទឹក ឬបូមទឹកដាក់ស្រែ តាំងពីចាប់ផ្តើមភ្ជួររាស់រហូតដល់ស្រូវបានផល (បញ្ចូលទឹកមួយចប់) ។

| ស្រូវវស្សា | | | |
|---|---|---|---|
| 260 | សរុបផ្ទៃដីស្រូវវស្សាក្នុងឃុំ មាន | | ចំនួន.......... ហិកតា |
| 261 | ផ្ទៃដីដែលបានដាំដុះស្រូវវស្សាជាក់ស្តែង | | ចំនួន.......... ហិកតា |
| 262 | ផ្ទៃដីស្រូវវស្សាពឹងទឹកភ្លៀងទាំងស្រុង | | ចំនួន.......... ហិកតា |
| 263 | ផ្ទៃដីស្រូវវស្សាបញ្ចូលទឹកបង្គ្រប់ | | ចំនួន.......... ហិកតា |
| 264 | ក្នុងនោះ | ផ្ទៃដីស្រែបានបញ្ចូលទឹកពីប្រឡាយ-ទំនប់ | ចំនួន.......... ហិកតា |
| 265 | | ផ្ទៃដីស្រែបានបញ្ចូលទឹកពីទន្លេ ស្ទឹង បឹង អូរ ត្រពាំងធម្មជាតិ | ចំនួន.......... ហិកតា |
| 266 | | ផ្ទៃដីស្រែបានបញ្ចូលទឹកពីប្រភពទឹកអណ្តូងខួង | ចំនួន.......... ហិកតា |
| 267 | | ផ្ទៃដីស្រែបានបញ្ចូលទឹកពីប្រភពទឹកស្រះជីក | ចំនួន.......... ហិកតា |
| 268 | ទិន្នផលស្រូវវស្សាជាមធ្យមក្នុងមួយហិកតា | | .............. តោន |
| 269 | សរុបបរិមាណផលិតផលស្រូវវស្សា (ប៉ាន់ស្មានក្នុងឆ្នាំ) | | ចំនួន........... តោន |

**ផ្ទៃដីស្រូវវស្សាពឹងទឹកភ្លៀងទាំងស្រុង** : គឺជាដីស្រែរដូវវស្សាដែលធ្វើស្រែពឹងតែលើទឹកភ្លៀងទាំងស្រុងនៅពេលមានការរាំងស្ងួត ក៏គ្មានប្រភពទឹកណាដែលអាចជួយសង្គ្រោះស្រូវបានឡើយ។

**ផ្ទៃដីស្រូវវស្សាបញ្ចូលទឹកបង្គ្រប់** : គឺជាដីស្រែដែលធ្វើស្រូវនៅរដូវវស្សានៅដើមរដូវពឹងទឹកភ្លៀង ហើយនៅចុងរដូវទោះបីមានការរាំងស្ងួត(ស្ទើរទឹកភ្លៀង) ក៏អាចមានប្រភពទឹកបូម ឬបាចពីប្រឡាយ បឹង ស្ទឹង អូរ ឬត្រពាំង ដែលធានាស្រូវរដូវវស្សាមិនស្កក ។

**ស្ថិតិបរិមាណផលិតផលស្រូវ** : ជាចំនួនប៉ាន់ស្មានប្រចាំឆ្នាំ ហើយមិនគិតពីម្ចាស់កម្មសិទ្ធឡើយ គឺគិតតែក្នុងរង្វង់ដីព្រំប្រទល់រដ្ឋបាលឃុំប៉ុណ្ណោះ ។ ឧ. ស្រែក្នុងដីឃុំ"ក" ប៉ុន្តែម្ចាស់ស្រែរស់នៅក្នុងឃុំ"ខ" ស្ថិតិផ្ទៃដីបង្កបង្កើនផលនិងផលស្រូវ

ត្រូវកត់ត្រាបញ្ចូលក្នុងស្ថិតិឃុំ"ក" មិនមែនឃុំ"ខ" ។ ការធ្វើបែបនេះ ដើម្បីជៀសវាងការកត់ត្រាត្រួតគ្នា ដែលធ្វើអោយតួលេខសរុបថ្នាក់ស្រុកកើនខ្ពស់ហួសតួលេខជាក់ស្តែងដែលស្រុកមាន ព្រោះថាបើបូកតួលេខគ្រប់ឃុំនៅក្នុងស្រុក ចូលគ្នានោះនឹងទៅជាតួលេខស្ថិតិថ្នាក់ស្រុក។

ស្ថិតិនេះស្រង់ប្រចាំឆ្នាំ ដើម្បីធ្វើការប្រៀបធៀបលទ្ធផលសំរេចបានក្នុងអណត្តិរបស់ក្រុមប្រឹក្សាឃុំ ។

| ស្រូវបង្កើនរដូវ | | លើកទី១ | លើកទី២ |
|---|---|---|---|
| 270 | សរុបផ្ទៃដីដែលបានដាំដុះជាក់ស្តែង | ចំនួន ....... ហិកតា | ចំនួន .... ហិកតា |
| 271 | ទិន្នផលស្រូវជាមធ្យមក្នុងមួយហិកតា | ............ តោន | ........... តោន |
| 272 | សរុបបរិមាណផលិតផលស្រូវ (ប៉ាន់ស្មានក្នុងឆ្នាំ) | ចំនួន ........ តោន | ចំនួន ..... តោន |

*ស្រូវបង្កើនរដូវ(ឬស្រូវកាច់ជព្រាំង)សំដៅទៅលើដីស្រែទាំងឡាយណា ដែលបន្ទាប់ពីប្រមូលផលស្រូវវស្សារួចហើយនោះ ភ្ជួរដីបន្តធ្វើស្រែទៀត (ធ្វើស្រែ ២ដងឬ៣ដងក្នុងមួយឆ្នាំ) ។*

| ស្រូវចំការ | | |
|---|---|---|
| 273 | សរុបផ្ទៃដីស្រូវចំការដែលបានដាំដុះជាក់ស្តែង | ចំនួន .......... ហិកតា |
| 274 | ទិន្នផលស្រូវជាមធ្យមក្នុងមួយហិកតា | ............... តោន |
| 275 | សរុបបរិមាណផលិតផលស្រូវចំការ (ប៉ាន់ស្មានក្នុងឆ្នាំ) | ចំនួន ........... តោន |

## ផ្នែកប្រឡាយនិងប្រព័ន្ធធារាសាស្ត្រ

| | | |
|---|---|---|
| 276 | ប្រវែងប្រឡាយមានទឹកអាចប្រើប្រាស់បានរយៈពេល៦ខែក្នុងរដូវវស្សា | មាន ...... ម៉ែត្រ |
| 277 | ប្រវែងប្រឡាយដែលត្រូវការស្តារឡើងវិញ | មាន ...... ម៉ែត្រ |
| 278 | ប្រវែងប្រឡាយដែលត្រូវជីកថ្មី | មាន ...... ម៉ែត្រ |

## បរិមាណផលិតផលដំណាំចំការផ្សេងៗដែលបានដាំក្នុងដែនដីរដ្ឋបាលឃុំឆ្នាំនេះ :

| | ប្រភេទដំណាំ | ផ្ទៃដីដាំបានក្នុងឆ្នាំនេះ(ជាន់ស្មាន) | ទិន្នផលជាមធ្យមក្នុងមួយហិកតា | បរិមាណផលិតផល (ជាន់ស្មាន) |
|---|---|---|---|---|
| 279 | ដំណាំពោត | មាន ....ហិកតា | ......... តោន | ផលសរុប....តោន |
| 280 | ដំណាំសណ្តែកសៀង | មាន .....ហិកតា | ......... តោន | ផលសរុប....តោន |
| 281 | ដំណាំសណ្តែកបាយ | មាន .....ហិកតា | ......... តោន | ផលសរុប....តោន |
| 282 | ដំណាំសណ្តែកដី | មាន .....ហិកតា | ......... តោន | ផលសរុប....តោន |
| 283 | ដំណាំដំឡូងមី | មាន .....ហិកតា | ......... តោន | ផលសរុប....តោន |
| 284 | ដំណាំដំឡូងជ្វា | មាន .....ហិកតា | ......... តោន | ផលសរុប....តោន |
| 285 | ដំណាំល្ង | មាន .....ហិកតា | ......... តោន | ផលសរុប....តោន |

ស្ថិតិបរិមាណផលដំណាំចំការផ្សេងៗ គឺសំដៅចំពោះដំណាំមួយចំនួនដូចមានក្នុងតារាង ហើយស្ថិតក្នុងដែនដីរដ្ឋបាលឃុំដោយមិនគិតម្ចាស់កម្មសិទ្ធឡើយ ពោលគឺដីនៅក្នុងព្រំប្រទល់ឃុំណា ឃុំនោះជាអ្នកកត់ស្ថិតិ ។ ការកំណត់របៀបនេះ គឺដើម្បីកុំអោយនៅពេលបូកសរុបថ្នាក់ស្រុក ធ្វើអោយលើសចំនួនតួលេខស្ថិតិច្រើនខុសការពិត ។ ចំពោះដំណាំចំរុះ ពោត សណ្តែក ល្ងលាយគ្នាត្រូវគិតតាមដំណាំសំខាន់ ។ ក្នុងករណីការដាំដុះពីរដង ពោតលើកទី១ បន្ទាប់មកសណ្តែកជាលើកទី២ ស្ថិតិត្រូវគិតផ្ទៃដីដាំដុះដំណាំនោះ មានន័យថា ផ្ទៃដី

ដាំពោតក៏កត់ត្រា ហើយផ្ទៃដីដាំសណ្ដែកលើកទី២ ក៏ត្រូវកត់ត្រាដែរ ហេតុនេះ ចំនួនផ្ទៃដីដាំដុះសរុបអាចលើសផ្ទៃដីឃុំទាំងមូល ដោយសារការដាំដុះច្រើនលើក ។

# ផ្នែកគមនាគមន៍

## *ប្រភេទផ្លូវគោរ៉ុ បេតុងនិងប្រភេទលូ*(បើគ្មានសូមបំពេញលេខសូន្យ) :

| | បរិយាយ | ប្រភេទផ្លូវ | | | |
|---|---|---|---|---|---|
| | | បេទីមីណឺ | DBST | MAKADAM | ចាក់បេតុង |
| 286 | ចំនួនខ្សែ | មាន.... ខ្សែ | មាន.... ខ្សែ | មាន.... ខ្សែ | មាន.. ខ្សែ |
| 287 | ប្រវែងផ្លូវ | មាន... ម៉ែត្រ | មាន ... ម៉ែត្រ | មាន... ម៉ែត្រ | មាន.. ម៉ែត្រ |
| 288 | ប្រវែងផ្លូវដែលត្រូវជួសជុល | មាន... ម៉ែត្រ | មាន ... ម៉ែត្រ | មាន... ម៉ែត្រ | មាន.. ម៉ែត្រ |
| 289 | ប្រវែងផ្លូវដែលត្រូវធ្វើថ្មី | មាន... ម៉ែត្រ | មាន .... ម៉ែត្រ | មាន... ម៉ែត្រ | មាន.. ម៉ែត្រ |

| | បរិយាយ | ប្រភេទលូ មានមុខកាត់ចាប់ពី | | |
|---|---|---|---|---|
| | | 30-50 CM | 60-100 CM | 100 CM ឡើង |
| 290 | ចំនួនខ្សែ | មាន.... ខ្សែ | មាន.... ខ្សែ | មាន.... ខ្សែ |
| 291 | ប្រវែងលូ | មាន... ម៉ែត្រ | មាន ... ម៉ែត្រ | មាន... ម៉ែត្រ |
| 292 | ប្រវែងលូត្រូវជួសជុល | មាន... ម៉ែត្រ | មាន ... ម៉ែត្រ | មាន... ម៉ែត្រ |
| 293 | ប្រវែងលូត្រូវធ្វើថ្មី | មាន... ម៉ែត្រ | មាន ... ម៉ែត្រ | មាន... ម៉ែត្រ |

## ប្រភេទផ្លូវដី (បើគ្មានសូមបំពេញលេខសូន្យ) :

| | បរិយាយ | ប្រភេទផ្លូវលំ | | |
|---|---|---|---|---|
| | | ក្រួសក្រហម ខ្សាច់ភ្នំ | ផ្លូវលំដីសរ (លើកដីសរុច) | ផ្លូវលំធម្មតា (មិនទាន់លើកដី) |
| 294 | ចំនួនខ្សែ | មាន.... ខ្សែ | មាន.... ខ្សែ | មាន.... ខ្សែ |
| 295 | ប្រវែងផ្លូវ | មាន... ម៉ែត្រ | មាន ... ម៉ែត្រ | មាន... ម៉ែត្រ |
| 296 | ប្រវែងផ្លូវត្រូវជួសជុល | មាន... ម៉ែត្រ | មាន ... ម៉ែត្រ | មាន... ម៉ែត្រ |
| 297 | ប្រវែងផ្លូវត្រូវធ្វើថ្មី | មាន... ម៉ែត្រ | មាន ... ម៉ែត្រ | មាន... ម៉ែត្រ |

ផ្លូវលំនៅក្នុងឃុំសង្កាត់ សំដៅទៅលើផ្លូវទាំងឡាយណា ដែលឃុំសង្កាត់យល់ថាជាផ្លូវស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដែលត្រូវថែរក្សានិងធ្វើការអភិវឌ្ឍន៍ ។ ចំពោះឃុំសង្កាត់ដែលនៅក្នុងទឹក ឬទឹកលិចរយៈពេល ៦ខែ ប្រវែងផ្លូវលំគឺ សូន្យ គ.ម ។

## <u>សំណង់រំដោះទឹក</u> : (បើគ្មានសូមបំពេញលេខសូន្យ)

| | ប្រភេទសំណង់ | ចំនួនកន្លែង | ប្រវែង (ម៉ែត្រ) | សំណង់ដែលត្រូវជួសជុល | | សំណង់ថ្មីដែលត្រូវការចាំបាច់ | |
|---|---|---|---|---|---|---|---|
| | | | | ចំនួនកន្លែង | ប្រវែង (ម៉ែត្រ) | ចំនួនកន្លែង | ប្រវែង (ម៉ែត្រ) |
| 298 | លូទោល | .. កន្លែង | .... ម៉ែត្រ | ... កន្លែង | .... ម៉ែត្រ | .. កន្លែង | ...... ម៉ែត្រ |
| 299 | លូភ្លោះ | .. កន្លែង | .... ម៉ែត្រ | ... កន្លែង | .... ម៉ែត្រ | .. កន្លែង | ..... ម៉ែត្រ |
| 300 | លូទ្រីប (លូជ្រុង) | .. កន្លែង | .... ម៉ែត្រ | ... កន្លែង | .... ម៉ែត្រ | .. កន្លែង | ...... ម៉ែត្រ |
| 301 | ស្ពានឈើ | .. កន្លែង | .... ម៉ែត្រ | ... កន្លែង | .... ម៉ែត្រ | .. កន្លែង | ..... ម៉ែត្រ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 302 | ស្ពានបេតុង | .. កន្លែង | ... ម៉ែត្រ | ... កន្លែង | .... ម៉ែត្រ | .. កន្លែង | ...... ម៉ែត្រ |
| 303 | ស្ពានដែក | .. កន្លែង | ... ម៉ែត្រ | ... កន្លែង | .... ម៉ែត្រ | .. កន្លែង | ...... ម៉ែត្រ |
| 304 | សំណង់ផ្លូវបង្ហៀរទឹក | .. កន្លែង | ... ម៉ែត្រ | ... កន្លែង | .... ម៉ែត្រ | .. កន្លែង | ...... ម៉ែត្រ |

## ចំនួនគ្រួសារដែលបានចូលរួមក្នុងសហគមន៍នានា ដែលមាននៅក្នុងឃុំ :

| | | |
|---|---|---|
| 305 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍ព្រៃឈើ | ........... គ្រួសារ |
| 306 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍នេសាទ | ........... គ្រួសារ |
| 307 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍គ្រប់គ្រងធនធានធម្មជាតិ | ........... គ្រួសារ |
| 308 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍គ្រប់គ្រងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ | ........... គ្រួសារ |
| 309 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍ប្រើប្រាស់ទឹកស្អាតនិងអនាម័យ | ........... គ្រួសារ |
| 310 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍ថែទាំផ្លូវលំ | ........... គ្រួសារ |
| 311 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍អ្នកក្រីក្រ | ........... គ្រួសារ |
| 312 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍កសិករ | ........... គ្រួសារ |
| 313 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍ផលិតទឹកត្នោត | ........... គ្រួសារ |
| 314 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍ទេសចរណ៍ | ........... គ្រួសារ |
| 315 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍ផលិតអំបិល(កំពត) | ........... គ្រួសារ |
| 316 | ចំនួនគ្រួសារចូលរួមក្នុងសហគមន៍ផ្សេងៗ (គ្មានឈ្មោះសហគមន៍ខាងលើ) | ........... គ្រួសារ |

# ទិន្នន័យបន្ថែមថ្នាក់ឃុំ

## ផ្នែកសិប្បកម្មនិងអាជីវកម្មដោយគ្រឿងយន្តមាន :

| | | |
|---|---|---|
| 317 | ចំនួនម៉ាស៊ីនកិនស្រូវខ្នាតតូច | មាន .......... កន្លែង |
| 318 | ចំនួនម៉ាស៊ីនកិនស្រូវខ្នាតមធ្យមឬធំ | មាន .......... កន្លែង |
| 319 | ចំនួនម៉ាស៊ីនភ្លើងសំរាប់ធ្វើអាជីវកម្មផ្តល់ថាមពលអគ្គិសនី | មាន .......... កន្លែង |
| 320 | ចំនួនកន្លែងជួសជុលកង់ ម៉ូតូ | មាន .......... កន្លែង |
| 321 | ចំនួនកន្លែងជួសជុលគ្រឿងយន្តនិងឧបករណ៍កសិកម្ម | មាន .......... កន្លែង |
| 322 | ចំនួនកន្លែងជួសជុលគ្រឿងអេឡិចត្រូនិក | មាន .......... កន្លែង |
| 323 | ចំនួនកន្លែងសិប្បកម្មបិតស្រា | មាន .......... កន្លែង |
| 324 | ចំនួនកន្លែងសិប្បកម្មធ្វើគ្រឿងសង្ហារឹមអំពីឈើ និងអនុផលព្រៃឈើ | មាន .......... កន្លែង |
| 325 | ចំនួនកន្លែងសិប្បកម្ម ( ផ្សេងៗក្រៅពីគ្រឿងសង្ហារឹម ) | មាន .......... កន្លែង |

## ការធ្វើអាជីវកម្មផ្នែកសេវាកម្ម

| | | |
|---|---|---|
| 326 | ចំនួនសេវាកម្មខ្នាតតូច ( កាត់សក់ បំរើទូរសព្ទ័ ម៉ាស្សា ការ៉ាអូខេ ..... ) | មាន .......... កន្លែង |
| 327 | ចំនួនអាជីវកម្មខ្នាតតូច ( លក់ចាយ គ្រឿងទេស ភេសជ្ជៈ ...... ) | មាន .......... កន្លែង |
| 328 | ចំនួនផ្សារខ្នាតធំ | មាន .......... កន្លែង |
| 329 | ចំនួនផ្សារខ្នាតតូច | មាន .......... កន្លែង |
| 330 | ចំនួនឱសថស្ថាន និងឱសថស្ថានរង | មាន .......... កន្លែង |
| 331 | ចំនួនគ្លីនិច | មាន .......... កន្លែង |
| 332 | ចំនួនសណ្ឋាគារ | មាន .......... កន្លែង |
| 333 | ចំនួនផ្ទះសំណាក់ | មាន .......... កន្លែង |
| 334 | ចំនួនភោជនីយដ្ឋាន | មាន .........., កន្លែង |
| 335 | ចំនួនស្ថានីយ៍ប្រេងឥន្ធនៈ | មាន .......... កន្លែង |

**ចំនួនករណីអំពើហិង្សាក្នុងគ្រួសារ** *(បើគ្មានសូមបំពេញលេខសូន្យ)* **:**

| | | | |
|---|---|---|---|
| *336* | *សរុបចំនួនករណី(ដង)អំពើហិង្សាក្នុងគ្រួសារដែលមេភូមិបានរាយការណ៍* | | *មាន ........ ករណី* |
| *337* | *ក្នុងនោះ* | *អំពើហិង្សាផ្លូវកាយ* | *មាន ........ ករណី* |
| *338* | | *អំពើហិង្សាផ្លូវភេទ* | *មាន ........ ករណី* |
| *339* | | *អំពើហិង្សាផ្លូវចិត្ត* | *មាន ........ ករណី* |
| *340* | | *អំពើហិង្សាផ្នែកជីវភាពសេដ្ឋកិច្ច* | *មាន ........ ករណី* |
| *341* | *សរុបចំនួនសេចក្តីសំរេចរដ្ឋបាលផ្នែកអំពើហិង្សាក្នុងគ្រួសារ* | | *មាន ........ ករណី* |

ការកត់ត្រាស្ថិតិ**ចំនួនករណីអំពើហិង្សាក្នុងគ្រួសារ** ក្រុមប្រឹក្សាឃុំសង្កាត់ស្មៀនឃុំសង្កាត់ត្រូវធ្វើការបូកសរុបពី"**តារាងព័ត៌មានស្តីពីអំពើហិង្សាក្នុងគ្រួសារនៅតាមសហគមន៍** " នៃឯកសារស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដែលមេភូមិនិមួយៗបានរាយការណ៍ជាប្រចាំខែ ។

**សរុបចំនួនសេចក្តីសំរេចរដ្ឋបាលផ្នែកអំពើហិង្សាក្នុងគ្រួសារ :** គឺជាចំនួនលើកឬចំនួនដង ដែលឃុំសង្កាត់ចេញសេចក្តីសំរេចរដ្ឋបាល ក្នុងការធ្វើអន្តរាគមន៍នូវអំពើហិង្សាក្នុងគ្រួសារ ដែលកើតមានឡើងនៅក្នុងឃុំសង្កាត់ ។ ស្ថិតិដែលត្រូវស្រង់ក្នុងសំណួរនេះ ឃុំសង្កាត់ ស្មៀនត្រូវធ្វើការបូកសរុបពីតារាង **តារាងព័ត៌មានស្តីពីការធ្វើអន្តរាគមន៍លើករណីអំពើហិង្សាក្នុងគ្រួសារ** នៃឯកសារស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដែលឃុំសង្កាត់បានធ្វើការបូកសរុបប្រចាំខែ ។

ឯកសារស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ បានធ្វើការបណ្តុះបណ្តាលដោយក្រសួងមហាផ្ទៃនិងក្រសួងកិច្ចការនារី។

# កុមារទទួលថ្នាំបង្ការ គ្រប់មានសុខភាពល្អ



©UNICEF/CBD2006/Micheal Bierman

**ក្រសួងផែនការ**

អាគារលេខ:៣៨៦ មហាវិថីព្រះមុន្នីវង្ស សង្កាត់បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ:(០២៣) ២១៨ ៤០៦ /២១៥ ០៧២

ទូរសារ:(០២៣) ៧២០ ៩០៦

អ៊ីម៉ែល: eng@seila.gov.kh

NCDD Library
001359